**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ សហគមន៍អេកូទេសចរណ៍អារ៉ែង

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែ ០៤ ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែ ០៦ ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **សុខ ឧត្តម**
**ស៊ុយ ស្រីនិច**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈឹម ផាន់ណា**

ថ្នាក់បរិញ្ញាបត្រ **គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច** ឆ្នាំចូលសិក្សា ២០១៧
ជំនាន់ទី ៧ ឆ្នាំសរសេររបាយការណ៍ ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរ ឈ្មោះ **សុខ ឧត្តម** និង **ស៊ុយ ស្រីនិច** ជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ចឆ្នាំទី៤ ជំនាន់ទី ៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០២១។ ក្នុងនាមយើងខ្ញុំទាំងពីរនាក់ ជាយុវជនជំនាន់ក្រោយ ដែលជាទំពាំងស្នងឬស្សី និងជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ យើងខ្ញុំក៏បានសម្រេចចិត្តស្រាវជ្រាវ និងសរសេរជាសារណាក្រោមប្រធានបទស្តីពី « **ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍អារ៉ែង** » ដើម្បីជាដើមទុននិងចំណេះដឹងបន្ថែមដល់ប្អូនៗជំនាន់ក្រោយសម្រាប់ធ្វើជាស្ពានទៅរកភាពជោគជ័យនាថ្ងៃអនាគត។

ឆ្លៀតក្នុងឱកាសនេះផងដែរ យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ** ជាទីគោរព និងស្រលាញ់នៃកូន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ណែនាំប្រកបដោយកន្លងធម៌ ព្រមទាំងផ្តល់នូវក្តីអាណិតស្រឡាញ់ចំពោះកូនតាំងពីតូចរហូតដល់ធំពេញវ័យ ដោយអ្នកមានគុណទាំងពីរបានលះបង់នូវកម្លាំងកាយ និងកម្លាំងចិត្តព្រមទាំងបញ្ញា និងស្មារតី មិនតែប៉ុណ្ណោះលោកអ្នកមានគុណទាំងពីរបានចំណាយថវិកាជាច្រើនដើម្បីផ្គត់ផ្គង់យើងខ្ញុំក្នុងការសិក្សារៀនសូត្រកន្លងមក។ គុណូបការៈ និងព្រហ្មវិហារធម៌ របស់លោកអ្នកមានគុណទាំងពីរ សម្រាប់យើងខ្ញុំគឺពិតជាធំធេងខ្លាំងណាស់ ធំជាងមហាសមុទ្រដែលគ្មានកោះត្រើយ និងរកអ្វីមកប្រៀបប្រដូចបានឡើយ។ កូនមិនអាចបំភ្លេចនូវទង្វើដែលល្អរបស់អ្នកមានគុណទាំងពីរមកលើកូនបានទេ ដោយកូនបានផ្ទុកវាទុកនៅក្នុងបេះដូងកូនជានិច្ចជារាប។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអប់រំអស់ពីសមត្ថភាពក្នុងការផ្ទេរ ចំណេះដឹង បទពិសោធន៍ ឯកសារ សិក្សាស្រាវជ្រាវ ដល់យើងខ្ញុំទាំងពីរក្នុងការសិក្សារៀនសូត្រ និងជាទីកន្លែងសម្រាប់ធ្វើការស្រាវជ្រាវ។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **លោកសាស្ត្រាចារ្យ ឈឹម ផាន់ណា** ដែលជាសាស្ត្រាចារ្យណែនាំ ដល់យើងខ្ញុំទាំងពីរ ព្រមទាំងបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញជ្រោមជ្រែង កែតម្រូវ និងអនុសាសន៍ល្អៗ ដែលធ្វើឱ្យការស្រាវជ្រាវមួយនេះ ដំណើរការទៅដោយរលូននិងប្រកបដោយលទ្ធផលល្អ។

ម៉្យាងទៀតយើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ ចំពោះ លោកតា លោកយាយ អ៊ុំប្រុស អ៊ុំស្រី លោកពូ អ្នកមីង បងប្អូន សិស្សច្បង មិត្តភក្តិទាំងអស់ដែលបានផ្តល់ជាកម្លាំងចិត្ត និងផ្តល់ជាគំនិតល្អៗ ជាច្រើន ក៏ដូចជាចែករំលែកនូវបទពិសោធន៍ ដល់យើងខ្ញុំទាំងពីរនាក់ក្នុងការសរសេរសារណាមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំ សូមឱ្យវត្ថុស័ក្តសិទ្ធិទាំងអស់ ក្នុងលោកតាមថែរក្សា ការពារ និងប្រសិទ្ធិពរជ័យ សិរីសួស្តីដល់យើងទាំងអស់គ្នា ឱ្យជៀសផុតពីជំងឺដ៏កាចសាហាវ និងជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ កាយសម្បទារឹងមាំ អាយុ យឺនយូ ជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធិពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងប្រទេសកម្ពុជា  វិស័យទេសចរណ៍គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បម្រើលើគ្រប់វិស័យជាច្រើនដូចជា៖ វិស័យសេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ សុខាភិបាល និង វិស័យផ្សេងៗ ជាច្រើនទៀត។ ជាមួយគ្នានេះដែរ វិស័យទេសចរណ៍គឺជាវិស័យមួយដែលជួយលើកស្ទួយមុខមាត់ប្រទេសជាតិ តាមរយៈការបង្ហាញនូវ វប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ និងធនធានធម្មជាតិដ៏សំបូរបែបនៅក្នុងប្រទេសកម្ពុជាទៅកាន់ភ្ញៀវទេសចរអន្តរជាតិ។

យើងខ្ញុំទាំងពីរនាក់មើលឃើញនូវទិដ្ឋភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា   សំបូរទៅដោយធនធានធម្មជាតិដ៏សំបូរបែប   និងទេសភាពដ៏ស្រស់ល្អគ្រកាលផ្សេងៗទើបធ្វើឱ្យយើងខ្ញុំទាំងពីរនាក់   ចង់ចងក្រងនូវឯកសារមួយចំនួនដែលពាក់ព័ន្ធទៅនឹងអេកូទេសចរណ៍ដើម្បីចែករំលែកភាពអស្ចារ្យនៅក្នុងប្រទេសកម្ពុជា ទើបយើងខ្ញុំពីរនាក់បានសម្រេចចិត្តស្រាវជ្រាវនូវ  ឯកសារសារណាបញ្ចប់ការសិក្សាមួយ  អំពី « **ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍អារ៉ែង** » ។ យើងខ្ញុំទាំងពីរនាក់មានជំនឿយ៉ាងមុតមាំថា សារៈណាបញ្ចប់ការសិក្សាមួយនេះនឹងអាចជួយដល់ប្រជាពលរដ្ឋខ្មែរដែលមានគម្រោងចង់យល់ដឹងអំពីអេកូទេសចរណ៍ និងផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍។ ម៉្យាងវិញទៀតសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំនេះ  នឹងអាចជួយពន្យល់បន្ថែមដល់និស្សិតជំនាន់ក្រោយឱ្យយល់ដឹងកាន់តែច្បាស់នូវ ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ក្នុងប្រទេសកម្ពុជា។

យ៉ាងណាមិញការស្រាវជ្រាវលើប្រធានបទនេះ គឺនៅមានចំណុចខ្វះចន្លោះ ទាំងពាក្យពេចន៍ និងអត្ថន័យខ្លឹមសារ អាស្រ័យហេតុនេះសូម លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដល់ការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ផង  ហើយយើងទាំងពីរនាក់មានភាពរីករាយយ៉ាងខ្លាំងក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះឱ្យមានភាពល្អប្រសើរ។

# មាតិកា

**ទំព័រ**

**បញ្ជីអក្សរកាត់**....................vi

**បញ្ជីរូបភាព**....................vii

**បញ្ជីតារាង**....................viii

## សេចក្តីផ្តើម

១. លំនាំបញ្ហា....................១

២. ចំណោទបញ្ហា....................២

៣. គោលបំណង....................៣

៤. សារៈប្រយោជន៍....................៣

៥. ទំហំនិងដែនកំណត់....................៣

៦. វិធីសាស្រ្ត....................៤

ក ប្រភពទិន្នន័យ....................៤

ខ ការប្រមូលទិន្នន័យ....................៤

គ ការវិភាគទិន្នន័យ....................៤

៧. រចនាសម្ព័ន្ធ....................៤

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១ ទេសចរណ៍....................៥

១.២ និយមន័យពាក់ព័ន្ធទេសចរណ៍....................៦

១.២.១ អ្វីទៅជាទេសចរ....................៦

១.២.២ អ្នកណាជាទេសចរ....................៧

១.៣ អេកូទេសចរណ៍....................៧

១.៣.១ អ្វីទៅជាអេកូទេសចរណ៍?....................៨

១.៣.២ ប្រវត្តិអេកូទេសចរណ៍....................១០

១.៣.៣ គោលការណ៍សំខាន់ៗអេកូទេសចរណ៍....................១០

១.៣.៤ ឥទ្ធិពលនានានៃអេកូទេសចរណ៍....................១១

១.៣.៥ គុណសម្បត្តិនិងគុណវិបត្តិនៃអេកូទេសចរណ៍....................១១

១.៤. តំបន់ការពារក្នុងសហគមន៍អេកូទេសចរណ៍ ......... ១២
១.៤.១. តំបន់ការពារជាអ្វី? ......... ១៣
១.៤.២. តួនាទីអេកូទេសចរណ៍ក្នុងតំបន់ការពារ ......... ១៥
១.៥. យល់ដឹងពីសហគមន៍ ......... ១៦
១.៥.១ តួនាទីសហគមន៍ក្នុងអេកូទេសចរណ៍ ......... ១៧
១.៦. ការអភិវឌ្ឍអេកូទេសចរណ៍ ......... ១៨
១.៦.១ និយមន័យការអភិវឌ្ឍ ......... ១៩
១.៦.២ ភាពចាំបាច់នៃការអភិវឌ្ឍទេសចរណ៍ ......... ១៩
១.៧ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍អេកូទេសចរណ៍កម្ពុជា ......... ២៣
១.៧.១ ធ្វើផែនការ និងបែងចែកជាតំបន់អេកូទេសចរណ៍អាទិភាពនិងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍គំរូ ......... ២៤

# ជំពូកទី២
# សហគមន៍អេកូទេសចរណ៍អារ៉ែង និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ

២.១ ប្រវត្តិនិងទីតាំងភូមិសាស្ត្រ ......... ២៧
២.១.១ មធ្យោបាយធ្វើដំណើរ ......... ២៨
២.១.២ ចាកចេញពីតំបន់ស្ទឹងអារ៉ែង ......... ២៩
២.២ ភាពអំណោយផល ......... ៣០
២.៣ ការបង្កើតសហគមន៍ ......... ៣០
២.៣.១ គោលបំណងក្នុងការបង្កើតសហគមន៍អារ៉ែង ......... ៣១
២.៣.២ ចក្ខុវិស័យ ......... ៣៤
២.៣.៣ គោលដៅ ......... ៣៤
២.៣.៤ តម្លៃស្នូល ......... ៣៤
២.៣.៥ ពីអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ......... ៣៤
២.៤ ផលប្រយោជន៍ចំពោះសហគមន៍អារ៉ែង ......... ៣៥
២.៥ ធនធានធម្មជាតិ សេវាកម្ម តំបន់កម្សាន្ត និងសកម្មភាពភ្ញៀវទេសចរ ......... ៣៦
២.៥.១ ធនធានធម្មជាតិ ......... ៣៦
២.៥.២ សេវាកម្ម ......... ៤០
២.៥.៣ តំបន់កម្សាន្ត ......... ៤៣
២.៥.៤ សកម្មភាពភ្ញៀវទេសចរ ......... ៤៦

២.៦ ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈនានា.....៥០
២.៧ ការអភិវឌ្ឍទេសចរណ៍បានផ្តល់ផលប៉ះពាល់វិជ្ជមាន.....៥០
២.៧.១ ផលប៉ះពាល់វិជ្ជមានចំពោះសេដ្ឋកិច្ច.....៥០
២.៧.២ ផលប៉ះពាល់វិជ្ជមានចំពោះបរិស្ថាន.....៥១
២.៧.៣ ផលប៉ះពាល់វិជ្ជមានចំពោះវប្បធម៌.....៥២
២.៧.៤ ផលប៉ះពាល់វិជ្ជមានចំពោះសង្គម.....៥២
២.៨ ការអភិវឌ្ឍទេសចរណ៍បានផ្តល់ផលប៉ះពាល់អវិជ្ជមាន.....៥៣
២.៨.១ ផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ច.....៥៣
២.៨.២ ផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន.....៥៤
២.៨.៣ ផលប៉ះពាល់អវិជ្ជមានចំពោះវប្បធម៌.....៥៤
២.៨.៤ ផលប៉ះពាល់អវិជ្ជមានចំពោះសង្គម.....៥៤
២.៩ យុទ្ធសាស្ត្រគ្រប់គ្រងអំពីផលប៉ះពាល់លើការអភិវឌ្ឍអេកូទេសចរណ៍អារ៉ែង.....៥៥
២.៩.១ ការគ្រប់គ្រងផលប៉ះពាល់នៃការអភិវឌ្ឍទេសចរណ៍.....៥៥
២.៩.២ ការគ្រប់គ្រងផលប៉ះពាល់ដើម្បីទទួលបាននិរន្តរភាព.....៥៨
២.១០ យុទ្ធសាស្ត្រម៉ាឃីតធីង និងការអប់រំ.....៦៣
២.១១ ការអភិវឌ្ឍ អភិរក្ស ថែរក្សា ការពារតំបន់អេកូទេសចរណ៍.....៦៤
២.១១.១ ការអភិរក្ស.....៦៤
២.១១.២ ការអភិវឌ្ឍ.....៦៤
២.១២ កត្តាសំខាន់ដើម្បីទទួលនិរន្តភាព.....៦៥

## ជំពូកទី៣

## ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍផលិតផលសហគមន៍អារ៉ែង

៣.១ កញ្ចប់សេវាកម្មទេសចរណ៍.....៦៧
៣.១.១ កញ្ចប់ធួររយៈពេលខ្លី.....៦៧
៣.១.១.១ សម្រាប់ភ្ញៀវជាក្រុម.....៦៧
៣.១.១.២ សម្រាប់ភ្ញៀវជាគ្រួសារ.....៦៧
៣.១.១.៣ សម្រាប់ភ្ញៀវជាក្រុមហ៊ុន.....៦៧
៣.១.២ កញ្ចប់ធួររយៈពេលវែង.....៦៨
៣.១.២.១ សម្រាប់ក្រុមអ្នកស្រាវជ្រាវរុករក.....៦៨
៣.១.២.២ អ្នកចិត្តសាស្ត្រ ធ្វើសមាធិ និងវិបាសនា.....៦៨

៣.១.៣ សេវាកម្មគោលសម្រាប់ទទួលភ្ញៀវទេសចរ ........ ៦៨
៣.១.៤ ផលិតផលទេសចរណ៍ ........ ៧១
៣.១.៤.១ ដបទឹក កែវទឹក សៀវភៅ ប៊ិច បរិស្ថានអាចឆ្លាក់រូបបាន ........ ៧១
៣.១.៤.២ ផ្ទាំងគំនូរ ចម្លាក់ស្បែកគោ និងចម្លាក់នានា ........ ៧២
៣.២ រចនាសម្ព័ន្ធទីផ្សារ ........ ៧២
៣.២.១ សម្បាទារទីផ្សារ ........ ៧៣
៣.២.២ ទីផ្សារឌីជីថល ........ ៧៣
៣.៣ ពង្រឹងគុណភាពសេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធ ........ ៧៤
៣.៣.១ សេវាកម្ម ........ ៧៤
៣.៣.១.១ ការស្នាក់នៅ ........ ៧៤
៣.៣.១.២ ម្ហូបអាហារ ........ ៧៤
៣.៣.១.៣ ការដឹកជញ្ជូន ........ ៧៥
៣.៣.២ ហេដ្ឋារចនាសម្ព័ន្ធ ........ ៧៥
៣.៣.២.១ ស្ពាន ផ្លូវថ្នល់ ប៉ុស្តិ៍សុខភាព ........ ៧៥
៣.៣.២.២ សេវាសាធារណៈផ្សេងៗ ........ ៧៥
៣.៣.៣ ការវិភាគទៅលើសហគមន៍អេកូទេសចរណ៍អារ៉ែង ........ ៧៥
៣.៣.៣.១ ភាពខ្លាំង ........ ៧៥
៣.៣.៣.២ ភាពខ្សោយ ........ ៧៦
៣.៣.៣.៣ ឱកាស ........ ៧៦
៣.៣.៣.៤ កត្តារារាំងនិងគំរាមកំហែង ........ ៧៦
**សន្និដ្ឋាន** ........ ៧៧
**អនុសាសន៍** ........ ៧៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

គ.ម : គីឡូម៉ែត្រ

UNWTO : United Nation World Tourism Organization

UNEP : The United Nations Environment Programme

IUCN : International Union for Conservation of Nature

STAR-CBET : The Steung Areng Community-Based Ecotourism Project

# បញ្ជីរូបភាព

**ទំព័រ**


រូបភាពទី១៖ ផែនទីគោលដៅទេសចរណ៍នៅក្នុងប្រទេសកម្ពុជា........................................................២៧
រូបភាពទី២៖ ភូមិនៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែង........................................................២៨
រូបភាពទី៣៖ ផែនទីតំបន់អេកូទេសចរណ៍ស្ទឹងអារ៉ែង........................................................៣០
រូបភាពទី៤៖ នៅតំបន់សហគមន៍ស្ទឹងអារ៉ែង........................................................៣២
រូបភាពទី៥៖ នៅមុខមជ្ឈមណ្ឌលសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង........................................................៣២
រូបភាពទី៦៖ ការចូលរួមសកម្មភាពក្នុងសហគមន៍........................................................៣៣
រូបភាពទី៧៖ ហូបអាហារថ្ងៃត្រង់........................................................៣៣
រូបភាពទី៨៖ ទឹកធ្លាក់ស្ទឹងត្រយ៉ាង........................................................៣៦
រូបភាពទី៩៖ តំបន់ព្រៃភ្នំនៅតំបន់អារ៉ែង........................................................៣៦
រូបភាពទី១០៖ ៣ង និងមឈូសបុរាណអាយុ៥០០ឆ្នាំ........................................................៣៧
រូបភាពទី១១៖ ត្រីនាគ........................................................៣៧
រូបភាពទី១២៖ សត្វក្រពើភ្នំ........................................................៣៨
រូបភាពទី១៣៖ សត្វទន្សោង........................................................៣៨
រូបភាពទី១៤៖ សត្វជ្រូកព្រៃ........................................................៣៩
រូបភាពទី១៥៖ សត្វខ្លាពពក........................................................៣៩
រូបភាពទី១៦៖ ពូម៉ូតូឌុប........................................................៤០
រូបភាពទី១៧៖ ជិះទូកមើលទេសភាព........................................................៤០
រូបភាពទី១៨៖ ជិះម៉ូតូចូលព្រៃបោះតង់........................................................៤១
រូបភាពទី១៩៖ អាំងត្រីជាអាហារពេលកំពុងសម្រាកក្នុងព្រៃបោះតង់........................................................៤១
រូបភាពទី២០៖ បោះតង់ស្រូបខ្យល់អាកាសបរិសុទ្ធ និងមើលទេសភាពពេលរាត្រីនៅភ្នំម្រេចកង្កែប..............៤២
រូបភាពទី២១៖ ទឹកជ្រោះឆាយយោង........................................................៤៣
រូបភាពទី២២៖ ទឹកធ្លាក់ឆាយតាប៉ាង........................................................៤៥
រូបភាពទី២៣៖ ជម្រកត្រីនាគ........................................................៤៥
រូបភាពទី២៣៖ រូបភាពផ្សេងៗទាក់ទងនិងសកម្មភាពដំណើរកម្សាន្តជាមួយទេសភាពធម្មជាតិតាមជួរភ្នំក្រវាញ
........................................................៤៨
រូបភាពទី២៤៖ ដបទឹក កែវទឹក សៀវភៅ ប៊ិច បរិស្ថានអាចធ្លាក់រូបបាន........................................................៧១
រូបភាពទី២៥៖ ផ្ទាំងគំនូរ........................................................៧២
រូបភាពទី២៦៖ Logo Website និង Page ផ្លូវការរបស់សហគមន៍អេកូទេសចរណ៍អារ៉ែង........................៧៣

# បញ្ជីតារាង

តារាងទី១៖ តារាងតម្លៃសេវាកម្ម..........................................................................................៧០

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជា ជាប្រទេសដែនដី អច្ឆរិយៈ សម្បូរទៅដោយធនធានធម្មជាតិ ធនធានជីវៈចម្រុះតំបន់ព្រៃត្រូពិចដ៏ធំជាងគេ ជាដែនជម្រកនិងជាឋានសួគ៌របស់សត្វព្រៃក្នុងទ្វីបអាស៊ី និងជាតំបន់មួយដែលមានសត្វព្រៃច្រើនជាងគេក្នុងពិភពលោកបន្ទាប់ពីទ្វីបអាហ្វ្រិក ។ កម្ពុជាជាប្រទេសមួយដែលសម្បូរទៅដោយ វប្បធម៌អរិយធម៌ប្រពៃណី ទំនៀមទម្លាប់ សាសនា សិល្បៈ ក្បូនខ្នាត ក្បូរក្បាច់រចនា ចម្លាក់ ប្រាសាទបុរាណ វត្តុនិងតំបន់បុរាណនានាដែលបានបន្សល់ទុកដោយបុព្វបុរសខ្មែរ។

សព្វថ្ងៃនេះប្រទេសកម្ពុជា ជាប្រទេសដែលកំពុងមានការអភិវឌ្ឍ និងរីកចម្រើនឡើងជាលំដាប់ទៅលើគ្រប់វិស័យមិនថាវិស័យ ទេសចរណ៍ វិស័យធនាគារ វិស័យអចលនទ្រព្យ វិស័យកសិកម្ម វិស័យឧស្សាហកម្មនោះទេ ជាពិសេសវិស័យទេសចរណ៍ជាវិស័យក្បាលម៉ាស៊ីនមួយយ៉ាងសំខាន់ក្នុងការរកចំណូលឱ្យជាតិនិងជំរុញក្នុងការអភិវឌ្ឍរីកចម្រើននូវសេដ្ឋកិច្ចជាតិទាំងមូលតាមរយៈ ការបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋគ្រប់រូបបង្កើនចំណូលជាតិ កាត់បន្ថយភាពក្រីក្រ និងចំណាកស្រុករបស់ប្រជាជនតាមតំបន់ដាច់ស្រយាលលើកកម្ពស់ជីវភាពនិងការរស់នៅរបស់ប្រជាជន ។ នៅតាមតំបន់និងខេត្តនីមួយៗមានការកកើតឡើងជាលំដាប់នូវសណ្ឋាគារម៉ូតែល បឹងហ្គាឡូ ផ្ទះមាត់ទឹក ផ្ទះតង់ តំបន់រមណីយដ្ឋាននានាទាំងច្នៃប្រឌិតប្លែកៗតាមសម័យកាល និងធម្មជាតិបែបប្រវត្តិសាស្ត្រ ក្រុមហ៊ុនទេសចរណ៍ ក្រុមហ៊ុនអាកាសចរ និងសេវាកម្មដឹកជញ្ជូនទាំងផ្លូវទឹក ផ្លូវគោក និងអាកាស រីកចម្រើនទាំងផ្នែកម្ហូបអាហារ ការស្នាក់នៅ ការធ្វើដំណើរ ការបង្កើតនិងច្នៃប្រឌិត ការតាំងពិពណ៌ផលិតផលទេសចរណ៍ សន្និបាទ ការប្រជុំគណៈមន្ត្រីនានា ការធ្វើដំណើរបែបផ្សងព្រេងនិងស្រាវជ្រាវ សុទ្ធសឹងតែជាចំណែកមួយយ៉ាងធំក្នុងវិស័យទេសចរណ៍។

បកមកមើលខេត្តកោះកុងវិញ យើងខ្ញុំក៏សង្កេតឃើញថាខេត្តនេះកំពុងតែមានការរីកចម្រើនឡើងជាខ្លាំងនិងទទួលបានភ្ញៀវទេសចរទាំងជាតិនិងអន្តរជាតិ និងបន្តជម្រុញការអភិវឌ្ឍ អភិរក្សប្រកបដោយប្រសិទ្ធភាពខ្ពស់និងនិរន្តភាពនៅតំបន់ព្រៃត្រូពិច និងតំបន់កោះនានាក្នុងខេត្តកោះកុង ។

ខេត្តកោះកុង (ជា ភាសា អង់គ្លេស Koh Kong province និងមានអក្សរកាត់ KKG) គឺជាខេត្តមួយក្នុងចំណោមខេត្តជាប់ សមុទ្រ ទាំងបួន និងស្ថិតនៅប៉ែកនិរតីបំផុតនៃប្រទេសកម្ពុជា ហើយមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ខាងលិច និងខាងត្បូង ជាប់នឹងឈូងសមុទ្រ និងប្រទេសថៃ និងខាងជើងជាប់ ខេត្តពោធិ៍សាត់ ។ ខេត្ត កោះកុងមាន ក្រុងចំនួន១ និងស្រុកចំនួន ៦ ឃុំចំនួន២៦ និងសង្កាត់ចំនួន៣

ដែលបានបែងចែកជា ១១៩ភូមិ និង មានផ្ទៃដី សរុប ១០,០៤៥.៥៨ គីឡូម៉ែត្រការ៉េ[1]។ ជាមួយនឹង ធនធានធម្មជាតិ និងជីវៈចម្រុះដ៏សំបូរបែប។ ខេត្តកោះកុង មានឆ្នេរសមុទ្រ សរុប ២១៥ គីឡូម៉ែត្រស្មើនឹងជាង ៥០% នៃឆ្នេរសមុទ្ររបស់ប្រទេសកម្ពុជាទាំងមូល។ ប្រជាជនរស់នៅប្រកបរបរនេសាទ ធ្វើស្រែចំការ ដំណាំដាំដុះ និងសម្បូរទៅដោយដងព្រៃក ព្រៃកោងកាងដែលជាដែនជម្រកសត្វស្លាបនិងមច្ឆាជាតិ។ ខេត្តកោះកុងជាខេត្តមួយដែលមានសក្តានុពលទេសចរណ៍បែបធម្មជាតិ និងមានរមណីដ្ឋានទេសចរណ៍នានាអមទៅដោយទេសភាពខៀវស្រងាត់ និងព្រៃភ្នំ ទឹកជ្រោះ ជ្រលងដងអូរ សត្វព្រៃ តំបន់កោះ និងស្ទឹង ជាពិសេសសហគមន៍អេកូទេសចរណ៍ដែលគ្របដណ្តប់ទៅតំបន់សក្តានុពលនានានៅក្នុងសហគមន៍[2] ។

ដោយសង្កេតមើលឃើញថាខេត្តកោះកុងមានសក្តានុពលទេសចរណ៍ជាច្រើនបែបនិងមានការរីកចម្រើនឡើងជាលំដាប់ទទួលបានការគាំទ្រពីភ្ញៀវទេសចរគ្រប់ស្រទាប់ថ្នាក់ទាំងជាតិ និងអន្តរជាតិមកហើយនោះទាំងការគ្រប់គ្រងនៅក្នុងសហគមន៍អេកូទេសចរណ៍មានសភាពល្អប្រសើរនិងជាចំណែកមួយយ៉ាងធំក្នុងវិស័យនេះ ហើយដើម្បីផ្សារភ្ជាប់ពីទ្រឹស្តីនិងការអនុវត្តផ្ទាល់ទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទ « **ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ អារ៉ែង** » ។ ដើម្បីធ្វើការស្រាវជ្រាវវិភាគវែកញែក ប្រកបដោយប្រសិទ្ធភាព និងមានសារៈប្រយោជន៍ទៅដល់ថ្នាក់ដឹកនាំនៅក្នុងសហគមន៍ជាដើម។ ហេតុនេះក្រុមស្រាវជ្រាវយើងខ្ញុំបានអនុវត្តន៍តាមគោលការណ៍វិធីសាស្ត្រនៃការស្រាវជ្រាវដែលមានដំណើរការសកម្មភាពបន្តបន្ទាប់ជាច្រើនទៅតាមដំណាក់កាលខាងក្រោមនេះ ។

## ២. ចំណោទបញ្ហា

អារ៉ែងជាសហគមន៍អេកូទេសចរណ៍មួយដែលពោរពេញទៅដោយសក្តានុពលធនធានធម្មជាតិជាច្រើនប្រភេទ និងជាតំបន់ព្រៃត្រូពិចធំជាងគេនៅក្នុងអាស៊ីអាគ្នេយ៍យើងនេះ។ ដើម្បីភាពងាយស្រួលសម្រួលដល់ប្រធានបទមួយនេះក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំបានចោទជាសំណួរទៅកាន់ថ្នាក់ដឹកនាំរបស់សហគមន៍អេកូទេសចរណ៍ « អារ៉ែង » ដើម្បីធ្វើការសិក្សានិងទទួលយកពត៌មានបន្ថែមនិងច្បាស់លាស់ពីសហគមន៍ទទួលដឹងនូវពត៌មានផ្សេងៗទាក់ទងនិងផ្នែកណាខ្លះដែលមិនទាន់មានការអភិវឌ្ឍនិងមានគម្រោងដើម្បីអភិវឌ្ឍន៍ និងសិក្សាស្វែងយល់បន្ថែមពីការរស់នៅរបស់ប្រជាជនក្នុងសហគមន៍។ តើសហគមន៍អេកូទេសចរណ៍អារ៉ែងមានផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍យ៉ាងដូចម្តេច?

---

[1] http://www.areng-valley.org/ “សហគមន៍អេកូទេសចរណ៍ តំបន់ស្ទឹងអារ៉ែង STUENG ARRENG COMMUNITY-BASED ECOTOURISM” ២០១៨

[2] http://www.areng-valley.org/ “សហគមន៍អេកូទេសចរណ៍ តំបន់ស្ទឹងអារ៉ែង STUENG ARRENG COMMUNITY-BASED ECOTOURISM” ២០១៨

## ៣. គោលបំណង

គោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះគឺដើម្បីឱ្យការសិក្សានេះមានភាពត្រឹមត្រូវច្បាស់លាស់ និងចំគោលដៅ អាចទុកជាព័ត៌មានឯកសារសម្រាប់ស្រាវជ្រាវរបស់អ្នកជំនាន់ក្រោយដែលមានគោលបំណងចង់សិក្សាស្វែងយល់បន្ថែមពីវិស័យទេសចរណ៍ពាក់ព័ន្ធនិងអេកូទេសចរណ៍សហគមន៍អារ៉ែង។ ក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវលើផ្នែកសំខាន់ៗដូចជា៖

- ទិដ្ឋភាពទូទៅរបស់អេកូទេសចរណ៍និងការអភិវឌ្ឍទេសចរណ៍
- យុទ្ធសាស្ត្រនិងផែនការ ការអភិវឌ្ឍនៅក្នុងសហគមន៍អារ៉ែង
- ផ្សព្វផ្សាយ ពន្យល់ណែនាំ កែច្នៃ ថែរក្សា ការពារនិងអភិរក្សតំបន់ព្រៃឈើ និងសត្វព្រៃ
- ផ្សព្វផ្សាយ ពន្យល់លំអិតពីធនធានធម្មជាតិព្រៃឈើ ជីវៈចម្រុះ អេកូឡូស៊ី និងសត្វព្រៃ
- ផលប៉ះពាល់វិជ្ជមាននិងអវិជ្ជមានក្នុងការអភិវឌ្ឍនអេកូទេសចរណ៍និងនិរន្តភាព
- ការគ្រប់គ្រងរបស់សហគមន៍និងការរស់នៅរបស់ប្រជាពលរដ្ឋ

## ៤. សារៈប្រយោជន៍

ការសិក្សាស្រាវជ្រាវចំពោះប្រធានបទនេះនឹងផ្ដល់ប្រយោជន៍ជាច្រើនទៅដល់សហគមន៍នៅក្នុងតំបន់ ចំពោះប្រជាជន ចំពោះខេត្តកោះកុងទាំងមូលនឹងទទួលបានភ្ញៀវទេសចរជាច្រើនអនេក និងជាការរកចំណូលជូនជាតិ។ ជាចំណុចដែលសហគមន៍ត្រូវសិក្សាកែលម្អទទួលយកការយកចិត្តទុកដាក់បន្ថែមផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសទេសរណ៍នានាពីសំណាក់រាជរដ្ឋាភិបាល។ ទទួលបានការវិនិយោគិនល្អៗក្នុងការអភិវឌ្ឍតំបន់អារ៉ែងប្រកបដោយនិរន្តភាពនិងប្រសិទ្ធភាព។ ជាការរួមចំណែកក្នុងការផ្សព្វផ្សាយអប់រំឱ្យទេសចរគ្រប់រូបយល់ដឹងពីសារៈប្រយោជន៍របស់ព្រៃឈើ សត្វព្រៃ ជីវៈចម្រុះ នានាដែលត្រូវការថែរក្សានិងអភិរក្សមិនឱ្យបាត់បង់។

## ៥. ទំហំនិងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះត្រូវបាននិយាយលំអិតច្បាស់លាស់ជាក់ស្ដែងទៅតាមថ្នាក់ដឹកនាំរបស់សហគមន៍អារ៉ែងផ្ទាល់និងបញ្ចូលជាមួយគំនិត ការវិភាគវែកញែកបន្ថែមរបស់ក្រុមយើងខ្ញុំដោយតាមរយៈការសិក្សាស្រាវជ្រាវនិងប្រមូលទិន្នន័យបន្ថែមពិសាស្ត្រាចារ្យណែនាំ ការបំពេញកម្រងសំណួរផ្ទាល់ជាមួយប្រជាជនគ្រប់ស្រទាប់ថ្នាក់ជាមួយប្រធានសហគមន៍អារ៉ែង ប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង ជនជាតិភាគតិចដែលរស់នៅនិងប្រកបមុខរបរសេវាកម្មទេសចរណ៍នេះផ្ទាល់ និងប្រជាជនដែលរស់នៅក្នុងសហគមន៍។

## ៦. វិធីសាស្ត្រ

### ក ប្រភពទិន្នន័យ

ទិន្នន័យដែលបានយកមកស្រាវជ្រាវនេះគឺបានដកស្រង់ចេញពីការិយាល័យរដ្ឋបាលនៅក្នុងសហគមន៍អារ៉ែង មន្ទីរទេសចរណ៍ខេត្តកោះកុង មន្ទីរទេសចរណ៍ក្រុងភ្នំពេញ បណ្ណាល័យសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ប្រព័ន្ធអ៊ីនធើណែត។

### ខ ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវនេះផងដែរ យើងខ្ញុំធ្វើការប្រមូលទិន្នន័យតាមរយៈការសម្ភាសន៍ផ្ទាល់មាត់ជាមួយ និងប្រធានមន្ទីរទេសចរណ៍ ខេត្តកោះកុង ប្រធានសហគមន៍អេកូទេសចរណ៍អារ៉ែង និងឯកសារនានាដែលយើងខ្ញុំទទួលបានពីសាស្ត្រាចារ្យណែនាំនិងការសួរផ្ទាល់មាត់ពីប្រជាជនដែលរស់នៅក្នុងតំបន់សហគមន៍ដោយផ្ទាល់។

### គ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យគឺពួកយើងធ្វើឡើងដោយផ្អែកលើភស្តុតាងសំណៅឯកសារដែលភាគីពាក់ព័ន្ធបានផ្តល់ឱ្យនិងទៅតាមស្ថានភាពជាក់ស្តែងទៅតាមអ្នកដែលបានដឹងពត៌មានផ្សេងៗពាក់ព័ន្ធនិងតំបន់សហគមន៍អារ៉ែង។

## ៧. រចនាសម្ព័ន្ធ

សារណានេះមានរចនាសម្ព័ន្ធដូចខាងក្រោម៖

សេចក្តីផ្តើម៖ និយាយបង្ហាញឱ្យស្គាល់ពីប្រធានបទ ចំណោទបញ្ហានៃប្រធានបទ គោលបំណងនៃការជ្រើសរើសយកប្រធានបទ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវលើប្រធានបទ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទនេះ ។

**ជំពូកទី១ ៖ រំលឹកទ្រឹស្តី**

**ជំពូកទី២ ៖ សហគមន៍អេកូទេសចរណ៍អារ៉ែង និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ**

**ជំពូកទី៣ ៖ ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍផលិតផលសហគមន៍អារ៉ែង**

# ជំពូកទី១
# រំលឹកទ្រឹស្តី

មុននឹងចូលដល់ការនិយាយបកស្រាយលំអិតស៊ីជម្រៅជាមួយនិងប្រធានបទពួកយើង យើងខ្ញុំសូមនិយាយពាក់ព័ន្ធនិងការរំលឹកទ្រឹស្តីខ្លះៗដែលជាប្រទីបនាំអ្នកទាំងអស់គ្នាឱ្យបានយល់ពីអេកូទេសចរណ៍អ្នកទាំងអស់គ្នានឹងបានស្វែងយល់អ្វីទៅហៅថា៖

- អ្វីទៅហៅថាអេកូទេសចរណ៍?
- ដូចម្តេចដែលហៅថាសហគមន៍អេកូទេសចរណ៍?
- ដូចម្តេចដែលហៅថាតំបន់ការពារ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ?
- គុណសម្បត្តិនិងគុណវិបត្តិនៃអេកូទេសចរណ៍

## ១.១ ទេសចរណ៍

វិស័យទេសចរណ៍ គឺជាការធ្វើដំណើរកម្សាន្តរបស់អ្នកដែលមិនមែនជាម្ចាស់ស្រុកមានរយៈពេលខ្លីនិងជាបណ្តោះអាសន្ន ដែលធ្វើដំណើរទៅតំបន់គោលដៅហើយត្រឡប់មកវិញ។ វិស័យទេសចរណ៍រួមមាន ការស្នាក់នៅ អាហារភេសជ្ជៈ ភាពទាក់ទាញ ការដឹកជញ្ជូន ព័ត៌មាន និង សេវាកម្មផ្សេងៗទៀត។ សម្បទា និងសេវាកម្មទាំងនេះបំរើឱ្យផ្សេងៗគ្នា ដែលក្រៅពីទេសចរណ៍ ។ ភាពខុសគ្នារវាងភ្ញៀវទេសចរ និងទេសចរណ៍គឺភ្ញៀវទេសចរសំដៅដល់បុគ្គលទាំងឡាយណាដែលធ្វីដំណើរចាកចេញពីលំនៅអចិន្ត្រៃយ៍ឆ្ពោះទៅកាន់កន្លែងណាមួយដោយស្នាក់នៅទីនោះលើសពីរយៈពេល២៤ម៉ោង ដោយគិតទៅលើរយៈពេលដែលភ្ញៀវស្នាក់នៅពីពេលដែលគេចូលមកក្នុងប្រទេស រហូតដល់ពេលដែលគេចាកចេញទៅវិញ[3] រីឯទេសចរណ៍គឺជាឧស្សាហកម្ម និងពាណិជ្ជកម្មទាំងមូល។ បច្ចុប្បន្នមានប្រទេសជាច្រើននៅលើពិភពលោកបានចាប់ទុកវិស័យទេសចរណ៍ គឺជាកម្លាំងចលករដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចព្រោះវាអាចបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលលើកកម្ពស់ជីវភាពរស់នៅជំរុញកំណើនផលិតផលក្នុងស្រុក រក្សាលំនឹងពាណិជ្ជកម្ម និងជួយកាត់បន្ថយភាពក្រីក្រ ជាពិសេសវិស័យនេះក៏បាននាំមកនូវកិត្យានុភាពប្រទេសជាតិ ជួយថែរក្សាមរតកវប្បធម៌ ប្រពៃណីវប្បធម៌សង្គម និងបូរណៈភាពទឹកដី ព្រមទាំងជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសង្គម[4] ។ ក្នុងមួយឆ្នាំៗវិស័យទេសចរណ៍បាននាំមកនូវចំណូលរូបិយប័ណ្ណអន្តរជាតិរាប់ពាន់លានដុល្លារសហរដ្ឋអាមេរិច ចាប់ចូលក្នុងចរន្តសេដ្ឋកិច្ចរបស់ប្រទេសមួយចំនួន រួមទាំងកម្ពុជាផងដែរ។ វឌ្ឍភាពសេដ្ឋកិច្ចនៃឧស្សាហកម្មទេសចរណ៍ពេលបច្ចុប្បន្នបានចូលរួមបង្កើតឱកាសការងារដល់ប្រជាពលរដ្ឋស្មើ ១១% នៃការងារសរុប និងអាចដោះស្រាយវិបត្តិសេដ្ឋកិច្ចសង្គមបានយ៉ាងមានប្រសិទ្ធភាព។ ជាក់ស្តែងក្នុងឆ្នាំ ២០០៨ ទោះជាពិភពលោកមានវិបត្តិយ៉ាងណាក៏ដោយក៏វិស័យទេសចរណ៍ត្រូវបានគេមើលឃើញថានៅរក្សាប្រភព

[3] បណ្ឌិតសួនវ៉ានី ទ្រឹស្តីនិងទស្សនៈមូលដ្ឋាន២០០៦

[4] សៀវភៅផែនការអភិវឌ្ឍន៍ទេសចរណ៍របស់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

ចំណូលទូរបិយប័ណ្ណបរទេសមួយក្នុងចំណោមប្រភេទរូបិយប័ណ្ណបរទេសធំៗទាំងប្រាំរបស់ប្រទេសកំពុងអភិវឌ្ឍន៍គឺប្រមាណជាង ៨៣% និងបានផ្តល់ឱកាសការងារប្រមាណ ២៣០លាននាក់ ឬស្មើនឹងចំនួន ១១%នៃកម្លាំងការងារសរុប[5]។

ទេសចរណ៍មានន័យទូលំទូលាយខ្លាំងណាស់ហើយនិយមន័យរបស់វាបានត្រូវបានជួបប្រទេសផ្សេងៗគ្នាជាច្រើនក្នុងប្រភេទឯកសារ។ Tourism ខ្មែរថា "ទេសចរណ៍" មានន័យជា សកម្មភាពនៃមនុស្សដែលធ្វើដំណើរ និងស្នាក់នៅកន្លែងណាមួយដែលមិនមែនកន្លែងដែលគេរស់នៅជាប្រក្រតី និងស្នាក់នៅទីនោះមិនលើសពីមួយឆ្នាំ ដើម្បីសម្រាក កម្សាន្ត និងក្នុងគោលបំណងផ្សេងៗទៀត[6]។ មានការកំណត់ផ្សេងៗទៀតថា ទេសចរណ៍ជាការធ្វើដំណើរ ឬជាប្រភេទចលនារបស់ពលរដ្ឋដែលមិនទាក់ទងនិងការផ្លាស់ប្តូរទីកន្លែងរស់នៅ និងការងារគឺបានន័យថាធ្វើដំណើរក្នុងបំណងសម្រាកលំហែកាយអារម្មណ៍។ ទាំងនេះបង្ហាញឱ្យឃើញថាទេសចរណ៍កើតចេញពីការធ្វើដំណើរហើយការធ្វើរដំណើរនេះបាននាំឱ្យមានការកកើតឡើងនូវសកម្មភាពថ្មីមួយទៀតគឺទីស្នាក់នៅទទួលទានអាហារ និងសម្រាកលំហែកាយ។ ការធ្វើដំណើរទេសចរណ៍ និងបដិសណ្ឋាកិច្ចជានិយមន័យដែលមានទំនាក់ទំនងគ្នាដោយមិនអាចបំបែកចេញពីគ្នាបាន និងនៅក្នុងជីវិតរស់នៅក្នុងសង្គមមហាជនគ្រប់រូបតែងតែទាមទារ និងចង់បានដោយខានមិនបានក្នុងការធ្វើដំណើរជាចលនារបស់ប្រជាពលរដ្ឋក្នុងកំឡុងពេលណាមួយនារយៈកាលណាមួយក្នុងតំបន់ណាមួយ។ រីឯអ្នកធ្វើចលនានេះដោយមិនគិតពីគោលបំណងទិសដៅ និងមធ្យាបាយធ្វើដំណើររយៈពេលខ្លីឬវែងនោះត្រូវបានគេហៅថាអ្នកធ្វើដំណើរដោយសមស្របទៅតាមលក្ខណៈពិសេសៗ នៃការធ្វើដំណើរគេកំណត់ថាជាអ្នកឆ្លងកាត់ ឬធ្វើដំណើរតាមសមុទ្រ ហោះហើរ អាជីវករ អ្នកវិទ្យាសាស្ត្រ។ ក្នុងលក្ខខណ្ឌនៃការរៀបចំធ្វើដំណើរ អ្នកដំណើរអាចប្រើប្រាស់សេវាកម្មផ្សេងៗ ដែលផ្តល់ដោយអង្គការ ឬក្រុមហ៊ុនឧស្សាហកម្មទេសចរណ៍។ អ្នកដំណើរក្នុងគោលបំណងណាមួយបានត្រូវគេហៅថា Visitor ។ យោងតាមកត្តាផ្សេងៗនៃសេដ្ឋកិច្ច អ្នកដំណើរប្រភេទនេះត្រូវបានបែងចែកជាអ្នកដែលបានស្នាក់នៅយ៉ាងហោចណាស់មួយយប់ ឬមួយពេលក្នុងតំបន់ដែលគេមកដល់ និងអ្នកមកដល់ដែលមានពេលតិចជាង ២៤ម៉ោង។ ការកើតឡើងនៃការធ្វើដំណើរ មិនអាចត្រូវគេកំណត់ច្បាស់លាស់នោះទេ។

## ១.២ និយមន័យពាក់ព័ន្ធទេសចរណ៍

### ១.២.១ អ្វីទៅជាទេសចរ

ទេសចរជាអ្នកដែលបានស្នាក់នៅយប់ក្រៅពីកន្លែងរស់នៅរបស់ខ្លួនតែមិនលើសរយៈពេល ៣៦៥ថ្ងៃ។ អ្នកមកដល់ហើយស្នាក់នៅលើសពី ៣៦៥ថ្ងៃជាបន្តបន្ទាប់មិនត្រូវបានចាត់ទុកថាជាទេសចរទេ។ តាមកត្តាផ្សេងៗរយៈពេលធ្វើដំណើរជាទេសចរណ៍ត្រូវបានបែងចែកដូចខាងក្រោមៈ

[5] របាយការណ៍របស់អង្គការទេសចរណ៍ពិភពលោក

[6] Pearson, Int'n to Hospitality and Tourism Management, 2013

- ការធ្វើដំណើរនៅថ្ងៃទំនេរ Weekend Holiday ត្រូវស្ថិតក្នុងរយៈពេលពី១-៣ថ្ងៃ។ ចរិកលក្ខណៈនៃដំណើរនេះបង្ហាញអំពីកម្រិតចំណាយតិចបំផុតលើការធ្វើដំណើរហើយពិសេសគឺសំដៅទៅតំបន់លំហែកាយអារម្មណ៍មជ្ឈមណ្ឌលវប្បធម៌ និងរមណីយដ្ឋានទេសចរណ៍។

- ដំណើរក្នុងរយៈពេល ៥-៧ថ្ងៃ ត្រូវបានរីកដុះដាលនិងទទួលបានការពេញនិយមយ៉ាងខ្លាំងនៅក្នុងពិភពលោកទាំងសម្រាប់ទេសចរណ៍ដោយផ្ទាល់ និងទាំងសម្រាប់អ្នកប្រតិបត្តិការងារអាជីវកម្មទេសចរណ៍។

- ដំណើរក្នុងរយៈពេល ៨-១២ថ្ងៃសម្រាប់ប្រភេទណាមួយនៃទេសចរណ៍។ ដំណើរក្នុងរយៈពេលនេះត្រូវបានបន្ថយតម្លៃយ៉ាងច្រើន។ ចំណាយតិចសម្រាប់ការធ្វើដំណើរទៅតំបន់ដាច់ស្រយាលណាមួយ ក្នុងរយៈពេលពីរអាទិត្យជាងការធ្វើដំណើរពីរដង ដែលម្តងមានរយៈពេលមួយសប្តាហ៍។

- ដំណើរក្នុងរយៈយូរអង្វែងលើសពីពីរសប្តាហ៍ (មិនលើសពី ៣៦៥ ថ្ងៃ)។ ការធ្វើដំណើររបៀបនេះមានតិចនៅឡើយទេថ្មីៗនេះនៅក្នុងពិភពលោកមានការស្នើឡើងថាបើសិនជាបានទិញបន្ទប់សណ្ឋាគារសម្រាប់ស្នាក់នៅដល់ទៅពីរសប្តាហ៍នោះ នៅសប្តាហ៍ទីបីនេះ នឹងផ្តល់បន្ទប់ដោយមិនគិតថ្លៃ។ ការធ្វើដំណើររបៀបនេះ ភាគច្រើនធ្វើឡើងទៅតាមប្រភេទទេសចរណ៍ពិសេសៗដូចជា Crossing Tour, Adventure Tour ជាដើម។[7]

### ១.២.២ អ្នកណាជាទេសចរ

នៅក្នុងវិស័យទេសចរណ៍អ្នកដែលទទួលសេវាកម្មមានតែមួយគឺទេសចរ។ ទេសចរជាអ្នកទទួល និងប្រើប្រាស់នូវផលិតផលទេសចរណ៍។ កម្មវិធីដំណើរកម្សាន្ត ខ្សែទស្សនកិច្ច សេវាកម្ម ឬទំនិញ និងត្រូវបានកំណត់ថាជាកម្មវត្ថុចម្បងនៃសកម្មភាពការងាររបស់ក្រុមហ៊ុន និងទីភ្នាក់ងារទេសចរណ៍។ខុសគ្នាពីទីផ្សារទំនិញនិងផ្សារហិរញ្ញវត្ថុដែលផលិតផលជាអ្នកស្វែងរកអតិថិជននៅក្នុងវិស័យទេសចរណ៍ អ្នកប្រើប្រាស់ផលិតផលនេះ (អតិថិជន ឬអ្នកទិញ) ស្វែងរកផលិតផលទេសចរណ៍ និងសេវាកម្មទេសចរណ៍ដោយខ្លួនឯង។ នេះជាលក្ខណៈពិសេសរបស់ទេសចរដែលជាអ្នកប្រើប្រាស់ផលិតផល និងសេវាកម្មទេសចរណ៍។ អ្នកប្រើប្រាស់ផលិតផល និងទទួលសេវាកម្មទេសចរណ៍គ្មានសិទ្ធិអាចសាកល្បង ឬស្គាល់ពីគុណភាពនៃសំណើមកគេនូវទស្សនកិច្ចកម្មវិធីដំណើរសេវាកម្មនិងទំនិញជាមុនទេ។ ផលិតផលទេសចរណ៍ ត្រូវបានគេផ្តល់ ឬវាយតម្លៃក្នុងរយៈពេលនៃការប្រតិបត្តិ និងដំណើរការទទួលសេវានេះពីសំណាក់ទេសចរប៉ុណ្ណោះ[8]។

## ១.៣ អេកូទេសចរណ៍

អេកូទេសចរណ៍ត្រូវបានកំណត់យ៉ាងទូលំទូលាយថាជាការធ្វើដំណើរដែលមានឥទ្ធិពលតិចតួចទៅទីតាំងដែលជិតផុតពូជនិងមិនមានបញ្ហា។ វាខុសគ្នាពីទេសចរណ៍ប្រពៃណីពីព្រោះវាអនុញ្ញាតឱ្យអ្នកដំណើរទៅ

[7] http://thecbca.weebly.com/uploads/2/4/5/8/24584341/chapter_2_general_structure_of_tourism.pdf "ជំពូកទី២ រចនាសម្ព័ន្ធទូទៅ របស់សហគមន៍ " ទំព័រ ២៩

[8] http://thecbca.weebly.com/uploads/2/4/5/8/24584341/chapter_2_general_structure_of_tourism.pdf "ជំពូកទី២ រចនាសម្ព័ន្ធទូទៅ របស់សហគមន៍ " ទំព័រ ២៦

ជាអ្នកមានចំណេះដឹងអំពីតំបន់ទាំងផ្នែកទេសភាពនិងលក្ខណៈវប្បធម៌ហើយជាញឹកញាប់ផ្តល់មូលនិធិសម្រាប់ការអភិរក្សនិងផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៃទីកន្លែងដែលក្រីក្រជាញឹកញាប់។

អេកូទេសចរណ៍ Eco-tourism សព្វថ្ងៃនេះត្រូវបានចាត់ទុកថាជាវិស័យគន្លឹះមួយ ដែលជួយទ្រទ្រង់ ថែរក្សា និងគាំពារផងព្រមទាំង ជួយបង្កើតបង្កើនសកម្មភាពសេដ្ឋកិច្ចក្នុងតំបន់ធម្មជាតិក្នុងទូទាំងពិភពលោកផង។ អេកូទេសចរណ៍ ផ្តល់ឱកាសជាច្រើនដល់អ្នកទស្សនាដើម្បីដកស្រង់ ប្រមូលបទពិសោធពីធនធានធម្មជាតិពីសារៈសំខាន់នៃការអភិរក្សជីវៈចម្រុះ។ និងពីវប្បធម៌តំបន់អភិវឌ្ឍន៍។ តាមរយៈសកម្មភាពទាំងនេះអេកូទេសចរណ៍បានបង្កើតប្រាក់ចំណូលសម្រាប់អភិរក្ស ធានា រក្សាភាពដើមនៃធនធានធម្មជាតិ និងវប្បធម៌តំបន់ និងផ្តល់ប្រយោជន៍សេដ្ឋកិច្ចយ៉ាងច្រើន ដល់សហគមន៍ (ក្រុមមនុស្ស) ក្នុងតំបន់ធម្មជាតិ ដែលវិស័យនេះបានត្រូវអភិវឌ្ឍន៍។

### ១.៣.១ អ្វីទៅជាអេកូទេសចរណ៍?

ពាក្យអេកូទេសចរណ៍ Eco-tourism ត្រូវបានបង្កើតឡើងដោយពាក្យពីរ គឺ Eco និង Tourism។ Eco ជាអក្សរកាត់ដែលបានមកពីពាក្យ Ecology (អេកូឡូស៊ី) ប្រែជាភាសាខ្មែរថា "បរិស្ថានវិទ្យា" មានន័យថាជាទំនាក់ទំនងទៅវិញទៅមករវាងរុក្ខជាតិសត្វលោកនានា និងស្ថានប្រព័ន្ធដែលពួកគេរស់នៅ។ តាមវចនានុក្រម Merriam-webster Dictionary ពាក្យអេកូឡូស៊ីត្រូវបានពន្យល់ថាមានន័យ ៤យ៉ាង គឺ ទី១គឺជាមែកធាងនៃវិទ្យាសាស្ត្រដែលមានការទាក់រវាងភាវៈរស់ទាំងឡាយ និងបរិស្ថានដែលពួកវារស់នៅ ទី២ គឺជាចំនួនសរុប ឬបែបបទនៃទំនាក់ទំនងនានារវាងភាវៈរស់ទាំងឡាយ និងបរិស្ថានដែលពួកវារស់នៅ ទី៣ គឺជាអេកូឡូស៊ីមនុស្ស មានន័យថាមែកធាងនៃសង្គមវិទ្យាពិសេសទំនាក់ទំនងរវាងមនុស្សទាំងឡាយនិងសេដ្ឋកិច្ចសង្គមនិងបរិយាកាសនយោបាយ[9] និង ទី៤ គឺជាការសិក្សាពីស្ថានប្រព័ន្ធទាំងឡាយដែលមានលក្ខណៈស្មុគ្រស្មាញ[10]។

Tourism ខ្មែរថា "ទេសចរណ៍" មានន័យថាសកម្មភាពនៃមនុស្សដែលធ្វើដំណើរ និងស្នាក់នៅកន្លែងណាមួយដែលមិនមែនកន្លែងដែលគេរស់នៅជាប្រក្រតី និងស្នាក់នៅទីនោះមិនលើសពីមួយឆ្នាំដើម្បីសម្រាកកម្សាន្ត និងក្នុងគោលបំណងផ្សេងៗទៀត។ តាមច្បាប់ស្តីពីទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា "ទេសចរណ៍" ត្រូវបានសំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរទៅនិងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេសម្រាប់រយៈពេលកំណត់មួយដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នាដើម្បីសម្រាកកម្សាន្តធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

តាមន័យបានសិក្សាខាងលើបញ្ញត្តិស្តីពី អេកូទេសចរណ៍ គឺជាទស្សនាទានថ្មីមួយ ដែលនៅមានការយល់ច្រឡំច្រើន និងមានការប្រើប្រាស់ខុសជាច្រើនមកហើយ។ អេកូទេសចរណ៍ដោយការយល់ច្រឡំត្រូវបានប្រើប្រាស់

[9] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈនិង បណ្ឌិត ឈឹមផាន់ណា, ទំព័រ៣

[10] www.merriam-webster.com/dictionary

ដើម្បីទាក់ទាញអ្នកធ្វើដំណើរឱ្យទៅកាន់តំបន់មួយដែលមានការថែរក្សា និងការពារធម្មជាតិមិនមែនដើម្បីគោលបំណងរីករាយសប្បាយជាមួយធម្មជាតិតែការគាំពារ ការពារបរិស្ថានធម្មជាតិ គឺជាអាទិភាព។ បែបនេះបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងវប្បធម៌តំបន់ផង [11]។

តាមលោក Fennel ឆ្នាំ១៩៩៩ អេកូទេសចរណ៍ ត្រូវបានកំណត់លើកដំបូងដោយ Park Canada ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយប្រទេសកាណាដាបានទទួលតួនាទីជាអ្នកគ្រប់គ្រងទាំងផ្នែកអេកូទេសចរណ៍ និងផ្នែកទេសចរណ៍វប្បធម៌[12]។ ជាបន្តបន្ទាប់និយមន័យ អេកូទេសចរណ៍ត្រូវបានគេអភិវឌ្ឍន៍ និងនិយមន័យជាច្រើនត្រូវបានគេផ្តល់ឱ្យ ឧទាហរណ៍៖

អេកូទេសចរណ៍ គឺជាដំណើរកម្សាន្តមានទំនួលខុសត្រូវទៅតំបន់ធម្មជាតិនានាដែលមានកិច្ចអភិរក្សបរិស្ថាន និងធ្វើឱ្យសុខុមាលភាពសហគមន៍មូលដ្ឋានប្រសើរឡើង[13]។

អេកូទេសចរណ៍ គឺជាទេសចរណ៍អាស្រ័យធម្មជាតិដែលមានការទាក់ទងជាមួយនឹងការអប់រំការបកស្រាយអំពីបរិស្ថានធម្មជាតិ និងការរៀបចំគ្រប់គ្រងប្រកបដោយចីរភាព[14] ។

អេកូទេសចរណ៍ គឺជាដំណើរកម្សាន្តដែលមានទំនួលខុសត្រូវ និងជំរុញការអភិរក្សធម្មជាតិ និងធ្វើយ៉ាងណាឱ្យមាននិរន្តរភាពនូវការរស់នៅជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន[15]។

អេកូទេសចរណ៍ គឺជាដំណើរកម្សាន្តដែលមានការទំនួលខុសត្រូវលើបរិស្ថានហើយការកម្សាន្តនោះមិនបានធ្វើឱ្យមានការប៉ះពាល់អវិជ្ជមានដល់ធម្មជាតិ ពោលគឺជាដំណើរកម្សាន្តក្នុងគោលបំណងសប្បាយរីករាយ និងឱ្យតម្លៃលើធម្មជាតិព្រមទាំងជំរុញការអភិរក្សនិងការប៉ះពាល់អវិជ្ជមានឱ្យកាន់តែតិច និងផ្តល់ឱ្យប្រជាពលរដ្ឋទទួលប្រយោជន៍សេដ្ឋកិច្ចពីធម្មជាតិនោះ[16]។

អេកូទេសចរណ៍ គឺជាដំណើរដែលមានការទទួលខុសត្រូវលើបរិស្ថាន និងទស្សនកិច្ចទៅតំបន់ធម្មជាតិដើម្បីកម្សាន្ត និងទស្សនាធម្មជាតិព្រមទាំងលក្ខណៈពិសេសរបស់វប្បធម៌ដែលនៅជាប់ជាមួយទាំងអតីតកាល និងបច្ចុប្បន្នជំរុញឱ្យមានការអភិរក្សគ្មានផលប៉ះពាល់ដោយចំនួនទេសចរ និងផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន[17]។

---

[11] ក្រសួងទេសចរណ៍ "ច្បាប់ស្តីពី ភ្នំពេញ" ,២០០៩

[12] Stan MCGAHEY, The Ethics, Obligations, and Stake Holders of Ecotourism Marketing, United States, 2012, No. 2(14),p.1

[13] The International Ecotourism Society, 1990

[14] The International Ecotourism Strategy 1994, p.17

[15] www.conversation.org/xp/CIWEB/programs/ecotourism.xml

[16] IUCN, 1996

[17] វ៉ា ស៊ីហេង ស៊ុំ សុចិន្តា និងហុង វណ្ណៈ, អេកូទេសចរណ៍, ភ្នំពេញ ២០០៦

តាមច្បាប់ស្តីពីទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា អេកូទេសចរណ៍ត្រូវបានសំដៅដល់ទម្រង់ទេសចរណ៍ផ្អែកលើធម្មជាតិដែលមានគោលបំណងអភិរក្សបរិស្ថានធម្មជាតិនិងវប្បធម៌តំបន់ ជួយលើកកម្ពស់ជីវភាពរស់នៅសុខុមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានផ្តល់បទពិសោធល្អដល់ទេសចរ និងការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ និងកម្សាន្តកោតសរសើររៀនសូត្រពីធម្មជាតិ [18]។

អេកូទេសចរណ៍ គឺជាការធ្វើដំណើរទៅតំបន់ការពារធម្មជាតិ (តំបន់ដែលមានលក្ខណៈដើមនៃធម្មជាតិទាំងស្រុង) ដែលជាទូទៅជាតំបន់ដែលមានការការពារ។ ការធ្វើដំណើរនោះត្រូវធានាមិនមានការប៉ះពាល់ ត្រូវអប់រំដល់អ្នកធ្វើដំណើរឱ្យផ្តល់ថវិកាក្នុងការអភិរក្សផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងផ្តល់អំណាចផ្នែកនយោបាយដល់សហគមន៍មូលដ្ឋានព្រមទាំងជំរុញឱ្យមានការគោរពវប្បធម៌ និងគោរពសិទ្ធិមនុស្សក្នុងតំបន់ផងដែរ ។ ជាមួយគ្នានេះអេកូទេសចរណ៍មានកាតព្វកិច្ចការពារតំបន់ធម្មជាតិដើម្បីបម្រើដល់ការទស្សនាទស្សនីយភាពធម្មជាតិ និងវប្បធម៌សង្គមផ្តល់ការអប់រំស្តីអំពីប្រយោជន៍នៃធនធានទាំងឡាយនៅក្នុងសហគមន៍ ចូលរួមអភិរក្សហើយក្នុងនោះក៏គិតពីផលប្រយោជន៍របស់សហគមន៍ផងដែរ ។

### ១.៣.២ ប្រវត្តិអេកូទេសចរណ៍

អេកូទេសចរណ៍និងទម្រង់នៃការធ្វើដំណើរប្រកបដោយនិរន្តរភាពមានប្រភពដើមរបស់ពួកគេជាមួយចលនាបរិស្ថាននៃទសវត្សរ៍ឆ្នាំ១៩៧០។ អេកូទេសចរណ៍ខ្លួនឯងមិនបានក្លាយជាទំនៀមទម្លាប់ជាគំនិតទេសចរណ៍រហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៨០។ ក្នុងអំឡុងពេលនោះការបង្កើនការយល់ដឹងពីបរិស្ថាននិងបំណងប្រាថ្នាក្នុងការធ្វើដំណើរទៅកន្លែងធម្មជាតិផ្ទុយពីការបង្កើតទីតាំងទេសចរណ៍ធ្វើឱ្យអេកូទេសចរណ៍មានភាពល្អប្រសើរ។ ចាប់តាំងពីពេលនោះមកអង្គការផ្សេងៗ ទៀតដែលមានឯកទេសខាងអេកូទេសចរណ៍បានបង្កើតនិងមនុស្សផ្សេងគ្នាជាច្រើនបានក្លាយជាអ្នកជំនាញលើបញ្ហានេះ។ Martha D.Honey, បណ្ឌិតជាសហស្ថាបនិកនៃមជ្ឈមណ្ឌលសម្រាប់ការទទួលខុសត្រូវលើវិស័យទេសចរណ៍គឺជាឧទាហរណ៍មួយក្នុងចំណោមអ្នកជំនាញអេកូទេសចរណ៍ជាច្រើន[19]។

### ១.៣.៣ គោលការណ៍សំខាន់ៗអេកូទេសចរណ៍

ដោយសារតែប្រជាប្រិយភាពកាន់តែរីកលូតលាស់នៃការធ្វើដំណើរទាក់ទងនឹងបរិស្ថាននិងការធ្វើដំណើរផ្សងព្រេងប្រភេទផ្សេងៗ នៃការធ្វើដំណើរបច្ចុប្បន្នត្រូវបានចាត់ថ្នាក់ជាអេកូទេសចរណ៍។ ភាគច្រើននៃបរិស្ថានទាំងនេះមិនមានអេកូទេសចរណ៍ពិតៗ ទេពីព្រោះពួកគេមិនសង្កត់ធ្ងន់លើការអភិរក្សការអប់រំការធ្វើដំណើរមានឥទ្ធិពលទាបនិងការចូលរួមពីវប្បធម៌និងសង្គមនៅក្នុងទីតាំងដែលត្រូវបានទៅទស្សនា។ ហេតុដូច្នេះហើយត្រូវចាត់ទុកថាអេកូទេសចរណ៍ត្រូវតែបំពេញតាមគោលការណ៍ដូចខាងក្រោមដែលកំណត់ដោយសមាគមន៍អេកូទេសចរណ៍អន្តរជាតិ: កាត់បន្ថយផលប៉ះពាល់នៃការមកទស្សនាទីតាំង (កាត់បន្ថយការប្រើប្រាស់ផ្លូវថ្នល់),

---

[18] ច្បាប់ស្តីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ២០០៩

[19] https://km.eferrit.com/ "សេចក្តីណែនាំអំពីអេកូទេសចរណ៍"

កសាងការគោរពនិងការយល់ដឹងអំពីបរិស្ថាននិងការអនុវត្តវប្បធម៌, ធានាថាទេសចរណ៍ផ្តល់នូវបទពិសោធន៍វិជ្ជមានទាំងភ្ញៀវនិងភ្ញៀវ, ផ្តល់ជំនួយហិរញ្ញវត្ថុដោយផ្ទាល់សម្រាប់ការអភិរក្ស, ផ្តល់ជំនួយហិរញ្ញវត្ថុការផ្តល់សិទ្ធិអំណាចនិងអត្ថប្រយោជន៍ផ្សេងៗដល់ប្រជាពលរដ្ឋក្នុងតំបន់ និងបង្កើនការយល់ដឹងរបស់អ្នកដំណើរអំពីបរិយាកាសនយោបាយបរិស្ថាននិងសង្គមនៃប្រទេសម្ចាស់ផ្ទះ[20]។

**១.៣.៤ ឥទ្ធិពលនានានៃអេកូទេសចរណ៍**

ឥទ្ធិពលទៅលើសេដ្ឋកិច្ច អេកូទេសចរណ៍មានឥទ្ធិពលទៅលើសេដ្ឋកិច្ចតំបន់អភិវឌ្ឍន៍។ ការលក់សត្វព្រៃឈើហ៊ុប។ល។ ពីមុនគឺជាមធ្យោបាយមួយគាប់ប្រសើរដែលនាំមកនូវប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់។ តម្រូវការចំពោះផលិតផលទាំងនេះកើនឡើងឥតឈប់ឈរពូជសត្វកម្រ និងប្រភេទឈើប្រណិតល្អក៏ចេះតែបាត់បង់ខ្លាំងឡើងៗ និងគ្រោះថ្នាក់ជាងនេះទៅទៀតគឺមានសត្វខ្លះកំពុងតែប្រឈមមុខទៅនឹងការផុតពូជ។

អេកូទេសចរណ៍ មានសារៈសំខាន់បំផុតក្នុងការស្វែងរកដំណោះស្រាយដើម្បីរារាំងសកម្មភាពទាំងអស់នេះ[21]។ ជាក់ស្តែង គម្រោងអភិរក្សសត្វស្វាភ្នំដែលធំជាងគេនៅអាហ្វ្រិក (Mountain Gorilla Project) បានចាប់ផ្តើមឡើងដោយមានអ្នកទស្សនាមិនដល់ ៥០នាក់ហើយប្រាក់ចំណូលទទួលបានគឺមិនដល់ ២ពាន់ដុល្លារផងស្រាប់តែរយៈពេល ១០ឆ្នាំក្រោយមកមានភ្ញៀវជាមធ្យម៥០០០នាក់ជាប្រចាំឆ្នាំបានទៅឧទ្យានដើម្បីទស្សនាស្វាហ្គ័រវីឡា។ ទេសចរបានចំណាយប្រាក់ជិត ២០០ដុល្លារក្នុងម្នាក់ៗ ដូច្នេះ ឧទ្យាននេះអាចរកចំណូលជាប្រចាំឆ្នាំបានជិត ១លានដុល្លារ។ មានការប៉ាន់ស្មានថាទេសចរនឹងចំណាយប្រាក់ ៦០០ដុល្លារនាឆ្នាំខាងមុខនៅពេលដែលសេវាកម្មមួយចំនួនត្រូវបានពង្រីក និងពង្រឹងហើយនាំចំណូលរហូតដល់ ៣លានដុល្លារក្នុងមួយឆ្នាំ[22]។

**១.៣.៥ គុណសម្បត្តិនិងគុណវិបត្តិនៃអេកូទេសចរណ៍**

អេកូទេសចរណ៍គឺជាទេសចរណ៍មួយប្រភេទដោយអាស្រ័យទៅលើធម្មជាតិនិងវប្បធម៌ប្រចាំតំបន់ភ្ជាប់ជាមួយការអប់រំបរិស្ថានដែលកំពុងក្លាយជាជម្រើសដ៏ពេញនិយមសម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។ អេកូទេសចរណ៍បានផ្តល់សារៈប្រយោជន៍យ៉ាងច្រើនទៅកាន់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដូចជាការផ្តល់នូវការងារដើម្បីកាត់បន្ថយនៃភាពក្រីក្រ។ លើសពីនេះទៅទៀតអេកូទេសចរណ៍ក៏បានផ្តល់សារៈប្រយោជន៍ជូនភ្ញៀវទេសចរផងដែលតាមរយៈផ្តល់ចំណេះដឹង និងភាពសប្បាយរីករាយ។ អេកូទេសចរណ៍មានគុណសម្បត្តិដូចជា[23] ផលប៉ះពាល់លើបរិស្ថា

---

[20] https://km.eferrit.com/ "សេចក្តីណែនាំអំពីអេកូទេសចរណ៍"

[21] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៨

[22] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៩

[23] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ២១

នកាន់តែរួញតូច, បង្កើតការយល់ដឹងគោរពវប្បធម៌ និងបរិស្ថានមូលដ្ឋាន, ផ្តល់បទពិសោធន៍ការងារ និងអត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធ, បង្រៀនភ្ញៀវតាមរយៈការទស្សនកិច្ច, ទទួលបានថវិកាពីការចូលទៅទស្សនា, ការរស់នៅរបស់សត្វព្រៃត្រូវបានការពារ, ភ្ញៀវទទួលបានគំនិតថ្មីៗពីតំបន់ និងបានជួយផ្សព្វផ្សាយ។

ទោះបីជាអេកូទេសចរណ៍បានផ្តល់សារៈប្រយោជន៍យ៉ាងច្រើនទៅកាន់ប្រជាពលរដ្ឋក្នុងមូលដ្ឋានក៏ដូចជាភ្ញៀវទេសចរ និងបានចូលរួមអភិវឌ្ឍន៍វិស័យជាច្រើននៅក្នុងប្រទេសកម្ពុជាយ៉ាងណាក្តីក៏នៅតែមានគុណវិបត្តិផងដែរ។ គុណវិបត្តិអេកូទេសចរណ៍មានដូចជា[24] ការសាងសង់នានាកាន់តែកកកុញ, បង្កឱ្យមានជាតិពុលក្នុងតំបន់លំនៅដ្ឋាន, រមណីយដ្ឋានក្លាយជាតំបន់ទាក់ទាញខ្លាំង, ការកើនឡើងភ្ញៀវពិបាកគ្រប់គ្រង, បង្កឱ្យមានបញ្ហាចរាចរណ៍សិករិចរិលកន្លែងចត, មានការសិករិចរិលលើផ្លូវដើរ និងជ្រុះដី, មានការរៀបចំនូវថាមពលខ្នាតធំ សម្រាប់ប្រើប្រាស់, មានការកាប់បំផ្លាញព្រៃឈើដើម្បីអភិវឌ្ឍន៍ និងមានបញ្ហាគ្រប់គ្រងកាកសំណល់រឹងរាវ និងលូទឹក ។

អេកូទេសចរណ៍ គឺជាផ្នែកមួយនៃឧស្សាហកម្មទេសចរណ៍ដែលអាចធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីមានស្ថេរភាព និងអាចធ្វើឱ្យខូចខាតផងដែរអាស្រ័យដោយការគ្រប់គ្រង ឧទាហរណ៍ អាចការពារ និងបំផ្លាញប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធជីវៈចម្រុះ។ ការកើនឡើងនៃចរន្តភ្ញៀវច្រើនអាចធ្វើឱ្យមានការកើនឡើងនូវការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់និងអាចកើតមានអំពើពេស្យា និងការប្រើប្រាស់ថ្នាំញៀន។

កម្ពុជាបានផ្តល់អាទិភាពយ៉ាងសំខាន់ដល់ការអភិវឌ្ឍអេកូទេសចរណ៍នៅភូមិភាគឦសាន្តនៃប្រទេស (រតនគីរី ស្ទឹងត្រែង ក្រចេះ និងមណ្ឌលគីរី)។ ប្រសិនបើគម្រោងទទួលបានជោគជ័យកម្ពុជាអាចទទួលផលចំណេញព្រមគ្នារវាងការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍតំបន់ដាច់ស្រយាលនៃភូមិភាគឦសាន្ត។ ការអភិវឌ្ឍអេកូទេសចរណ៍នៅភូមិភាគឦសាន្តនៃកម្ពុជាត្រូវភ្ជាប់ជាមួយចំណេះដឹង បទពិសោធន៍ ភាពស្មោះត្រង់ មនសិការ និងសីលធម៌ខ្ពង់ខ្ពស់[25]។

## ១.៤. តំបន់ការពារក្នុងសហគមន៍អេកូទេសចរណ៍

ការរស់នៅដោយធុញថប់នៅក្នុងទីក្រុង និងទីប្រជុំជនបានជំរុញឱ្យមនុស្សកាន់តែច្រើនឡើងៗធ្វើដំណើរទៅកាន់ទីជនបទ និងតំបន់ធម្មជាតិនានាដើម្បីផ្លាស់ប្តូរបរិយាកាស និងសម្រាកលំហែ។ តំបន់ធម្មជាតិបានបង្ហាញអំពីទស្សនីយភាពប្លែកៗ បង្ហាញនូវវប្បធម៌របស់ប្រជាជន និងសហគមន៍។ ធនធានធម្មជាតិ និងវប្បធម៌របស់សហគមន៍ គឺជាផលិតផលដែលមានសក្តានុពលទាក់ទាញរបស់អេកូទេសចរណ៍។ ធនធានទាំងអស់នេះភាគច្រើនត្រូវបានគេប្រទះឃើញមាននៅក្នុងតំបន់ការពារ ។

[24] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ២១

[25] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ២២

អង្គការទេសចរណ៍ពិភពលោក (UNWTO) បានយកចិត្តទុកដាក់ចំពោះអេកូទេសចរណ៍តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មកម្ល៉េះហើយបានចេញផ្សាយឯកសារមួយច្បាប់មានចំណងជើងថា "សេចក្តីណែនាំសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងទេសចរណ៍ប្រកបដោយចីរភាពនៃឧទ្យានជាតិ និងតំបន់ការពារនានា (Guidelines for the Sustainable Development and Management of Tourism in National Parks and Protected Areas) ដោយសហការជាមួយកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP) និងសហភាពអន្តរជាតិដើម្បីអភិរក្សបរិស្ថាន (IUCN) ក្នុងឆ្នាំ១៩៩២[26]។

អង្គការ UNWTO UNEP និង IUCN បានផលិតស្នាដៃកាន់តែធំឡើងនាឆ្នាំ២០០២ មានចំណងជើងថា ទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ការពារនិងណែនាំអំពីការរៀបចំផែនការនិងគ្រប់គ្រង (Sustainable Tourism in Protected Areas: Guidelines for Planning and Management)។

ស្នាដៃទាំងអស់នេះបង្ហាញថារវាងតំបន់ការពារ និងទេសចរណ៍គឺទំនាក់ទំនងគ្នាមិនអាចផ្តាច់គ្នាបានឡើយ ។ តាមរយៈទំនាក់ទំនងដ៏ស្មុគ្រស្មាញ និងជួនកាលអាចជាគូបក្ខដិបក្ខនោះទេសចរណ៍ គឺជាសមាសធាតុដ៏សំខាន់ក្នុងការពិចារណាស្ថាបនា និងគ្រប់គ្រងតំបន់ការពារ។ អង្គការទាំង ៣ បានចេញសេចក្តីណែនាំសំដៅកសាងការយល់ដឹង និងវិធានការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់ការពារ[27]។

តាមស្មារតីនៃសន្និសីទតំបន់ និងកិច្ចប្រជុំស្តីពីអេកូទេសចរណ៍ពិភពលោក សេចក្តីប្រកាសជាអន្តរជាតិរបស់អង្គការសហប្រជាជាតិអំពីអេកូទេសចរណ៍នាឆ្នាំ២០០២ និងយោងតាមក្របខណ្ឌនៃសកម្មភាពអនុវត្តអង្គការ UNWTO បានផ្សព្វផ្សាយសេចក្តីណែនាំអំពីវិធីសាស្ត្រការអភិវឌ្ឍអេកូទេសចរណ៍ និងការគាំទ្រនូវសកម្មភាពជាតិ និងតំបន់អភិវឌ្ឍន៍អេកូទេសចរណ៍[28]។

### ១.៤.១. តំបន់ការពារជាអ្វី?

ការបំផ្លិចបំផ្លាញធនធានធម្មជាតិក្នុងគោលបំណងបំពេញតម្រូវការរបស់មនុស្សបានកាន់តែកើតមានឡើងឥតឈប់ឈរ និងគួរឱ្យបារម្ភ។ ប្រទេសមួយចំនួន ដែលពុំមានឧស្សាហកម្មទំនើប ឬប្រទេសក្រីក្របានប្រើប្រាស់ធនធានធម្មជាតិ ឧទាហរណ៍ ការកាប់ព្រៃឈើ ការចាប់សត្វព្រៃដែលមាន ដោយអះអាងថា គឺដើម្បីអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន ។ ការប្រើប្រាស់ធនធានធម្មជាតិហួសកំណត់ និងខ្ជះខ្ជាយបានជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។

---

[26] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៤៥

[27] Sdt.unwto.org/en/content/ecotourism-and-protected-areas, 2013

[28] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៤៥

ពិតណាស់ថាកាលណាព្រៃឈើក្នុងតំបន់ណាមួយ ទទួលរងការបំផ្លិចបំផ្លាញគ្រោះមហន្តរាយធម្មជាតិនឹងកើតមានឡើង ឧទាហរណ៍ទឹកជំនន់មិនត្រឹមតែតំបន់ដែលទទួលរងការបំផ្លាញព្រៃឈើនោះទេតែវានឹងរាលដាលដល់តំបន់មួយចំនួនទៀត។ មានប្រភេទនៃការបំផ្លាញធនធានធម្មជាតិដទៃទៀត ដូចជាការវាតទីយកដីធ្វើលំនៅដ្ឋាន ការធ្វើកសិកម្មព្រៃដុត ការកាប់ឆ្ការព្រៃយកដីធ្វើកសិកម្ម ការផ្តល់ដីព្រៃសម្បទានដល់ក្រុមហ៊ុនដើម្បីអភិវឌ្ឍន៍អ្វីមួយ ក៏ជាគ្រោះថ្នាក់ដែរ ។

ហេតុផលនេះបានជំរុញឱ្យអ្នកវិទ្យាសាស្ត្រដែលមានការបារម្ភអំពីបរិស្ថានពិភពលោកខិតខំរិះរកវិធីដើម្បីបញ្ចៀសការប្រើប្រាស់ធនធានធម្មជាតិដែលមានហួសពីកម្រិតដែលវាអាចបន្តកំណើត និងសន្សំសំចៃធនធានទាំងនោះដោយណែនាំយ៉ាងទទូចឱ្យបង្កើតឱ្យមានតំបន់ការពារ។ តំបន់ការពារខ្លះអាចកើតឡើងក្នុងរូបភាពផ្សេងពីនេះ។ តាមន័យនេះតំបន់ការពារមាននិយមន័យយ៉ាងសាមញ្ញថា គឺជាតំបន់ដែលត្រូវបានកំណត់ឡើងសម្រាប់អភិរក្សធម្មជាតិ[29] ។

តាមអង្គការ IUCN – International Union for the Conservation of nature តំបន់ការពារត្រូវបានផ្តល់និយមន័យថាជាតំបន់ដែលមានលក្ខណៈភូមិសាស្ត្រមានការទទួលស្គាល់គោរពនិងការគ្រប់គ្រងដោយច្បាប់ ឬមធ្យោបាយប្រសិទ្ធភាពនានាដទៃទៀតសំដៅសម្រេចបាននូវការអភិរក្សធម្មជាតិ ដែលមានការពាក់ព័ន្ធនឹងសេវាប្រព័ន្ធអេកូឡូស៊ី និងតម្លៃវប្បធម៌រយៈពេលយូរ[30]។ តំបន់ការពារចាប់ផ្តើមលេចរូបរាងក្នុងអំឡុងសតវត្សទី១៩ និងជាការឆ្លើយតបទៅនឹងការសម្លោជដូចបានលើកឡើងខាងលើ[31]។ តំបន់ការពារជាបំណែកមួយផ្នែករបស់ដី (Land) ឬបឹង ឬសមុទ្រ ទឹកក្រោមដី (In Water) តំបន់ជាយសមុទ្រ និងឆ្នេរសមុទ្រ រួមទាំងពីរ[32] ។ តំបន់ការពារត្រូវបានចារឹក តាមកម្មវត្ថុសំខាន់ៗដូចខាងក្រោម[33]៖

- ការអភិរក្សធម្មជាតិត្រូវរៀបចំតាមកម្រិតនៃតំបន់តែក្នុងករណីមានបញ្ហាការអភិរក្សធម្មជាតិគឺត្រូវគិតជាអាទិភាព
- តំបន់ត្រូវបានគ្រប់គ្រង និងការពារ គឺជាតំបន់ដែលរាល់រូបភាពនៃការធ្វើអាជីវកម្ម ត្រូវហាមដាច់ខាត
- ការជ្រើសរើសប្រភេទតំបន់ការពារ ត្រូវតែផ្អែកលើកម្មវត្ថុចម្បងៗនៃតំបន់ការពារនីមួយៗ
- ប្រព័ន្ធគ្រប់គ្រងតំបន់ គឺជាភ្នាក់ងាររដ្ឋាភិបាល ឬអង្គភាពណាមួយពិតប្រាកដ (ការផ្តល់សិទ្ធិអំណាចឱ្យ)

[29] Tin Ponlok, Dictionary of Environment Terms, Phnom Penh, p46

[30] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៤៥

[31] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៤៧

[32] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៤៩

[33] Nigel Daunly, Guidelines for Applying Protected Area Management Categories, IUCN, Gland, Switzerland, 2008, p.10 (pdf)

- ការគ្រប់គ្រងត្រូវឆ្លើយតបនឹងកិច្ចអភិរក្សតែកម្មវត្ថុនៃតំបន់ការពារមួយត្រូវជាក់លាក់និងមិនអាចទូទៅនីយកម្មបានទេ
- ការគ្រប់គ្រងជីវៈចម្រុះ ត្រូវឆ្លើយតបនឹងសេចក្តីត្រូវការរបស់សហគមន៍ និងត្រូវតែបានលើកទឹកចិត្ត
- កម្មវត្ថុនៃតំបន់ការពារមួយចំនួនត្រូវធ្វើការផ្លាស់ប្តូរករណីការវាយតម្លៃបង្ហាញថាមិនឆ្លើយតបនឹងតម្រូវការដែលបានកំណត់ ឬមិនឆ្លុះបញ្ចាំងនូវប្រសិទ្ធភាពនៃការគ្រប់គ្រង
- បានបង្កើតកម្មវត្ថុអភិរក្សដែលតាមរយៈនេះ ការគ្រប់គ្រងធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីត្រូវមានជាបន្ត និងមានលក្ខណៈប្រសើរឡើងៗ ។

នៅកម្ពុជាតំបន់ការពារត្រូវបានរៀបចំឱ្យមាន និងកំណត់ដោយក្របខណ្ឌច្បាប់ ។ ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ចង្អុលបង្ហាញឱ្យបង្កើតតំបន់ការពារធម្មជាតិ ប្រមាណ ៤ប្រភេទ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា[34]។

## ១.៤.២. តួនាទីអេកូទេសចរណ៍ក្នុងតំបន់ការពារ

អេកូទេសចរណ៍ ត្រូវបានចាត់ថាជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារ។ ទោះបីជាយ៉ាងនេះក្តីក៏មានភាពចាំបាច់ក្នុងការដាក់កម្រិតដល់បណ្តាសកម្មភាពអេកូទេសចរណ៍ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើង។ ការកម្រិតសកម្មភាពត្រូវបានរៀបចំឡើងដោយអ្នកគ្រប់គ្រងតំបន់ការពារដោយផ្អែកលើឯកសារផែនការ (Planning documents)។ ឯកសារផែនការ គឺជាផែនទីដែលកំណត់គោលដៅត្រូវធ្វើដំណើរទៅ ហើយផ្តល់នូវការវាយតម្លៃយ៉ាងល្អិតល្អន់អំពីមូលដ្ឋានធនធានធម្មជាតិ និងវប្បធម៌។ ផែនការត្រូវគូសបញ្ជាក់ផងដែរ អំពីការគំរាមកំហែងពិតប្រាកដចំពោះសមាសភាពធម្មជាតិ និងវប្បធម៌ព្រមទាំងយុទ្ធសាស្ត្រកាត់បន្ថយការគំរាមកំហែងទាំងឡាយ។ បន្ថែមពីលើនេះ ផែនការត្រូវកំណត់កម្មវត្ថុគ្រប់គ្រងយូរអង្វែង និងគម្រោងការបែងចែកតំបន់ដែលកំណត់អត្តសញ្ញាណនៃទីកន្លែងដែលសកម្មភាពពិតប្រាកដអាចកើតឡើង។

តំបន់ការពារត្រូវបានហៅផងដែរថា ឧទ្យានធម្មជាតិដែលជាទីតាំងទាំងឡាយណាដែលទទួលបានកិច្ចការពារព្រោះតំបន់នោះ គឺជាតំបន់ដែលមានតម្លៃផ្នែកធម្មជាតិ អេកូឡូស៊ី និងវប្បធម៌។ ជាទូទៅកម្រិតនៃការការពារ គាំពារ និងថែរក្សាតំបន់ការពារមានរូបភាពច្រើនប្រភេទខុសៗគ្នាផ្អែកតាមច្បាប់របស់ប្រទេសនីមួយៗ តំបន់នីមួយៗ ឬតាមបទដ្ឋាននានានៃអង្គភាពអន្តរជាតិ ដែលមានការពាក់ព័ន្ធ[35]។

ក្រៅជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ការពារអេកូទេសចរណ៍ត្រូវបានចាត់ទុក ថាជាសកម្មភាពនិរន្តរភាពដ៏ឧត្តុងឧត្តមដែលត្រូវបានរៀបចំឡើងដើម្បី ១)-កាត់បន្ថយឱ្យដល់កម្រិតអប្បបរមា នូវផលប៉ះពាល់អវិជ្ជមានចំពោះប្រព័ន្ធអេកូឡូស៊ី ២)- បង្កើត និង បែងចែកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់សហគមន៍

[34] សួន វ៉ានី, ប្រតិបត្តិការដំណើរទេសចរណ៍ និងខ្សែទស្សនកិច្ច ភ្នំពេញ

[35] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៦១

៣)- គោរពវប្បធម៌សហគមន៍ ៤)- អភិវឌ្ឍយន្តការដំណើរការចូលរួមអំពីអ្នកពាក់ព័ន្ធទាំងអស់ ៥)- ត្រួតពិនិត្យក្នុងគោលបំណងការពារផលប៉ះពាល់វិជ្ជមាន និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទាំងឡាយ។

## ១.៥. យល់ដឹងពីសហគមន៍

ពាក្យថា សហគមន៍ត្រូវបានគេផ្ដល់និយមន័យជាច្រើនបែបផ្អែកតាមលក្ខខណ្ឌនានានៃកម្មវត្ថុជាសារវន្តរបស់អ្នកប្រាជ្ញ ស្ថាប័ននានា និងមុខវិជ្ជាសិក្សា។ ពាក្យសហគមន៍ត្រូវបានប្រទះឃើញ និងប្រើប្រាស់ជាញឹកញាប់នៅក្នុងជីវភាពរស់នៅធម្មតា និងក្នុងមុខវិជ្ជាមួយចំនួនដូចជា បរិស្ថានវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា សង្គមវិទ្យា ចិត្តវិទ្យា និងសេដ្ឋកិច្ចវិទ្យា។

ក្នុងអក្សរសាស្ត្រខ្មែរ សហគមន៍មានន័យថា ការទៅជាមួយដំណើរជាមួយគ្នាប្រជុំភូមិ ឬអ្នកស្រុកប្រកបមុខរបរចូលគ្នា[36]។

វិទ្យាសាស្ត្រផែនដីវិទ្យាផ្ដល់ន័យឱ្យ សហគមន៍ ថាជាបណ្ដាភាវៈនៃសារពាង្គកាយមានជីវិត រួមមាន សត្វ រុក្ខជាតិ និងមីក្រូសារពាង្គកាយស្ថិតក្នុងមជ្ឈដ្ឋានរស់នៅមួយ និងមានលក្ខខណ្ឌជីវិតប្រហាក់ប្រហែលគ្នា ឧទាហរណ៍ សហគមន៍សត្វ និងរុក្ខជាតិនៃបឹងមួយវាលស្មៅមួយ ឬតំបន់ឆ្នេរមួយ[37]។ និយមន័យនេះ ថ្វីដ្បិតតែពុំទាន់ទទួលបានការឯកភាពយ៉ាងណាក៏ដោយ ក៏ចំណុចរួមដែលគេសង្កេតឃើញមានន័យផ្ដោតលើអន្តរទំនាក់ទំនងរវាងជីវសាស្ត្រចម្រុះ (សត្វរុក្ខជាតិ មនុស្ស និងមីក្រូសារពាង្គកាយ ) និងសមាសធាតុរបស់ស្ថានប្រព័ន្ធ (អង្គធាតុបង្កគ្មានជីវិតៈ ពន្លឺ ព្រះអាទិត្យ ទឹក និងសីតុណ្ហភាព ភាពស្រដៀងគ្នានៃប្រពៃណីទំនៀមទម្លាប់ និងផ្នត់គំនិតនៃការរស់នៅរបស់មនុស្សនៅក្នុងកន្លែងណាមួយ។

ក្នុងបច្ចេកសព្ទវប្បធម៌សព្វថ្ងៃសហគមន៍ត្រូវបានគេមើលឃើញនិងកំណត់ទៅភូមិសាស្ត្រនៃតំបន់ជ្រលងភ្នំ ភ្នំ ទឹក ឬតាមបែបនយោបាយនៃក្រុងតូច និងធំ និងប្រទេស។ កន្សោមពាក្យ សហគមន៍ជារឿយៗទាក់ទងនឹងទីក្រុងតូច ឬអង្គភាពនានានៃមជ្ឈមណ្ឌលទីក្រុងដូចជា ជាយក្រុងជាដើម។ ភាពខុសគ្នានៃសហគមន៍ទីក្រុង និងសហគមន៍ជនបទ គឺកំណត់តាមភូមិសាស្ត្រ និងនយោបាយច្រើនជាងទាក់ទងនឹងសេវាកម្មការអប់រំបរិស្ថានធម្មជាតិ[38]។ គ្រួសារនានាក៏ជាទម្រង់នៃសហគមន៍ដែរ ព្រោះចំណងគ្រួសារការទទួលខុសត្រូវបដិកានានានិងការគោរពសុទ្ធតែសហគមន៍។ សហគមន៍អន្តោគ្រាមជាច្រើនបានតាំងលំនៅដ្ឋានបែបចនាសម្ព័ន្ធស្មុគ្រស្មាញនៃចំណងគ្រួសារ។

---

[36] វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត គ.ស.១៩៦៧, ទំព័រ៩៩០

[37] ផែនដី និងបរិស្ថានវិទ្យា កម្មវិធីសិក្សាថ្នាក់ទី១១, ២០០០, ទំព័រ៦៤

[38] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ២៧

### ១.៥.១ តួនាទីសហគមន៍ក្នុងអេកូទេសចរណ៍

ពីអតីតកាលស្ទើររាល់សកម្មភាពនៃគម្រោងអភិវឌ្ឍន៍ទេសចរណ៍សហគមន៍ត្រូវបានគេផាត់ចោល ឬគ្មានចំណែក ឬមានចំណែកតិចតួចក្នុងសកម្មភាពអនុវត្តន៍គម្រោងនោះ។ ការរីកចម្រើននៃបរិបទ និងផ្ដត់នាំដល់ការយកចិត្តទុកដាក់ខ្ពស់អំពីផលអវិជ្ជមានដែលអាចកើតមានឡើងដោយសារតែការអភិវឌ្ឍគ្មានតម្លាភាពស្របពេលជាមួយគ្នានឹងការមើលឃើញអំពីសារប្រយោជន៍នៃវត្តមានសហគមន៍ក្នុងការអភិវឌ្ឍអេកូទេសចរណ៍ និងការធានាបាននិរន្តរភាពបានជំរុញទិន្នាការចូលរួមរបស់សហគមន៍កាន់តែមានកម្រិតខ្ពស់ឡើងៗ។

ប៉ុន្មានឆ្នាំចុងក្រោយនេះក្រុមអ្នកអភិរក្សបានចាប់ទទួលស្គាល់អំពីការដើរតួនាទីយ៉ាងសំខាន់របស់សហគមន៍នៅតាមតំបន់ឆ្មេរ និងនៅទីតំបន់ដាច់ស្រយាល ឬទីជនបទនៅក្នុងសកម្មភាពអភិរក្សជីវសាស្រ្តចម្រុះ។ គេសង្កេតឃើញមានអ្នកគ្រប់គ្រងតំបន់ការពារជាច្រើនបានបង្កើតយន្តការនានា ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងសហគមន៍ដោយចាត់ទុកពួកគេជាអ្នកជាប់ពាក់ព័ន្ធនៅក្នុងដំណើរការគ្រប់គ្រងនិងធ្វើផែនការ។ ស្របពេលដែលអេកូទេសចរបង្កើនការចាប់អារម្មណ៍លើការសិក្សាស្វែងយល់ពីលក្ខណៈផ្សេងគ្នានៃវប្បធម៌ការជំរុញឱ្យមានវត្តមានរបស់សហគមន៍ ក្នុងរាល់ការអភិវឌ្ឍអេកូទេសចរណ៍គឺពិតមានការកើនឡើង។

ការអភិវឌ្ឍអេកូទេសចរណ៍ដោយមានការចូលរួមពីសហគមន៍ជាបុព្វហេតុមួយនាំឱ្យមានការយល់ដឹងកាន់តែច្រើនរបស់សហគមន៍អំពីកាលានុវត្តភាពនៃវត្តមានអេកូទេសចរណ៍។ នៅទីកន្លែងដែលសហគមន៍បានរៀបចំបានល្អ និងមានកម្មសិទ្ធិលើដីធ្លីដែលជាកេរតំណែលគេពិនិត្យឃើញថាសហគមន៍នោះទទួលបានជោគជ័យច្រើនក្នុងការទាញយកនូវផលប្រយោជន៍សេដ្ឋកិច្ចពីអេកូទេសចរណ៍នៅក្នុងតំបន់ធម្មជាតិ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ប្រជាជនអន្ដោគ្រាមជាច្រើន និងសហគមន៍ផ្សេងៗទៀតបានស្ម័គ្រចិត្តទទួលយកអេកូទេសចរណ៍ និងចាត់ថាវិស័យនេះមានតម្លៃជាផ្នែកមួយក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៍របស់ខ្លួន។

វិភាគទានអេកូទេសចរណ៍ចំពោះការអភិរក្សបរិស្ថាននាំឱ្យអេកូទេសចរណ៍អាចផ្លាស់ប្តូរសកម្មភាពរបស់ខ្លួនដែលតែងតែគំរាមកំហែងទៅជាកាលានុវត្តភាពពោលគឺសកម្មភាពទាំងអស់នោះបានរួមចំណែកនាំឱ្យការអភិវឌ្ឍទទួលបាននិរន្តរភាព និងការសម្រេចបាននូវគោលដៅអភិរក្សតំបន់។ ដើម្បីបង្កើនផលប្រយោជន៍អភិរក្សនៃសកម្មភាពអេកូទេសចរណ៍ឱ្យបានដល់កម្រិតអតិបរមា គឺចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់អំពីរបៀបដែលអ្នកជាប់ពាក់ព័ន្ធនៅក្នុងមូលដ្ឋាន ឬសហគមន៍អាចចូលរួមក្នុងការធ្វើផែនការ និងការគ្រប់គ្រង។

ពិតណាស់ថា សហគមន៍ ឬសមាជិកសហគមន៍មិនមែនទាំងអស់សុទ្ធតែមានបំណងចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ទេ។ បែបនេះ អ្នករៀបចំផែនការ និងអ្នកអភិវឌ្ឍ ឬតួអង្គអភិវឌ្ឍគួរតែគោរពសេចក្តីសម្រេចចិត្តរបស់អ្នកទាំងនោះផង។ ទោះជាយ៉ាងនេះ សម្រាប់អ្នកទាំងឡាយណាដែលមានចំណែកពាក់ព័ន្ធ គឺអាចជ្រើសរើសប្រភេទនៃការចូលរួមរបស់ខ្លួនតាមលំដាប់កម្រិតមួយចំនួន ដូចជា ១)-ជួលដីទៅឱ្យប្រតិបត្តិករដើម្បីអភិវឌ្ឍន៍ ២)-ធ្វើការជាបុគ្គលិកពេញម៉ោង ក្រៅម៉ោង ឬតាមរដូវកាលនៅក្នុងក្រុមហ៊ុនទេសចរណ៍ ៣)-ផ្តល់សេវាកម្មដល់

ប្រតិបត្តិករទេសចរណ៍ ឧទាហរណ៍ ការរៀបចំម្ហូបអាហារមគ្គុទេសក៍ មធ្យោបាយដឹកជញ្ជូន សេវាកម្មស្នាក់នៅ ឬសេវាកម្មដទៃ ៤)-បង្កើតសម្ព័ន្ធអាជីវកម្មជាមួយនឹងការីទេសចរណ៍ដោយសហគមន៍ធ្វើជាអ្នកបម្រើសេវាកម្មភាគច្រើនក្នុងខណៈពេលដែលដៃគូធ្វើការជាអ្នករៀបចំគ្រប់គ្រងម៉ាឃីតធីង ទីផ្សារ ភស្តុភារ និងមគ្គុទេសក៍ ទេសចរណ៍ ៥)- ប្រតិបត្តិការជាកម្មវិធីសហគមន៍ឯករាជ្យ។

មុខងារ ឬតួនាទីទាំងអស់ដែលត្រូវជ្រើសរើសដោយសហគមន៍គួរតែផ្អែកលើផលប្រយោជន៍សមត្ថភាពរៀបចំបទពិសោធការចាប់អារម្មណ៍លើវប្បធម៌វត្តមាននៃភាពជាអ្នកដឹកនាំពូកែគុណភាពនៃធនធានវប្បធម៌ និងធម្មជាតិតម្រូវការទេសចរណ៍កាលានុវត្តភាពនៃការហ្វឹកហ្វឺនភាពអាចរកបាននូវដៃគូនិងផលប្រយោជន៍ឯកជន[39] ។

សហគមន៍ត្រូវទទួលបានផលប្រយោជន៍ច្រើនបំផុតពេលដែលមានការអភិវឌ្ឍអេកូទេសចរណ៍ប៉ុន្តែមិនមែនសុទ្ធតែជាជម្រើសដែលនឹងអាចកើតមាននោះទេ។ មានសារៈសំខាន់ខ្លាំងណាស់ដែលថាលទ្ធភាពហិរញ្ញវត្ថុរបស់គម្រោងមួយគួរត្រូវបានវាយតម្លៃមុននឹងបន្តនីតិវិធីអភិវឌ្ឍន៍នូវបណ្តាហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់បណ្តាហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ទាំងឡាយ។

## ១.៦. ការអភិវឌ្ឍអេកូទេសចរណ៍

លោក Liliane Pasape និងអ្នកស្រាវជ្រាវជាច្រើនបានបង្ហាញថាការអភិវឌ្ឍអេកូទេសចរណ៍គ្រោះថ្នាក់ខ្លាំងណាស់ (វានឹងបំផ្លាញអ្វីៗស្ទើរទាំងអស់ប្រសិនបើរៀបចំធ្វើដោយមិនបានគិតគូរឱ្យបានស្រួលបួលនិងដោយហ្មត់ចត់ទេនោះ។ នេះបញ្ជាក់ថា ការអភិវឌ្ឍអេកូទេសចរណ៍ត្រូវគិតគូរដល់កត្តា ៨ យ៉ាងជាចាំបាច់ ទី១ មិននាំឱ្យមានការសឹករិចរិលធនធាន និងត្រូវគ្រប់គ្រងបរិស្ថានសំឡេងឱ្យបានល្អក្នុងតំបន់អភិវឌ្ឍ ទី២ ផ្តល់អត្ថប្រយោជន៍ដល់បណ្តាធនធានដល់សហគមន៍ និងដល់ឧស្សាហកម្មទេសចរណ៍រយៈពេលយូរ ទី៣ អប់រំភាគីពាក់ព័ន្ធទាំងអស់អំពីការអភិវឌ្ឍអេកូទេសចរណ៍។ ទី៤ ផ្តល់សិទ្ធិអំណាចការចូលរួម និងបទពិសោធល្អៗ ទី៥ លើកទឹកចិត្តដល់គ្រប់ផ្នែក និងលើកតម្លៃវិសេសវិសាលនៃធនធានទាំងឡាយ ទី៦ ទទួលយក និងទទួលស្គាល់នូវដែនកំណត់នៃធនធានដែលទាក់ទងនឹងការគ្រប់គ្រងតម្រង់ទិសសម្រាប់ផ្គត់ផ្គង់ ទី៧ ជំរុញការយល់ដឹង និងទំនាក់ទំនងភាពជាដៃគូរវាងអ្នកពាក់ព័ន្ធ (ចំណងទាក់ទងជាមួយរដ្ឋាភិបាលអង្គការមិនមែនរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ អ្នកវិទ្យាសាស្ត្រ និងសហគមន៍) ទី៨ ជំរុញការទទួលខុសត្រូវប្រកបដោយគុណធម៌ក្រមសីលធម៌ និងមានឥរិយាបថសំដៅគាំពារបរិស្ថានធម្មជាតិ និងវប្បធម៌ក្នុងចំណោមអ្នកពាក់ព័ន្ធ[40]។

---

[39] សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈ និងបណ្ឌិត ឈឹមផាន់ណា, ទំព័រ៣២

[40] Liliane Pasape, Towards Sustainable Ecotourism through Stakeholder Collaborations in Tanzania, Department of Marketing, University of Dar es Salaam December 26, 2012, p.2

### ១.៦.១ និយមន័យការអភិវឌ្ឍ

ការអភិវឌ្ឍក្នុងលក្ខណៈទ្រឹស្តីដែលមនុស្សជាទូទៅចាត់ទុកការអភិវឌ្ឍថាជាការលូតលាស់និងការរីកចម្រើនទៅមុខប្រកបដោយជោគជ័យ។ ជាការពិតណាស់ តាមការសិក្សាការអភិវឌ្ឍ គឺជាដំណើរការពហុមាត្រាដ្ឋានដែលរួមបញ្ចូលនូវការផ្លាស់ប្តូរ និងការអភិវឌ្ឍទាំងបរិមាណ និងគុណភាព។ ការអភិវឌ្ឍ គឺធ្វើឱ្យសង្គមមួយមានការរីកចម្រើនលូតលាស់ជឿនលឿនលើគ្រប់វិស័យ ដូចជា វិស័យទេសចរណ៍ ប្រព័ន្ធរដ្ឋបាល នយោបាយរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ដូច្នេះ ពាក្យថាការអភិវឌ្ឍនេះ គឺត្រូវធ្វើឱ្យមានសុក្រិតភាពលើស្ថាប័នសង្គម និងរដ្ឋបាលសាធារណៈ ផ្នត់គំនិតប្រជាជន ការជំរុញកំណើនសេដ្ឋកិច្ចដើម្បីលុបបំបាត់ចោលភាពក្រីក្រ អនក្ខរភាព និងការថែរក្សាការពារបរិស្ថានធម្មជាតិ និងសម្បត្តិវប្បធម៌នានា។ រួមសេចក្តីមក ការអភិវឌ្ឍមានន័យថា៖

- ផ្លាស់ប្តូរពីអ្វីដែលគ្មាន ទៅជាមាន
- ផ្លាស់ប្តូរពីអ្វីដែលមានស្រាប់ឱ្យមានលក្ខណៈសម្បត្តិកាន់តែប្រសើរឡើង ពោលគឺផ្លាស់ប្តូរកម្រិតជីវភាពរស់នៅរបស់ប្រជាជាតិឱ្យមានការរីកចម្រើន និងប្រសើរឡើង
- ការអភិវឌ្ឍ គឺជាការធ្វើអ្វីដែលគ្មានឱ្យទៅជាមាន និងអ្វីដែលមានរួចហើយត្រូវតែធ្វើឱ្យប្រកមដោយប្រសិទ្ធភាព គុណភាព និងនិរន្តភាព[41]។

### ១.៦.២ ភាពចាំបាច់នៃការអភិវឌ្ឍទេសចរណ៍

ការអភិវឌ្ឍវិស័យទេសចរណ៍ត្រូវបានគេទទួលស្គាល់ថាជាគន្លឹះមួយសម្រាប់ទ្រទ្រង់ដល់កិច្ចការសង្គម។ ដើម្បីបុព្វហេតុដូចបញ្ជាក់នេះ វិស័យទេសចរណ៍ត្រូវបានជំរុញអភិវឌ្ឍន៍។ មានគោលដៅគន្លឹះចំនួន៥ ដែលជាប់ទាក់ទងនឹងការខិតខំអភិវឌ្ឍន៍ទេសចរណ៍ នៃបណ្តាប្រទេសជាច្រើនលើពិភពលោក និងរួមទាំងព្រះរាជាណាចក្រកម្ពុជាផង មានដូចខាងក្រោម[42] ៖

**១.ការធានាសុខុមាលភាពប្រជាពលរដ្ឋ** ជាការពិតណាស់សកម្មភាពទេសចរណ៍ត្រូវបានមនុស្សជាអ្នកប្រព្រឹត្តឡើង។ ការប្រព្រឹត្តឡើងនូវសកម្មភាពទាំងនេះគឺដោយសារមនុស្សមានគោលបំណងសម្រាកលំហែកាយ អារម្មណ៍កម្សាន្តសប្បាយរីករាយ ធ្វើបំលាស់ប្តូរបរិយាកាសទស្សនា ស្វែងយល់ដឹង ព្យាបាល កីឡា សាសនា អាជីវកម្ម សួរសុខទុក្ខញាតិសន្តាននិងការរក្សាសុខភាព។

បើសិនពលករ (ពលរដ្ឋ) មានសុខភាពមិនល្អ រាងកាយទ្រុឌទ្រោម សកម្មភាពការងារដែលអ្នកទាំងនោះកំពុងធ្វើ ឬត្រូវបានផ្តល់ឱ្យធ្វើនោះ ប្រាកដជា គ្មានប្រសិទ្ធភាព និងបន្សល់ទុកនូវការលំបាកដល់សង្គម អង្គភាព ក្រុមហ៊ុន និងប្រទេសរបស់គេ។ សង្គមមនុស្ស ពិសេស សង្គមលោកខាងលិចយល់ច្បាស់ថាកម្លាំងពលកម្មម្នាក់ៗ

[41] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១១

[42] សួន វ៉ានី និងហុង វណ្ណៈ, និរន្តភាពនៃការអភិវឌ្ឍទេសចរណ៍, ភ្នំពេញ ២០១២, ទំព័រ៣៦

ចាំបាច់ត្រូវតែមានលទ្ធភាព និងឱកាសគ្រប់គ្រាន់សម្រាប់ ការសម្រាកលំហែកាយ អារម្មណ៍ ប្រមូលកម្លាំងកាយ និងប្រាជ្ញាដែលបានបាត់បង់តាមរយៈការបំពេញការងាររបស់ពួកគេ។ មនុស្សត្រូវបានទទួលស្គាល់ថាជាធនធានដ៏មានតម្លៃ និងជាអ្នកធ្វើឱ្យអ្វីៗដំណើរការបានជាអ្នកធ្វើឱ្យមានផលិតភាព និងរកប្រយោជន៍ដល់កន្លែងដែលគាត់ធ្វើការ។

រដ្ឋាភិបាលដែលយកចិត្តទុកដាក់អំពីសុខភាពរបស់ប្រជាពលរដ្ឋជារដ្ឋាភិបាលដែលពិភពលោកឱ្យតម្លៃថា មានអារិយធម៌ខ្ពង់ខ្ពស់។ មាត្រា១ ស្តីពីសិទ្ធិសេរីភាពរបស់មនុស្សនៃអង្គការសហប្រជាជាតិ ១៩៨៥) បានបញ្ជាក់ថា៖

ប្រជាពលរដ្ឋគ្រប់ៗរូបត្រូវតែទទួលបាន១-សិទ្ធិសេរីភាពពេញលេញក្នុងការសម្រាកលំហែកាយអារម្មណ៍ ២- សិទ្ធិទទួលឱ្យបានត្រឹមត្រូវនូវរយៈពេលធ្វើការងារក្នុងមួយថ្ងៃ (៨ម៉ោង) និងប្រាក់បៀវត្សន៍ និង៣-សិទ្ធិក្នុងការទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការឈប់សម្រាកក្នុងរយៈពេលដែលគាត់ត្រូវបានអនុញ្ញាតឱ្យឈប់សម្រាក។ ក្រោយពីបានបម្រើការងារអស់រយៈពេលមួយឆ្នាំហើយកម្លាំងពលកម្មទាំងឡាយត្រូវមានសិទ្ធិសេរីភាពគ្រប់គ្រាន់សម្រាប់ធ្វើដំណើរទៅតំបន់ណាមួយដែលខ្លួនចង់ទៅទូទាំងពិភពលោកដើម្បីសម្រាកលំហែកាយ អារម្មណ៍ កម្សាន្ត សប្បាយរីករាយ ធ្វើបំលាស់ប្តូរបរិយាកាស ស្វែងយល់ដឹង ព្យាបាល កីឡាសាសនា អាជីវកម្ម សួរសុខទុក្ខញាតិសន្តាន និងការរក្សាសុខភាព។ សកម្មភាពទាំងឡាយនេះត្រូវបានចាត់ទុកថាជាសកម្មភាពទេសចរណ៍ និងវាជាគន្លឹះដ៏សំខាន់មួយ ដែលជួយបង្កើត បង្កើន និងស្តារកម្លាំងកាយ ចិត្ត ប្រាជ្ញា និងថាមពល របស់មនុស្សដែលបានបាត់បង់ក្នុងរយៈពេលដែលពួកគេបានបម្រើការងារជូនអង្គភាព ក្រុមហ៊ុន ឬស្ថាប័នមួយ។

ជាការពិតណាស់ សកម្មភាពទេសចរណ៍ គឺជាគន្លឹះដ៏មានសារៈសំខាន់មួយ ដែលជួយបង្កើត បង្កើន និងស្តារឡើងវិញកម្លាំងកាយកម្លាំងចិត្ត កម្លាំងប្រាជ្ញា និងថាមពលរបស់មនុស្ស ដែលបានបាត់បង់ដោយសារការងារ។ គ្មានទេសចរណ៍ អ្វីៗទាំងឡាយនឹងបាត់បង់ជីវិតលែងមានន័យ សង្គមនឹងមានភាពសោះកក្រោះ។ មនុស្សទាំងឡាយនឹងមិនមានឱកាសប្រើប្រាស់ពេលវេលាទំនេររបស់ពួកគេដើម្បីធ្វើសកម្មភាពសម្រាកលំហែកម្សាន្តហើយ។ ហេតុផលដូចលើកឡើងនេះបាននាំឱ្យមានការជំរុញអភិវឌ្ឍន៍ទេសចរណ៍។ មានន័យថាវិស័យទេសចរណ៍ត្រូវតែបានបង្កើតឡើង និងធានាឱ្យមនុស្សគ្រប់ៗរូបមាន ឱកាសចូលរួម និងធ្វើសកម្មភាពតាមបំណងប្រាថ្នា និងស្របច្បាប់។

**២.ការទាញយកផលពីការប្រើប្រាស់ធនធាន** ប្រទេសទាំងឡាយនៅលើពិភពលោកមាន និងបានទាញយកប្រយោជន៍ផ្សេងៗគ្នាពីសម្បត្តិធម្មជាតិ និងធនធានដទៃជាច្រើនទៀត។ ធនធានទាំងនេះមាន រ៉ែ ធនធានមានជីវិតដែលត្រូវបានគេជីកយ៉ាងមានប្រសិទ្ធភាព និងប្រើប្រាស់ក្នុងគោលបំណងសេដ្ឋកិច្ច។ ប្រទេសមួយចំនួនធំនៅឈូងសមុទ្រភាគច្រើនរស់នៅបានយ៉ាងល្អប្រសើរបំផុតបើធៀបទៅនិងប្រទេសដទៃលើពិភពលោកដោយការជីក និងធ្វើអាជីវកម្មលើប្រេង។

ទោះជាយ៉ាងនេះក៏ដោយ ក៏ប្រទេសមួយចំនួនក្នុងតំបន់នោះ ពិសេស គឺប្រទេសអារ៉ាប់រួម (អារ៉ាប់អេមីរ៉ាត់) បច្ចុប្បន្ននេះត្រូវបានទទួលស្គាល់ថាជាតំបន់ទេសចរណ៍ដ៏សំខាន់នៅភូមិភាគអារ៉ាប់។ ទេសចរណ៍នៅក្នុងប្រទេស

វាលខ្សាច់នេះសព្វថ្ងៃមានគុណសម្បត្តិប្រជែងបានជាមួយនឹងវិស័យអាជីវកម្មប្រេងទៀតផង។ ឯប្រទេសចិនវិញបានរៀបចំគម្រោងទទួលទេសចរបរទេសដល់ទៅ ១៣០លាននាក់នៅឆ្នាំ ២០១៥ ។

គួរបញ្ជាក់ដែរថា ក្រៅពីត្បូងថ្ម ប្រេង មាស ពេជ្រ នៅលើលោកយើងនេះមានសម្បត្តិធម្មជាតិ (រុក្ខា ព្រៃ ភ្នំ សត្វ ទន្លេ បឹង ស្ទឹង។ល។ ដ៏សន្ធឹកសន្ធាប់ថែមទៀតដែលជាមធ្យោបាយមួយដ៏ប្រសើរ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច (សេដ្ឋកិច្ចទេសចរណ៍) ដោយមិនចាំបាច់ខំប្រឹងប្រែងខ្លាំងពេកនោះទេ។ ឧទាហរណ៍៖ ចរន្តបំលាស់ប្តូរនៃទឹកសមុទ្រនៅប្រទេសបារាំងបានផ្តល់គុណសម្បត្តិពិសេសមួយសម្រាប់ការចូលទៅទស្សនារបស់ទេសចរពិភពលោក។ ប្រជាជនក្នុងតំបន់ និងមន្ទីរទេសចរណ៍ក្នុងតំបន់បានប្រើប្រាស់ធម្មជាតិដ៏ប្រសើរនេះយ៉ាងសកម្មក្នុងការទាក់ទាញទេសចរមកទស្សនា ហើយបង្កើតបាននូវឱកាសដ៏វិសេសវិសាលសម្រាប់ប្រជាពលរដ្ឋក្នុងតំបន់ប្រមូលប្រាក់សន្ធឹកសន្ធាប់តាមរយៈការលក់វត្ថុអនុស្សាវរីយ៍សេវាកម្មទេសចរណ៍ និងផ្តល់ចំណីអាហារ។ ការបង្ហាញខាងលើនេះអាចឱ្យសន្មត់បានថា ចរន្តបំលាស់ប្តូរនៃទឹកសមុទ្រនេះជាធនធានទេសចរណ៍ដែលចិញ្ចឹមជីវិតពលរដ្ឋ និងទីក្រុងនេះទាំងស្រុង។

ទេសចរណ៍ទោះជាតិចឬច្រើន តែងតែប្រើប្រាស់និងទាញយកប្រយោជន៍ពីធនធានមួយចំនួនក្នុងតំបន់សម្រាប់គោលដៅសេដ្ឋកិច្ច។ ឧទាហរណ៍សព្វថ្ងៃនេះតំបន់កោះនៅប្រទេសមួយចំនួនក្នុងពិភពលោកដោយសារតែមានគុណសម្បត្តិទាក់ទាញពិសេស និងភាពសម្បូរបែបនៃធនធានធម្មជាតិ (ភាពទាក់ទាញពិសេសនៃរុក្ខា ព្រៃ ភ្នំ សត្វ ទន្លេ បឹង ស្ទឹង ទេសភាព។ល។) បានក្លាយទៅជាតំបន់ទេសចរណ៍ដ៏ធំ ដែលទទួលបានទេសចរបរទេសពី ៥-៧ដង លើសចំនួនប្រជាពលរដ្ឋម្ចាស់ស្រុក (អ្នករស់នៅក្នុងតំបន់នោះ) ទៅទៀត។

មួយវិញទៀត គឺពាក់ព័ន្ធនឹងធនធានវប្បធម៌ ប្រវត្តិសាស្ត្រ ដែលជាធនធានមួយប្រភេទមិនអាចត្រូវបានប្រើប្រាស់នៅក្នុងបណ្តាសកម្មភាពសេដ្ឋកិច្ចណាមួយបានឡើយ។ ផ្ទុយទៅវិញ ធនធានទាំងនេះ គឺមានកាលានុវត្តភាពសម្រាប់ទាក់ទាញ និងអភិវឌ្ឍន៍ទេសចរណ៍។ ជាការពិតណាស់ធនធានវប្បធម៌ (បេតិកភណ្ឌ ប្រវត្តិសាស្ត្រ ប្រាង្គប្រាសាទ សំណង់បុរាណសំណង់សម័យសាសនា វត្តអារ៉ាម។ល។) គឺជាធនធានដ៏មានសក្តានុពលដែលបង្កើតនូវភាពទាក់ទាញទេសចរណ៍។

**៣.ផលប្រយោជន៍ដល់នយោបាយ** នយោបាយសេដ្ឋកិច្ចនិងទេសចរណ៍ត្រូវដើរជាមួយគ្នាដោយមិនអាចបំបែកបានពីគ្នាឡើយ។ ទេសចរណ៍ស្ថិតនៅក្រោមការត្រួតពិនិត្យ និងយកចិត្តទុកដាក់បំផុតពីរដ្ឋ និងអ្នកនយោបាយ។ ទេសចរណ៍ជាអាវុធដ៏សំខាន់ក្នុងការទទួលយក ឬបំពេញគោលនយោបាយណាមួយរបស់រដ្ឋ។ ទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជាក៏អាចចាត់ទុកថាជាវិស័យឈានមុខនៃអាជីវកម្មនៅក្នុងប្រទេសដែរ។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើវិស័យនេះបន្ថែមទាំងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រីកនិងអភិវឌ្ឍន៍ហើយបានអូសទាញទេសចរបរទេសឱ្យចូលមកសម្រាកលំហែ និងកម្សាន្តព្រមទាំងឱកាសយ៉ាងច្រើនដល់ពួកគេផង។

រឿងសំខាន់មួយទៀត គឺទេសចរណ៍បានបង្កលទ្ធភាពយ៉ាងល្អប្រសើរក្នុងកិច្ចពង្រឹង និងពង្រីកទំនាក់ទំនងល្អ សន្តិសុខក្នុងតំបន់ ប្រទេសនិងពិភពលោកបំបាត់សង្គ្រាម។ល។ សង្គ្រាមតែងតែផ្តល់ផលអាក្រក់ដល់សេដ្ឋកិច្ច អសន្តិសុខសង្គម ហើយជាកត្តាចម្បងក្នុងការធ្វើឱ្យទេសចរភ័យខ្លាចពុំហានចូលមកធ្វើសកម្មភាពនិងទស្សនាកម្សាន្ត។ ទាំងអស់នេះ នាំឱ្យថយចុះនូវប្រាក់ចំណូលពីទេសចរណ៍ប្រជារាស្ត្របាត់បង់ការងារធ្វើអាជីវកម្មប្រឈមនឹងការដួលរលំ។ល។ សង្គ្រាម និងទេសចរណ៍មិនអាចកើតឡើងក្នុងពេលតែមួយនោះទេ។

នយោបាយក្នុងពេលសព្វថ្ងៃនេះបានក្លាយជាកម្មវត្ថុរបស់ទេសចរណ៍។ ការប្រជុំធំៗជាលក្ខណៈអន្តរជាតិ (ដំណោះស្រាយបញ្ហានយោបាយពិភពលោក) គឺជាកម្មវត្ថុនៃសកម្មភាពដ៏ចម្បងសម្រាប់ក្រុមហ៊ុនទេសចរណ៍។ ទេសចរណ៍ត្រូវបានអ្នកដឹកនាំខ្ពស់ៗ និងអ្នកនយោបាយធំៗ ប្រើប្រាស់សម្រាប់រៀបរៀងបង្កើតជាមតិសាធារណៈ និងរៀបចំដំណោះស្រាយលើបញ្ហានយោបាយធំៗ។ មហោស្រពយុវវ័យពិភពលោកកីឡាអូឡាំពិចបានទាក់ទាញ និងទទួលនូវការយកចិត្តទុក ដាក់ខ្លាំងពីសំណាក់ពិភពសាធារណៈ និងផ្តល់នូវទម្ងន់ដល់នយោបាយ និងមនោគមវិជ្ជាផងដែរ។

**៤.ការបង្កើតតម្លៃមនុស្សជាតិ** ទេសចរណ៍មានឥទ្ធិពលយ៉ាងខ្លាំងទៅលើសង្គមជាតិវប្បធម៌ និងវិស័យសិក្សាធិការរបស់រដ្ឋ។ វាជាផ្នែកមួយនៃទំនាក់ទំនងជាលក្ខណៈអន្តរជាតិ និងបំណងប្រាថ្នាអំពីសន្តិភាព ការគោរពបូរណៈភាពដែនដី និងសង្គមមនុស្សជាទូទៅ។ វាសំដែងនូវកត្តាជាវិជ្ជមានដ៏ច្រើន ដែលផ្តល់ជាជំនួយសម្រាប់ការយោគយល់និងយល់ដឹងជាមូលដ្ឋានសម្រាប់ ការទទួលបានលទ្ធផលខ្ពស់លើការគោរពនិងទំនុកចិត្តរវាងពលរដ្ឋ និងពលរដ្ឋ។ ទេសចរណ៍ទំនើបកើតមានឡើងដោយសារការប្រើប្រាស់នយោបាយសង្គមយ៉ាងប្រពៃមួយ(លទ្ធភាពរបស់កម្មករឬបុគ្គលិកទទួលបានឱកាសឈប់សម្រាក និងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ពេលឈប់សម្រាកក្រោយពីបំពេញការងារបានមួយឆ្នាំ) និងក្នុងពេលតែមួយតាមរយៈការផ្តល់សិទ្ធិសេរីភាពពេញលេញដល់ប្រជាពលរដ្ឋក្នុងការសម្រាកលំហែកាយ និងអារម្មណ៍។

អ្វីទាំងនេះ បានក្លាយជាគន្លឹះមួយក្នុងការធ្វើឱ្យសង្គមមនុស្សមានភាពស្មើគ្នាឱ្យមានការយោគយល់គ្នា (រវាងពលរដ្ឋប្រទេសមួយ និងពលរដ្ឋប្រទេសដទៃ)និងទទួលបានការរីកចម្រើននូវគំនិតមតិផ្ទាល់របស់មហាជន។ ទេសចរណ៍ក្លាយទៅជាផ្នែកមួយដ៏ធំក្នុងការជំរុញឱ្យមានការរីកដុះដាលនៃវប្បធម៌សង្គម និងទឹកចិត្តរបស់ប្រជាពលរដ្ឋព្រោះទេសចរណ៍ គឺជាមធ្យោបាយដ៏សំខាន់សម្រាប់ស្វែងយល់ដឹង និងការបង្កើតចំណេះដឹងផ្ទាល់របស់មនុស្សជាតិ។ ទេសចរណ៍ផ្តល់លទ្ធភាពដល់មនុស្ស ក្នុងការទស្សនា និងយល់ដឹងអំពីប្រវត្តិសាស្ត្រ វប្បធម៌ដែលជាវត្ថុមានតម្លៃរបស់មនុស្សនៃតំបន់ណាមួយ ឬរបស់ប្រទេសដែលខ្លួនរស់នៅ។ នៅក្នុងដំណើរនៃការអភិវឌ្ឍទេសចរណ៍ ត្រូវតែបានជួយដល់ការបង្កើនសេដ្ឋកិច្ច និងជះឥទ្ធិពលទៅលើការរីកដុះដាល (បង្កើតឡើង) នូវការយល់ដឹងរបស់មនុស្ស។

ការការពារថែរក្សាសម្បត្តិ វប្បធម៌ ប្រវត្តិសាស្ត្រ សាសនា និងបេតិកភណ្ឌក្នុងប្រទេស ឬតំបន់ គឺជារឿងដែលអាទិភាព។ ក្នុងរយៈពេលនៃការមានឧប្បត្តិ ហេតុសង្គ្រាម។ល។ ជាករណីចាំបាច់ និងជាកាតព្វកិច្ចដ៏សំខាន់របស់ប្រជាពលរដ្ឋ រដ្ឋាភិបាល និងពិភពលោក។

**៥.ការបំពេញបំណងរបស់មនុស្ស** ដើម្បីបម្រើឱ្យអារម្មណ៍ និងបំណងប្រាថ្នា(ធ្វើ ដឹង ឃើញ កម្សាន្ត ។ល។) មនុស្សបានបង្ខំចិត្តក្នុងរយៈពេលដ៏វែង សន្សំប្រាក់ ដើម្បីបានធ្វើដំណើរចេញពីផ្ទះ (លំនៅដ្ឋានអចិន្ត្រៃយ៍) ទៅកាន់តំបន់ណាមួយដើម្បីសម្រាកលំហែកាយអារម្មណ៍ ស្វែងរកភាពសប្បាយរីករាយ និងធ្វើបំលាស់ប្តូរបរិយាកាស។ ការសិក្សាអំពីបំណងប្រាថ្នារបស់មនុស្សទាំងឡាយបានបង្ហាញថា ពួកគេត្រូវការចាំបាច់នូវសកម្មភាពទេសចរណ៍ (មានន័យថាមិនអាចខ្វះបាន)។ ជីវិតនឹងមិនមានន័យអ្វីទាំងអស់ប្រសិនបើមនុស្សទាំងឡាយមិនបានធ្វើសកម្មភាពទេសចរណ៍។ សេចក្តីប្រាថ្នាទាំងអស់នេះ មានដូចតទៅៈ

- បានស្គាល់អំពីវប្បធម៌ប្លែកៗ ហើយថ្មីសម្រាប់ពួកគេ
- បានស្គាល់ និងកម្សាន្តជាមួយជីវិតប្លែកៗ
- លទ្ធភាពសម្រាកលំហែក្នុងរមណីយដ្ឋាន
- រស់នៅមួយរយៈក្នុងជីវិតថ្មីមួយដែលធ្លាប់មានពីមុន
- ទិញទំនិញ វត្ថុអនុស្សាវរីយ៍ ចំណាយប្រាក់សន្សំ
- ទទួលនូវអារម្មណ៍ជាមនុស្សផ្សេង (មនុស្សកម្រិតខ្ពស់)
- ផ្លាស់ប្តូរបរិយាកាស បន្ធូរអារម្មណ៍ និងលំហែ
- ទស្សនាល្ខោន មហោស្រព តន្ត្រី ការប្រលងប្រជែង
- ជួបជាមួយមនុស្សថ្មីដែលជាទីជាប់ចិត្ត
- ស្វែងយល់/សិក្សាពីលក្ខខណ្ឌអាជីវកម្មនៅទីណាមួយ
- ទិញទំនិញសម្រាប់ពាណិជ្ជកម្ម និងការដោះដូរ
- សម្រាក លំហែនៅមាត់សមុទ្រ និងសកម្មភាពកីឡា
- ព្យាបាល កែលម្អសុខភាពផ្ទាល់ខ្លួនឡើងវិញ
- ស្វែងយល់ពីសាសនា
- ជួបនឹងបងប្អូន ញាតិមិត្ត មិត្តភក្តិ។ល។

ហេតុផលដូចលើកឡើងនាខាងលើនេះនាំឱ្យវិស័យទេសចរណ៍ត្រូវបានជំរុញអភិវឌ្ឍ។ មានន័យថាបង្កើតទេសចរណ៍ដើម្បីជួយដល់មនុស្សទាំងឡាយឱ្យមានកាលានុវត្តភាពបំពេញបំណងរបស់ពួកគេ។

## ១.៧ យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍អេកូទេសចរណ៍កម្ពុជា

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើយុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺ

ការរៀបចំ និងដាក់ចេញនូវវិធានការគោលនយោបាយសំដៅរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន សហគមន៍មូលដ្ឋាន គ្រឹះស្ថានហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជា តាមយន្តការភាពជាដៃគូរវាងរដ្ឋ ឯកជន ប្រជាពលរដ្ឋមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍ (4P) ដោយនឹងអនុវត្តតាមអភិក្រម ប្រយ័ត្នប្រយែងជាជំហានៗ ដែលរួមមាន[43]៖

1.ការចាប់ផ្តើមពីការពិនិត្យ និងកែសម្រួលនូវក្របខណ្ឌគតិយុត្ត ការរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការការបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុតាមការចាំបាច់ និងការកំណត់យន្តការស្ថាប័នឱ្យបានច្បាស់លាស់ព្រមទាំងការបង្កើតក្រុមការងារអន្តរក្រសួងជាស្ថាប័នសម្រាប់គ្រប់គ្រង និងសម្របសម្រួលអនុវត្តយុទ្ធសាស្ត្រនេះ។

2.អភិក្រម "រៀនផងធ្វើផង" ដោយរៀនសូត្រពីបទពិសោធជាក់ស្តែងទៅគ្រប់ដំណាក់កាលអនុវត្តនៃវដ្តរបស់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ ជាពិសេសការធ្វើអត្តសញ្ញាណកម្មគម្រោងរៀបចំបញ្ជីគម្រោងអាទិភាពសិក្សាសមិទ្ធិលទ្ធភាព និងគ្រប់គ្រងការអនុវត្តគម្រោងដើម្បីឈានទៅធ្វើការកែលម្អប្រព័ន្ធគ្រប់គ្រងយន្តការ (4P) ក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជាឱ្យមានសុក្រឹតភាព ប្រសិទ្ធភាព និងសិក្តិសិទ្ធភាព។ ក្នុងដំណាក់កាល "រៀនផងធ្វើផង" នេះដោយឈរលើគោលការណ៍ប្រុងប្រយ័ត្នខ្ពស់រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តតែ៖

- គម្រោងដែលផ្តួចផ្តើមដោយរដ្ឋ ឬសហគមន៍ ឬដោយដៃគូអភិវឌ្ឍសម្រាប់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ (ខ្នាតតូចដែលទីតាំងនេះមានវត្តមានប្រជាពលរដ្ឋមូលដ្ឋានស្រាប់។
- រាជរដ្ឋាភិបាលនៅតែរក្សាភាពទន់ភ្លន់និងហ្មតចត់ក្នុងការទទួលយកគម្រោងដឹកនាំដោយផ្នែកឯកជនមួយចំនួនដែលមាននវានុវត្តភាពកម្រិតខ្ពស់មកពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តផងដែរ។
- ការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្សកម្រិតថ្នាក់ជាតិថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន។

ក្នុងន័យនេះរាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជាមានដូចខាងក្រោម៖

### ១.៧.១ ធ្វើផែនការ និងបែងចែកជាតំបន់អេកូទេសចរណ៍អាទិភាពនិងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍គំរូ

យុទ្ធសាស្ត្រក្នុងការធ្វើផែនការនិងបែងចែកជាតំបន់អាទិភាពនិងការរៀបចំរមណីយដ្ឋានអេកូទេសចរណ៍រួមមាន[44]៖

• កំណត់ជាតំបន់អេកូទេសចរណ៍អាទិភាពចំនួន៤ រួមមាន៖ តំបន់ភូមិភាគឦសាន្ត តំបន់បឹងទន្លេសាប និងទន្លេមេគង្គតំបន់ឆ្នេរសមុទ្រ និងតំបន់ជួរភ្នំក្រវាញព្រមទាំងធ្វើការកំណត់អត្តសញ្ញាណកម្មរមណីយដ្ឋានអេកូទេសចរណ៍នៅតាមតំបន់អាទិភាពនីមួយៗ។

---

[43] រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០, អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៩ ខែវិច្ឆកា ឆ្នាំ២០១៨, pdf, ទំព័រ៩

[44] រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០, អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៩ ខែវិច្ឆកា ឆ្នាំ២០១៨, pdf, ទំព័រ១០

• រៀបចំអភិវឌ្ឍជារមណីយដ្ឋានអេកូទេសចរណ៍គំរូយ៉ាងហោចមួយនៅតាមតំបន់អាទិភាពនីមួយៗដែលអាចបម្រើឱ្យភ្ញៀវទេសចរស្នាក់នៅរយៈពេលខ្លី មធ្យម និងវែង (ទេសចរផ្ទះទីពីរ)។

• តម្រូវឱ្យមានផែនការមេអភិវឌ្ឍអេកូទេសចរណ៍សម្រាប់គម្រោងអភិវឌ្ឍអេកូទេសចរណ៍នីមួយៗ ដោយត្រូវគិតគូរអំពីការឆ្លើយតបនឹងការបម្រែបម្រួលអាកាសធាតុផង និងឆ្លើយតបតម្រូវការចាំបាច់នៃការអភិវឌ្ឍឱ្យបានជាអតិបរមាផង ស្របតាមគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍។

• រាល់គម្រោងអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ត្រូវមាន៖

• ត្រូវមានការកំណត់តួនាទីច្បាស់លាស់នៃគ្រប់ភាគីពាក់ព័ន្ធ។

• ត្រូវមានគម្រោងអាជីវកម្មសម្រាប់រាល់គម្រោងអភិវឌ្ឍអេកូទេសចរណ៍យន្តការបែងចែកប្រាក់ចំណេញការសិក្សាទីផ្សារ និងផ្សព្វផ្សាយ គំរូហិរញ្ញប្បទាន ផែនការគ្រប់គ្រងហានិភ័យជាដើម

• ត្រូវមានការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានទាក់ទងនឹងការគ្រប់គ្រងកាកសំណល់រឹង និងរាវច្បាស់លាស់។

• ត្រូវមានយន្តការគ្រប់គ្រងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចណ៍។

• ត្រូវមានការវិភាគសមត្ថភាពផ្ទុកនៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ដើម្បីកំណត់បរិមាណអតិបរមានៃភ្ញៀវទេសចរចូលទស្សនាតាមរមណីយដ្ឋាននីមួយៗ។

• រៀបចំឱ្យមានមូលនិធិទ្រទ្រង់ដល់ការសិក្សារៀបចំគម្រោងក្នុងដំណាក់កាលសមិទ្ធលទ្ធភាព។

• តម្រូវឱ្យអ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ គឺជាសហគមន៍មូលដ្ឋានសម្រាប់រាល់គម្រោងស្ថិតលើទីតាំងដែលមានប្រជាសហគមន៍មូលដ្ឋានស្រាប់។

• រៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងលើការតុបតែងរចនា ការស្ថាបនា និងប្រតិបត្តិការ នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ចាំបាច់នានាក្នុងរមណីយដ្ឋានអេកូទេសចរណ៍។

# ជំពូកទី២

# សហគមន៍អេកូទេសចរណ៍អារ៉ែង និងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍ

យើងបានដឹងហើយថា៖ ប្រទេសកម្ពុជាជាប្រទេសកំពុងមានការអភិវឌ្ឍទៅលើគ្រប់វិស័យជាពិសេសវិស័យទេសចរណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរកចំណូលឱ្យជាតិផ្តល់ការងារជាច្រើនកន្លែងដល់ប្រជាជនកាត់បន្ថយចំណាកស្រុកបង្កើនចំណូលជាតិនិងប្រជាពលរដ្ឋគ្រប់រូប។ និងជាប្រទេសមួយដែលសម្បូរទៅដោយសក្តានុពលទេសចរណ៍ដូចជា៖ ធនធានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ និងការកែច្នៃ។ ក្រសួងទេសចរណ៍បានឱ្យដឹងថាក្រសួងបានធ្វើការកំណត់នូវប៉ូលអភិវឌ្ឍន៍តំបន់ទេសចរណ៍ចំនួន៤ធំៗគឺ[45]៖

• តំបន់ភ្នំពេញ និងតំបន់ជុំវិញជារាជធានីមួយដ៏ល្បីល្បាញនៅអាស៊ីអាគ្នេយ៍ និងជាមជ្ឈមណ្ឌលនយោបាយ វប្បធម៌ ពាណិជ្ជកម្ម ទេសចរណ៍ ហើយជាទីតាំងប្រសព្វនៃទន្លេមេគង្គបែកជាមុខបួន និងសក្តានុពលទេសចរណ៍ (តំបន់ជុំវិញបឹងទន្លេសាប ព្រះបរមរាជ វាំង សារមន្ទីជាតិ)

• អង្គរ និងតំបន់ជុំវិញជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដែលមានភាពល្បីល្បាញនៅលើពិភពលោក (ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន និងប្រាសាទជាច្រើនផ្សេងទៀត)

• តំបន់ឆ្នេរជាតំបន់អេកូទេសចរណ៍ ដែលមានភាពទាក់ទាញខ្លាំង (ខេត្តកំពត ខេត្តកោះកុង ខេត្តកែប និងខេត្តព្រះសីហនុ)

• តំបន់ភូមិភាគឦសាន ជាតំបន់អេកូទេសចរណ៍ដែលរំលេចទៅដោយភាពទោលជាពិសេសសត្វផ្សោតទន្លេមេគង្គ ទេសភាពធម្មជាតិ និងវប្បធម៌ប្រពៃណីរបស់ជនជាតិ ភាគតិច (ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងរតនៈគិរី) ។

ដោយសារតែកត្តានៃតំបន់ដែលមានភាពទាក់ទាញទាំងអស់នេះហើយ ទើបមានការរីកចម្រើននិងអភិវឌ្ឍន៍ទៅមុខនៃវិស័យទេសចរណ៍របស់កម្ពុជាដែលបាន ផ្តល់នូវប្រាក់ចំណូលនិងការងារជាច្រើនដល់ប្រជាពលរដ្ឋក្នុងស្រុកនិងក្នុងតំបន់ឱ្យមានជីវភាពធូរធារក៏ដូចជាជួយកាត់បន្ថយភាពក្រីក្រផងដែរ។ ហេតុនេះហើយទើបពួកខ្ញុំបានជ្រើសរើសយកតំបន់អេកូទេសរណ៍សហគមន៍អារ៉ែង ជាឧទាហរណ៍ជាក់ស្តែងក្នុងការធ្វើផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍អេកូទេសរណ៍ប្រកបដោយ និរន្តភាព ស្ថេរភាព ការអភិវឌ្ឍ អភិរក្ស នៅក្នុងតំបន់និងសហគមន៍[46] ។

---

[45] ក្រសួងទេសចរណ៍ Ministry of Tourism, Cambodia

[46] https://khmertomorrow.com/areng-koh-kong-biodiversity-sanctuary-kh/

រូបភាពទី១៖ ផែនទីគោលដៅទេសចរណ៍នៅក្នុងប្រទេសកម្ពុជា[47]




## ២.១ ប្រវត្តិនិងទីតាំងភូមិសាស្ត្រ

តំបន់អារ៉ែងជាផ្នែកមួយនៃជួរភ្នំក្រវាញមានផ្ទៃដីជិត ១០ម៉ឺនហិកតាគ្របដណ្តប់ដោយព្រៃ ស្រោង ព្រៃរបោះ ដីចម្ការ ដីស្រែ និងដងស្ទឹង ដងព្រែក។ តំបន់អារ៉ែងជាតំបន់ព្រៃក្រាស់និងធំចុងក្រោយគេរបស់កម្ពុជា និងជាតំបន់ព្រៃត្រូពិចដ៏ធំនិងសំខាន់ជាងគេនៅក្នុងអាស៊ីអាគ្នេយ៍។ តំបន់នេះគឺជាផ្លូវធ្វើដំណើរឆ្លងកាត់របស់សត្វដំរីមួយក្នុងចំណោមផ្លូវចំនួនទាំង៧ ដែលនៅសេសសល់ក្នុងទ្វីបអាស៊ីហើយជាជម្រកចុងក្រោយរបស់សត្វក្រពើសៀម និងអណ្តើករាជ្យនៅលើសកលលោក[48] ។

តំបន់ស្ទឹងអារ៉ែងស្ថិតនៅក្នុងស្រុកថ្មបាំង ខេត្តកោះកុងភាគនិរតីនៃប្រទេសកម្ពុជាដែលមានប្រជាជនរស់នៅប្រមាណ ១,៧១២នាក់ (៤៧៣ គ្រួសារ) គ្របដណ្តប់លើឃុំចំនួន ៣ រួមមាន ឃុំថ្មដូនពៅ ឃុំជំនាប់ និងឃុំប្រឡាយ[49]។ ឃុំទាំង ៣ នេះមានភូមិចំនួន ៨[50]៖ ភូមិជំនាប់ ភូមិកោះ ភូមិព្រែកស្វាយ ភូមិច្រកឫស្សី ភូមិប្រឡាយ ភូមិសំពោង ភូមិទ័ពឃ្លៃ និងភូមិចំណារ។ អារ៉ែងមានចំងាយប្រមាណ ៨០ គ,ម ពីក្រុងខេមរភូមិន្ទ ខេត្តកោះកុង និងមានចំងាយប្រមាណ៣០០ គ,ម ពីរាជធានីភ្នំពេញ ដែលភ្ញៀវទេសចរជាតិ អន្តរជាតិទាំងអស់អាចធ្វើដំណើរ

47 https://ontheworldmap.com/cambodia/cambodia-tourist-map.html

48 https://visitcambodia.travel/kh/

49 http://areng-valley.org/kh/aboutus

50 http://areng-valley.org/kh/aboutus

មកកាន់សហគមន៍នេះបានតាមផ្លូវជាតិលេខ៤ និងលេខ៤៨ ជាមួយទេសភាពព្រៃភ្នំខៀវស្រងាត់អមជាមួយខ្យល់អាកាសបរិសុទ្ធនៃតំបន់ព្រៃត្រូពិច[51] ។

### ២.១.១ មធ្យោបាយធ្វើដំណើរ

យើងអាចធ្វើដំណើរពីភ្នំពេញឬតាមបណ្តាខេត្តនានាទៅកាន់សហគមន៍អារ៉ែងបានតាមរយៈ[52]៖

រូបភាពទី២៖ ភូមិនៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែង[53]



**រថយន្តក្រុង** ចេញដំណើរពីភ្នំពេញ៖ ធ្វើដំណើរតាមរថយន្តក្រុងដែលមានគោលដៅទៅទីរួមខេត្តកោះកុង ចេញពីភ្នំពេញនៅម៉ោង ៧ ព្រឹក ត្រង់មហាវិថីម៉ៅសេទុង មុំផ្សារដើមគរ។ ចុះពីរថយន្តក្រុងនៅផ្លូវប្រសព្វ វាលពីរ/ថ្មបាំង តាមផ្លូវលេខ៤៨ ដែលត្រូវមកដល់ផ្លូវប្រសព្វនេះប្រហែលម៉ោង ១ រសៀល[54]។

**ចេញដំណើរពីកោះកុង** រថយន្តក្រុងចេញដំណើរពីស្ថានីយ៍រថយន្តក្រុងមកភ្នំពេញនៅម៉ោង ៨ ព្រឹកហើយចុះពីរថយន្តក្រុងត្រង់ផ្លូវប្រសព្វវាលពីរ/ថ្មបាំងនៅម៉ោង ១០ព្រឹក។ ពីផ្លូវប្រសព្វវាលពីរ/ថ្មបាំង អ្នកអាចរកម៉ូតូឌុបមកកាន់តំបន់ស្ទឹងអារ៉ែងដោយខ្លួនឯងបាន ឬក៏បើសិនជាពួកយើងដឹងថាអ្នកមកដល់ពេលណាពួកយើងអាចជួយ

[51] http://areng-valley.org/kh/aboutus

[52] https://visitcambodia.travel/kh/

[53] https://www.facebook.com/arengecotourism/

[54] http://www.areng-valley.org/kh/direction

រៀបចំម៉ូតូឌុបរបស់អ្នកភូមិឱ្យទៅយកអ្នកត្រង់ចំណុចផ្លូវប្រសព្វដែលមានចម្ងាយ ៦០គ.ម ពីសហគមន៍។ ការធ្វើដំណើរតាមម៉ូតូឌុបចំណាយពេលប្រហែល ៤៥នាទី[55]។

**តាមរថយន្តផ្ទាល់ខ្លួន** ចេញដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ៤ រួចបត់តាមផ្លូវលេខ៤៨។ ធ្វើដំណើរតាមផ្លូវលេខ ៤៨ ប្រហែល ១១៩គ.ម មកកាន់ផ្លូវប្រសព្វវាលពីរ/ថ្មបាំង។ នៅផ្លូវប្រសព្វលោកអ្នកនឹងឃើញមានផ្លាកសញ្ញាធំមួយដាក់ថា សហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង។ រួចបត់តាមផ្លូវដែលមានសភាពហុយ និងបន្តដំណើរប្រមាណ ៦០គ.ម ទើបមកដល់សហគមន៍តំបន់ស្ទឹងអារ៉ែង[56]។

### ២.១.២ ចាកចេញពីតំបន់ស្ទឹងអារ៉ែង

អ្នកអាចធ្វើការកក់សំបុត្ររថយន្តក្រុងពីតំបន់ស្ទឹងអារ៉ែងមករាជធានីភ្នំពេញ និងខេត្តកោះកុង នៅក្នុងសហគមន៍ផ្ទាល់។ សូមធ្វើការកក់សំបុត្រទៅមកយ៉ាងហោចណាស់ឱ្យបាន ១ថ្ងៃមុនធ្វើដូចនេះយើងខ្ញុំអាចជួយរៀបចំសេវាម៉ូតូឌុបជូនលោកអ្នកទៅកាន់ផ្លូវប្រសព្វនៅលើផ្លូវលេខ៤៨ បាន។ ធ្វើដំណើរចេញពីផ្លូវប្រសព្វវាលពីរ/ថ្មបាំង អ្នកអាចទៅដល់រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ខេត្តកោះកុង និង ខេត្តត្រាត ឬ ទីក្រុងបាងកក ប្រទេសថៃក្នុងថ្ងៃដដែលបាន។ កន្លែងគោលដៅផ្សេងទៀតត្រូវការ ការឈប់សម្រាកមួយយប់ក្នុងរាជធានីភ្នំពេញ ឬជិះរថយន្តក្រុងពេលយប់បន្តពីរាជធានីភ្នំពេញ ទៅខេត្តសៀមរាប ឬខេត្តបាត់ដំបង។ ប្រសិនបើអ្នកធ្វើដំណើរទៅខេត្តកោះកុង ឬប្រទេសថៃអ្នកអាចជិះម៉ូតូឌុបនៅម៉ោង១១ ពីតំបន់ស្ទឹងអារ៉ែងដើម្បីចាំជិះរថយន្តក្រុងនៅផ្លូវប្រសព្វដែលមកដល់នៅម៉ោងប្រហែល ១រសៀល។ ប្រសិនបើអ្នកធ្វើដំណើរទៅកាន់គោលដៅផ្សេងទៀត អ្នកចាំបាច់ត្រូវចាកចេញពីតំបន់ស្ទឹងអារ៉ែងដោយជិះម៉ូតូឌុបនៅវេលាម៉ោង៦ ព្រឹក ដើម្បីធានាថាអ្នកអាចមកទាន់រថយន្តក្រុងមកដល់ផ្លូវប្រសព្វនៅម៉ោង៨ ព្រឹក ធ្វើដំណើរក្នុងទិសដៅឆ្ពោះទៅរាជធានីភ្នំពេញ។ ម៉ូតូឌុបចេញដំណើរពីតំបន់ស្ទឹងអារ៉ែងទៅផ្លូវប្រសព្វ ចំណាយពេលអស់ប្រមាណជា ៤៥នាទី[57]។

ប្រសិនបើអ្នកមានសំនួរ ឬត្រូវការជំនួយក្នុងការរៀបចំផែនការធ្វើដំណើរ អាចទាក់ទងក្រុមការងារយើងតាមរយៈអ៊ីម៉ែល arengbooking@gmail.com ឬទូរស័ព្ទលេខ +855 97 35 55 638 (097 35 55 638 ប្រសិនបើទូរស័ព្ទនៅក្នុងប្រទេស)[58]។

---

55 http://www.areng-valley.org/kh/direction

56 http://www.areng-valley.org/kh/direction

57 https://visitcambodia.travel/kh/item/view/545494d4f4t264a4x2u213x2

58 http://areng-valley.org/kh/contactus

រូបភាពទី៣៖ ផែនទីតំបន់អេកូទេសចរណ៍ស្ទឹងអារ៉ែង[59]




## ២.២ ភាពអំណោយផល

អារ៉ែងជាតំបន់ព្រៃត្រូពិចធំជាងគេនៅអាស៊ីអាគ្នេយ៍ដែលមានទស្សនិយភាពទេសចរណ៍ប្រកបដោយភាពស្រស់បំព្រងនិងពោរពេញទៅដោយធនធានធម្មជាតិយ៉ាងសម្បូរបែប ហើយជាតំបន់មួយដែលសម្បូរទៅដោយសក្ដានុពលធម្មជាតិនិងបុរាណជាច្រើនដូចជា ព្រៃភ្នំ ទឹកជ្រោះ ជ្រលង ដងអូរ សត្វព្រៃស្ទឹង ត្រីនាគ ក្រពើភ្នំ រូងភ្នំបុរាណ ពាងបុរាណ តំបន់ជនជាតិភាគតិច តំបន់ភ្នំ និងជម្រកសត្វព្រៃ[60]។

យោងទៅតាមប្រសាសន៍របស់លោក សេង ទៀក បាននិយាយថានៅក្នុងទសវត្សរ៍ទី ៥0 ប្រទេសកម្ពុជាត្រូវបានអ្នកវិទ្យាសាស្ត្រនិងអ្នកស្រាវជ្រាវពិពណ៌នាថា ជាឋានសួគ៌របស់សត្វព្រៃក្នុងទ្វីបអាស៊ី និងជាតំបន់មួយដែលមានសត្វព្រៃច្រើនជាងគេក្នុងពិភពលោកបន្ទាប់ពីទ្វីបអាហ្វ្រិក។ លោកអះអាងថា៖ « ការលើកឡើងនេះក៏មានភ័ស្តុតាងបញ្ជាក់ក្នុងភាគយន្តឯកសារស្តីពីការស្រាវជ្រាវសត្វគោព្រៃទន្សោង ខ្ទីង ក្របីព្រៃនៅកម្ពុជាដោយអ្នកវិទ្យាសាស្ត្រជនជាតិអាមេរិចក្នុងឆ្នាំ ១៩៥១ »។

## ២.៣ ការបង្កើតសហគមន៍

ការបង្កើតសហគមន៍និងបញ្ចុះបញ្ចូលប្រជាជនដែលរស់នៅក្នុងតំបន់នោះដែលធ្លាប់តែរស់នៅបែបជីវភាពសាមញ្ញនិងដើរព្រៃពិតជាមានផលវិបាកក្នុងការបង្កើតឡើង តែយ៉ាងណាមិញដោយសារមើលឃើញពីធនធានធម្មជាតិ និងសក្ដានុពលផ្សេងៗដែលមានស្រាប់នៅក្នុងតំបន់ទើបបណ្ដាលឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អារ៉ែងបានរួមគ្នាបង្កើតនៅសហគមន៍នេះឡើងដោយឱ្យឈ្មោះថា៖ សហគមន៍អេកូទេសចរណ៍ « ស្ទឹងអារ៉ែង » ។

[59] http://areng-valley.org/kh/direction

[60] http://areng-valley.org/kh/home

សហគមន៍នេះមានប្រជាជន ៤៧៣ គ្រួសារគ្របដណ្តប់៣ឃុំគឺឃុំចំណារ ឃុំជំនាប់ និងឃុំថ្មដូន៣ ហើយសមាជិកសហគមន៍មាន ១៤៩ សមាជិកសហគមន៍ត្រូវបានបង្កើតឡើងក្នុងខែមករាឆ្នាំ២០១៦ ដែលមានការចូលរួមពីសំណាក់ប្រជាសហគមន៍អាជ្ញាធរមូលដ្ឋានក្រោមការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការសម្ព័ន្ធមិត្ត សត្វព្រៃ (Wildlife Alliance)[61]។

គម្រោងសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង (STAR-CBET) ក្នុងគោលបំណងការពារប្រព័ន្ធអេកូឡូស៊ីដ៏មានសារៈសំខាន់ពីការប្រមាញ់សត្វព្រៃ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ពិសេសការផ្តល់នូវជម្រើសចិញ្ចឹមជីវិតបន្ថែមទៀតសម្រាប់ប្រជាសហគមន៍មូលដ្ឋានតាមរយៈអេកូទេសចរណ៍ប្រកបដោយនិរន្តរភាព[62]។

អង្គការសម្ព័ន្ធមិត្តសត្វព្រៃផ្តល់នូវការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់គម្រោងសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង[63]។ STAR-CBET បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ មូលដ្ឋាន ភាគីពាក់ព័ន្ធ និងក្រសួងស្ថាប័នរដ្ឋនានា ហើយត្រូវបានគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជនក្នុងមូលដ្ឋានផ្ទាល់។ សហគមន៍ក៏ទទួលបាននូវអាជ្ញាបណ្ណទេសចរណ៍ពី មន្ទីរទេសចរណ៍ ហើយបានចុះបញ្ជីការត្រឹមត្រូវជាមួយក្រសួងមហាផ្ទៃ ជាសមាគមន៍មួយ។

### ២.៣.១ គោលបំណងក្នុងការបង្កើតសហគមន៍អារ៉ែង

កត្តាសំខាន់ៗដែលបណ្តាលឱ្យមានសហគមន៍នេះកើតឡើងក្នុងគោលបំណង[64] ៖

- ដោយសារតែមានធនធានធម្មជាតិស្រាប់និងមើលឃើញពីសក្តានុពលនៃតំបន់នេះ
- បង្កើនចំណូលដល់ប្រជាជនក្នុងតំបន់ពីអ្នកដែលធ្លាប់តែប្រកបរបរដើរព្រៃឱ្យមកផ្តល់សេវាកម្មឱ្យភ្ញៀវទេសចរណ៍វិញ
- ដើម្បីការពារបរិស្ថាន ធម្មជាតិ សត្វព្រៃ
- ការពារនិងថែរក្សានៅតំបន់ដែលមានវត្ថុបុរាណ
- មានហេដ្ឋារចនាសម្ព័ន្ធល្អក្នុងការគ្រប់គ្រងនិងងាយស្រួលទទួលភ្ញៀវទេសចរជាពិសេសអ្នកចូលចិត្តដំណើរបែបផ្សងព្រេង (ទាំងជាតិនិងអន្តរជាតិ)
- ដើម្បីកាត់បន្ថយចំណាកស្រុករបស់ប្រជាពលរដ្ឋនៅក្នុងតំបន់
- ដើម្បីផ្តល់នូវជម្រើសការងារថ្មីដល់អ្នកកាប់ព្រៃ អ្នកបរបាញ់សត្វ និងអ្នកអាស្រ័យលើអនុផលព្រៃឈើ
- ប្រជាជនមានការរស់នៅស្រួល មានការងារធ្វើជាប្រចាំ

---

[61] http://areng-valley.org/kh/aboutus

[62] https://khmertomorrow.com/areng-koh-kong-biodiversity-sanctuary-kh/

[63] តាមប្រសាសន៍ផ្ទាល់របស់លោក ទិត លី ជាប្រធានមន្ទីរសហគមន៍អេកូទេសចរណ៍អារ៉ែង, សន្ទនាតាមរយៈទូរស័ព្ទ

[64] https://www.wildlifealliance.org/

- ប្រជាជនមានជំនាញនិងវិជ្ជាជីវៈ ចំណេះដឹងពាក់ព័ន្ធនិងបដិសណ្ឋារកិច្ច ការទទួលភ្ញៀវ នាំផ្លូវនិងផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយស្តង់ដា និងមានគុណភាពខ្ពស់
- ថែរក្សាតំបន់ការពារ និងព្រៃឈើ
- លើកកម្ពស់ស្ថានភាពនិងការរស់នៅរបស់ប្រជាជនជនជាតិភាគតិចឱ្យមានភាពសម្បូរបែបនិងងាយស្រួលជាងមុន
- ដើម្បីឱ្យប្រជាជនយល់ពីគោលបំណងការពារប្រព័ន្ធអេកូឡូស៊ីដ៏មានសារៈសំខាន់ពីការប្រមាញ់សត្វព្រៃ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់

រូបភាពទី៤៖ នៅតំបន់សហគមន៍ស្ទឹងអារ៉ែង[65]




រូបភាពទី៥៖ នៅមុខមជ្ឈមណ្ឌលសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង[66]




[65] https://www.facebook.com/arengecotourism/

[66] https://www.facebook.com/arengecotourism/

រូបភាពទី៦៖ ការចូលរួមសកម្មភាពក្នុងសហគមន៍[67]



រូបភាពទី៧៖ ហូបអាហារថ្ងៃត្រង់[68]



[67] https://www.facebook.com/arengecotourism/

[68] https://www.facebook.com/arengecotourism/

### ២.៣.២ ចក្ខុវិស័យ

ប្រជាពលរដ្ឋតំបន់ស្ទឹងអារ៉ែង មានគោលបំណងចង់ធ្វើឱ្យសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង ទទួលបានជោគជ័យ ការគោរព និងជាគំរូនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពមួយនៅក្នុងប្រទេសកម្ពុជា និងឆាកអន្តរជាតិ[69]។ ពួកគាត់ជាប្រជាជនមូលដ្ឋាន នឹងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍នេះ ដោយសហការជាមួយភាគីអភិវឌ្ឍន៍នានាដើម្បីទាក់ទាញភ្ញៀវទេសចរ និងចូលរួមយ៉ាងសកម្ម ក្នុងកិច្ចការពារធនធានធម្មជាតិ និងវប្បធម៌។ គម្រោងនេះចូលរួមចំណែកដោយផ្ទាល់ជួយដល់ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍មូលដ្ឋាន[70]។

### ២.៣.៣ គោលដៅ

STAR-CBET ត្រូវបានបង្កើតឡើងដើម្បីកិច្ចការពារធនធានធម្មជាតិ ធនធានវប្បធម៌ និងការអភិរក្សបរិស្ថាន[71]។ គម្រោងនេះត្រូវបានគាំទ្រ និងគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន និងបានជួយបង្កើតនូវឱកាសការងារ ផ្តល់នូវជម្រើសមួយក្នុងការទទួលបានចំណូលប្រកបដោយចីរភាពហើយបានកាត់បន្ថយដោយផ្ទាល់នូវបទឧក្រិដ្ឋព្រៃឈើ និងសត្វព្រៃ[72]។ តាមរយៈការបម្រើផលិតផល និងសេវាកម្មទេសចរណ៍គម្រោងនេះបានជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សប្រកបដោយនិរន្តរភាពហើយបានចូលរួមចំណែកការពារបេតិកភ័ណ្ឌធម្មជាតិប្រទេសកម្ពុជា សម្រាប់កូនចៅជំនាន់ក្រោយ។

### ២.៣.៤ តម្លៃស្នូល

នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានគុណប្រយោជន៍និងគុណតម្លៃជាច្រើនដូចជា អភិវឌ្ឍ, អភិរក្ស, និរន្តភាព, មានប្រសិទ្ធភាព, តម្លាភាព, មានប្រយោជន៍, ងាយស្រួល, ឯករាជ្យ និងសមស្រប[73]។

### ២.៣.៥ ពីអង្គការសម្ព័ន្ធមិត្តសត្វព្រៃ

អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ភាពដើមនៃតំបន់ស្ទឹងអារ៉ែងត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការកាប់ព្រៃឈើ និងការប្រមាញ់សត្វព្រៃខុសច្បាប់[74]។ ដើម្បីដោះស្រាយនូវឫសគល់នៃបញ្ហាការកាប់បំផ្លាញព្រៃឈើ និងកាត់បន្ថយភាពក្រីក្រដោយផ្ទាល់សម្រាប់ប្រជាជនមូលដ្ឋាន អង្គការសម្ព័ន្ធមិត្តសត្វព្រៃបានអនុវត្តនូវគម្រោងសហគមន៍អេកូទេសចរណ៍នេះឡើង[75]។ គម្រោង STAR-CBET បានផ្តល់នូវជម្រើសប្រភពចំណូលមួយសម្រាប់

---

[69] https://www.wildlifealliance.org/

[70] https://ams.com.kh/central/detail/31333

[71] https://www.wildlifealliance.org/

[72] តាមប្រសាសន៍ផ្ទាល់របស់លោក ទិត្យ លី ជាប្រធានមន្ទីរសហគមន៍អេកូទេសចរណ៍អារ៉ែង, សន្ទនាតាមរយៈទូរស័ព្ទ

[73] http://areng-valley.org/kh/aboutus

[74] https://www.wildlifealliance.org/

[75] https://www.wildlifealliance.org/

អ្នកកាប់ព្រៃឈើ និងអ្នកបរបាញ់សត្វពិសេសគោលការណ៍បែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ដល់សហគមន៍ដែលវាបានជួយលើកទឹកចិត្តដល់ប្រជាជនមូលដ្ឋានឱ្យចូលរួមក្នុងកិច្ចការពារតំបន់ស្ទឹងអារ៉ែង និងកាត់បន្ថយសកម្មភាពបំផ្លាញព្រៃឈើនានានៅក្នុង តំបន់។ គោលដៅ និងកិច្ចខិតខំប្រឹងប្រែងដើម្បីក្លាយខ្លួនជាភូមិមួយប្រកបដោយចីរភាព និងចូលរួមក្នុងការការពារព្រៃឈើត្រូវបានណែនាំ និងគាំទ្រដោយអង្គការសម្ព័ន្ធមិត្តសត្វព្រៃ។ អ្នកក៏អាចចូលរួមជួយគាំទ្រការងាររបស់ពួកយើងបានដែរ តាមរយៈឱកាសនានាដែលអង្គការសម្ព័ន្ធមិត្តសត្វព្រៃបានផ្តល់ជូនដូចជា ធ្វើជាកាដូរ ជួយឧបត្ថម្ភសត្វព្រៃ ដាំដើមឈើ និងមានអ្វីៗច្រើនជាងនេះទៀត។

## ២.៤ ផលប្រយោជន៍ចំពោះសហគមន៍អារ៉ែង

ផលប្រយោជន៍ចំពោះសហគមន៍អារ៉ែងមានដូចជា៖

**និរន្តរភាពចំពោះព្រៃឈើនិងសត្វព្រៃ** នៅពេលដែលប្រជាជនក្នុងភូមិនិងសហគមន៍ធ្វើការសាមគ្គីភាពក្នុងស្មារតីរឹងមាំដើម្បីធ្វើការការពារព្រៃឈើពីឈ្មួញទុច្ចរិតក្នុងការកាប់ព្រៃឈើយកទៅលក់ និងធ្វើសកម្មភាពខុសច្បាប់ពួកគេនឹងទទួលបានធម្មជាតិដ៏ស្រស់ស្អាតនិងល្អប្រពៃនិងអាចយកផលដំណាំផ្សេងៗនានានៅក្នុងតំបន់របស់ពួកគេរស់នៅ។ ជាពិសេសក្នុងការការពារសត្វព្រៃ និងថែរក្សាឱ្យបាននូវជម្រកសត្វព្រៃដ៏ធំជាងគេក្នុងទ្វីបអាស៊ីយើងនេះ។

**ទទួលបានប្រាក់ចំណូល** នៅពេលដែលតំបន់យើងពោរពេញទៅដោយធម្មជាតិព្រៃឈើខៀវស្រងាត់និងសត្វព្រៃតំបន់បុរាណនានា ប្រជាជនអាចរកប្រាក់ចំណូលកើនឡើងទៅតាមចំនួនភ្ញៀវទេសចរដែលបានមកកម្សាន្តតំបន់អារ៉ែង។ នៅពេលដែលសហគមន៍មានចំណែកពិតប្រាកដក្នុងដំណើរការអភិវឌ្ឍន៍អេកូទេសចរណ៍ប្រភពចំណូលត្រូវបានបង្កើតឡើងសម្រាប់សហគមន៍ ដោយសារឱកាសការងារ។ ចំណូលទាំងនេះ កើតឡើងតាមរយៈការប្រមូលថ្លៃឈ្នួលផ្សេងៗ ដូចជា ការប្រើប្រាស់ផ្លូវ ការផ្តល់កន្លែង ស្នាក់នៅ ឬសេវាកម្មមគ្គុទេសក៍ ទេសចរណ៍ ការរៀបចំនិងលក់ម្ហូបអាហារ និងការលក់វត្ថុអនុស្សាវរីយ៍ជាដើម។ ចំណូលទាំងនេះ នាំដល់ការកាត់បន្ថយការពឹងអាស្រ័យទៅលើសកម្មភាពដែលផ្តល់ផលអវិជ្ជមានមួយចំនួនដូចជា ការកាប់បំផ្លាញ ព្រៃឈើ ការបរបាញ់សត្វព្រៃការរានដី។ល។ ប្រការសំខាន់ត្រង់ថាក្នុងដំណើរការរៀបចំផែនការ គេត្រូវជៀសវាងការមកដល់របស់ភ្ញៀវច្រើនហួសពីសមត្ថភាពទ្រទ្រង់របស់សហគមន៍ និងតំបន់ការពារ។ ការមកដល់របស់ភ្ញៀវច្រើនលើសកម្រិតដែលអាចធ្វើឱ្យបាត់បង់នូវគុណភាពរូបសាស្ត្រនៃធនធានទាក់ទាញ (ធនធានធម្មជាតិ និង វប្បធម៌) របស់សហគមន៍។

**ទទួលបានការបណ្តុះបណ្តាលនូវជំនាញវិជ្ជាជីវៈបដិសណ្ឋារកិច្ច** ការផ្តល់សេវាកម្មទេសចរណ៍ឱ្យភ្ញៀវ ចំណេះដឹងផ្សេងៗពាក់ព័ន្ធនិងទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រនិងតំបន់កម្សាន្តនានានៅក្នុងសហគមន៍អារ៉ែង ។

**ប្រជាជនមានចំណូលខ្ពស់** តាមរយៈការទទួលបានការងារ និងការបើកអាជីវកម្ម។

## ២.៥ ធនធានធម្មជាតិ សេវាកម្ម តំបន់កម្សាន្ត និងសកម្មភាពធ្វើទេសចរ

### ២.៥.១ ធនធានធម្មជាតិ

អារ៉ែងជាតំបន់ព្រៃត្រូពិចធំជាងគេនៅអាស៊ីអាគ្នេយ៍ដែលមានទស្សនីយភាពទេសចរណ៍ប្រកបដោយភាពស្រស់បំព្រងនិងពោរពេញទៅដោយធនធានធម្មជាតិយ៉ាងសម្បូរបែប ហើយជាតំបន់មួយដែលសម្បូរទៅដោយសក្តានុពលធម្មជាតិនិងបុរាណជាច្រើនដូចជា[76] ៖ ព្រៃភ្នំ ទឹកជ្រោះ ជ្រលង ដងអូរ សត្វព្រៃ ស្ទឹង ពាងបុរាណ ត្រីនាគ ក្រពើភ្នំ រូងភ្នំបុរាណ ទឹកធ្លាក់ តំបន់ខ្ពស់រាប ភ្នំ និងព្រៃឈើ។

រូបភាពទី៨៖ ទឹកធ្លាក់ស្ទឹងត្រយ៉ាង[77]




រូបភាពទី៩៖ តំបន់ព្រៃភ្នំនៅតំបន់អារ៉ែង[78]




[76] https://visitcambodia.travel/kh/

[77] https://www.kohkong.gov.kh/archives/4657

[78] https://www.popular.com.kh/tours/128814.html/

រូបភាពទី១០៖ ពាង និងមឈូសបុរាណអាយុ៥០០ឆ្នាំ



រូបភាពទី១១៖ ត្រីនាគ[79]



[79] https://www.kohkong.gov.kh/archives/4657

រូបភាពទី១២៖ សត្វក្រពើភ្នំ[80]



ជាពិសេសជាតំបន់ដែលមាននូវធនធានសត្វព្រៃកម្រៗ មួយចំនួនដូចជា ដំរី ស្វា ក្រពើភ្នំ ត្រីនាគ ខ្លាឃ្មុំសត្វឈ្លូសសត្វប្រើស ខ្លារខិន ខ្លាពពក ទន្សោង ខ្ទីង និងជ្រូកព្រៃ[81] ។

រូបភាពទី១៣៖ សត្វទន្សោង[82]



[80] https://cambodiafreeidea.wordpress.com//

[81] https://visitcambodia.travel/kh/

[82] youthsmovement.com

រូបភាពទី១៤៖ សត្វជ្រូកព្រៃ[83]




រូបភាពទី១៥៖ សត្វខ្លាពពក[84]




83 youthsmovement.com

84 https://www.popular.com.kh/tours/128814.html/

### ២.៥.២ សេវាកម្ម

សហគមន៍នេះមាន ៦ សេវាកម្មគឺ[85]៖ មគ្គុទេសទេសចរណ៍ ផ្ទះស្នាក់ឬ ជួលតង់ ចុងភៅភូមិ ទូក ម៉ូតូឌុប និងគោយន្ត។

រូបភាពទី១៦៖ ពូម៉ូតូឌុប[86]



រូបភាពទី១៧៖ ជិះទូកមើលទេសភាព[87]



[85] តាមប្រសាសន៍ផ្ទាល់របស់លោក ទិត លី ជាប្រធានមន្ទីរសហគមន៍អេកូទេសចរណ៍អារ៉ែង, សន្ទនាតាមរយៈទូរស័ព្ទ

[86] https://www.kohkong.gov.kh/archives/4657

[87] youthsmovement.com

រូបភាពទី១៨៖ ជិះម៉ូតូចូលព្រៃបោះតង់[88]




រូបភាពទី១៩៖ អាំងត្រីជាអាហារពេលកំពុងសម្រាកក្នុងព្រៃបោះតង់[89]



[88] youthsmovement.com

[89] youthsmovement.com

រូបភាពទី២០៖ បោះតង់ស្រូបខ្យល់អាកាសបរិសុទ្ធ និងមើលទេសភាពពេលរាត្រីនៅភ្នំម្រេចកង្កែប[90]



[90] https://www.popular.com.kh/tours/128814.html/

សេវាកម្មទាំងអស់នេះគឺសុទ្ធសឹងតែជាសេវាកម្មដែលសំខាន់ៗ និងមិនអាចខ្វះបានរបស់ភ្ញៀវទេសចរម្នាក់ៗ ចំពោះសេវាកម្មស្នាក់នៅការបោះតង់គឺមានភាពលេចធ្លោជាងគេដោយសារការបោះតង់វាផ្តល់នូវភាពងាយស្រួបរិយាកាសថ្មីប្លែក ធម្មជាតិ ងាយស្រួលក្នុងការបោះនៅកន្លែងស្អាតៗ លើភ្នំឬតំបន់នានាដែលមានទេសភាពស្អាតៗ មានភ្នក់ភ្លើង និងសេវាកម្មម្ហូបអាហារចេញពីចុងភៅភូមិ ឬភ្ញៀវទេសចរអាចចម្អិនដោយខ្លួនឯងបាន[91] ។ សម្រាប់អ្នកនាំផ្លូវភ្ញៀវវិញ ឬ មគ្គុទេសក៍ទេសចរ គឺទទួលបានការងារច្រើននិងចំណូលច្រើនជាប្រចាំព្រោះថាភ្ញៀវទេសចរម្នាក់ៗមិនអាចស្គាល់ផ្លូវនិងទីតាំភូមិសាស្ត្រ ច្បាស់នៅតំបន់កម្សាន្តនីមួយៗ ឬក្នុងព្រៃនោះទេ ដូច្នេះ ការងារជាអ្នកនាំផ្លូវគឺទទួលបានកម្រៃខ្ពស់[92]។

### ២.៥.៣ តំបន់កម្សាន្ត

តំបន់អារ៉ែងមានកន្លែងទេសចរណ៍ជាច្រើនហើយបែងចែកជា ៣ប្រភេទធំៗគឺ[93] ៖ ទេសចរណ៍ធម្មជាតិ ទេសចរណ៍វប្បធម៌ក្នុងតំបន់ជនជាតិភាគតិចផង និងទេសចរណ៍ប្រវត្តិសាស្ត្រ។ អារ៉ែងសម្បូរទៅដោយសក្តានុពលទេសចរណ៍ធម្មជាតិល្អឯកមានគោលដៅទេសចរណ៍ជាង៦០កន្លែង[94] ។ កន្លែងដើរលេងសំខាន់ៗនៅក្នុងតំបន់អារ៉ែងមានដូចជា៖ ទឹកធ្លាក់ឆាយអារ៉ែង (ឆាយតាហ៊ីង) ទឹកធ្លាក់ឆាយតាប៉ាង ទឹកធ្លាក់ឆាយយោង ជម្រកត្រីនាគ ភ្នំម្រេចកង្កែប អូរពោធិ៍ប្រាំបួនតំបន់ពាងក្រឡបុរាណ តំបន់ពាង៧០ឬភ្នំពើងនិងម្ឈូសបុរាណ តំបន់ដើរផ្សងព្រេង ( Trekking) តំបន់មើលថ្ងៃលិច តំបន់ជនជាតិភាគតិច ស្ទឹងអារ៉ែង និងថ្មចេតីយ៍ ។

រូបភាពទី២១៖ ទឹកជ្រោះឆាយយោង[95]




[91] https://www.popular.com.kh/tours/123459.html/

[92] areng-valley.org

[93] https://khmertomorrow.com/areng-koh-kong-biodiversity-sanctuary-kh/

[94] https://visitcambodia.travel/kh/

[95] https://www.popular.com.kh/tours/


ទឹកជ្រោះតាយយោង
តំបន់អាប៉ែង
Hout Chamnab
Photography


ទឹកជ្រោះតាយយោង
តំបន់អាប៉ែង
Hout Chamnab
Photography

រូបភាពទី២២៖ ទឹកធ្លាក់ឆាយតាប៉ាង[96]




រូបភាពទី២៣៖ ជម្រកត្រីនាគ[97]



[96] https://www.youtube.com/watch?v=K_43HD2jLNg

[97] https://www.postkhmer.com/

### ២.៥.៤ សកម្មភាពភ្ញៀវទេសចរ

ការផ្តល់ជូននូវដំណើរផ្សងព្រេងនានាសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែងមានការផ្តល់ជូននូវសកម្មភាពទេសចរណ៍ជាច្រើនសម្រាប់អ្នកធ្វើដំណើរកម្សាន្តជាមួយទេសភាពធម្មជាតិតាមជួរភ្នំក្រវាញ។ជាមួយនឹងជម្រើសដូចជា ថ្មើរជើង ជិះកង់ ឬជិះម៉ូតូ ហើយមាន រយៈពេលចាប់ពី ២-៣ ម៉ោង រហូតដល់ច្រើនថ្ងៃ សហគមន៍ផ្តល់នូវជម្រើសជាច្រើនដើម្បីឱ្យភ្ញៀវទទួលបានបទពិសោធន៍នានាដែលមានតាមកន្លែងកម្សាន្ត។ បុគ្គលិកដែលមានចំណេះដឹងខ្ពស់ នឹងជួយអ្នកក្នុងការជ្រើសរើសនូវសកម្មភាពដែលល្អបំផុត ហើយមគ្គុទេសក៍ដែលមានបទពិសោធន៍ ហ៊ានធានាថាអ្នកនឹងទទួលបានការកម្សាន្តអស់ពីលទ្ធភាព[98]។

ចំណាំ៖ តម្លៃទាំងអស់គិតជា ដុល្លារអាមេរិក

**ដើរព្រៃ៖**

- ដើរព្រៃទៅក្បាលទូក ១ថ្ងៃ
- ដើរព្រៃទៅភ្នំម្រេចកង្កែប ១ថ្ងៃ
- ដើរព្រៃទៅត្រពាំងបបុសតូច ១ ថ្ងៃ
- ដើរព្រៃទៅឆាយទឹកប្រាក ១ ថ្ងៃ
- ដើរព្រៃទៅទីតាំងក្រឡបញ្ចុះសាកសព ២ ថ្ងៃ ១ យប់
- ដើរព្រៃទៅស្ទឹងដា ១ ថ្ងៃ
- ដើរព្រៃទៅវាលទ័ពឃ្លៃ ១ ថ្ងៃ
- ដើរព្រៃទៅឆាយបែកផ្សេង ២ ថ្ងៃ ១ យប់
- ដើរព្រៃទៅទឹកធ្លាក់ឆាយត្រពាំង ២ ថ្ងៃ ១ យប់
- ដើរព្រៃទៅសមុទ្រឈើម្រេចកង្កែប
- ដើរព្រៃទៅឆាយយោង ២ ថ្ងៃ ១ យប់

**ជិះកង់តាមផ្លូវភ្នំ**

- ជិះកង់ និងដើរព្រៃទៅម្រេចកង្កែប ២ ថ្ងៃ ១ យប់
- ជិះកង់ និងដើរព្រៃទៅត្រពាំងបបុសតូច ១ ថ្ងៃ
- ជិះកង់ និងដើរព្រៃទៅទីតាំងក្រឡបញ្ចុះសាកសព ២ ថ្ងៃ ១ យប់
- ជិះកង់ទៅឆាយទឹកប្រាក ១ ថ្ងៃ
- ជិះកង់ទៅខ្នងក្រពើ ៤ ថ្ងៃ ៣ យប់
- ជិះកង់ទៅឆាយយោង ២ ថ្ងៃ ១ យប់

[98] http://areng-valley.org/kh/get-involved

- ជិះកង់ទៅ វូងជនាង ៣ ថ្ងៃ ២ យប់

**ម៉ូតូ**

- ជិះម៉ូតូ និងដើរព្រៃទៅខ្ទងសេកប្រណាំង ៥ ថ្ងៃ ៤ យប់
- ជិះម៉ូតូ និងដើរព្រៃទៅឆាយស្វ ១ យប់
- ជិះម៉ូតូ ទៅពាមច្រវែក ២ ថ្ងៃ ១ យប់

**មគ្គុទេសក៍** ដែលមកពីសហគមន៍មូលដ្ឋាន ហើយពួកគាត់ស្គាល់ស្ថានភាពក្នុងព្រៃជាងអ្នកណាទាំងអស់ ។ ពីមុនពួកគាត់ជាអ្នកបរបាញ់សត្វ និងកាប់ព្រៃឈើប៉ុន្តែបច្ចុប្បន្នពួកគាត់ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងកិច្ចការងារអភិរក្ស និងចែករំលែកចំណេះដឹងដែលគាត់មានជាមួយនឹងភ្ញៀវទេសចរ។ មគ្គុទេសក៍មួយចំនួនអាចនិយាយភាសាអង់គ្លេសបានហើយពួកគាត់ទាំងអស់គ្នាសុទ្ធសឹងជាអ្នកជំនាញដើរព្រៃ និងអាចធានាថាអ្នកនឹងទទួលបាននូវបទពិសោធន៍ដែលមិនអាចបំភ្លេចបានពេលមកកម្សាន្តនៅកន្លែងធម្មជាតិដ៏អស្ចារ្យនេះ[99]។

**ឧបករណ៍ផ្សេងៗ** ដែលមានគុណភាពខ្ពស់ត្រូវបានផ្តល់ជូនសម្រាប់រាល់សកម្មភាពដំណើរកម្សាន្ត។ កញ្ចប់ដំណើរកម្សាន្តដើរព្រៃមានផ្តល់ជូននូវ កាបូបស្ពាយ អង្រឹង ភួយ កៅអីយឺត និងអាវភ្លៀងសម្រាប់ភ្ញៀវទេសចរម្នាក់ៗ ។ កញ្ចប់ដំណើរកម្សាន្តបោះតង់ ផ្តល់ជូននូវ តង់ ភួយ ខ្នើយ បង្គន់ចល័ត បន្ទប់ទឹក និងអំពូលសូឡា។ តំបន់អារ៉ែងជាតំបន់ធម្មជាតិខៀវស្រងាត់ដែលអាចឱ្យអ្នកទស្សនាទាំងអស់មានភាពរីករាយអារម្មណ៍ស្រស់ថ្លា និងមិនអាចបំភ្លេចបានជាមួយសកម្មភាពទេសចរណ៍ផ្សេងៗដូចជា[100]៖ ជិះទូកកម្សាន្ត ស្ទូចត្រី ថតរូបអនុស្សាវរីយ៍, ដាក់ម៉ុងនេសាទត្រីធម្មជាតិនិងចាប់ក្តាម, អាំងត្រីសាច់ គ្រឿងសមុទ្រ, បោះតង់លើភ្នំ, បោះតង់លើឆ្នេរខ្សាច់, ជិះទូកកាយ៉ាក, ទស្សនាទឹកធ្លាក់ស្រូបខ្យល់ត្រជាក់និងធម្មជាតិ, ដើរព្រៃ និងឡើងចុះភ្នំ, ងូតទឹកជ្រោះ, ដុតភ្នក់ភ្លើង, ទស្សនាពាងបុរាណ, ទស្សនារូងភ្នំបុរាណ, ទស្សនារបាំប្រពៃណីជនជាតិភាគតិច, ទស្សនាសត្វព្រៃ ត្រីនាគ និងក្រពើភ្នំ, មើលឆាយពពកពេលព្រឹក, ស្រូបខ្យល់អាកាសធម្មជាតិលាយឡំជាមួយនិងទឹកសន្សើម និងបោះតង់នៅមាត់អូរ។

[99] areng-valley.org

[100] https://visitcambodia.travel/kh/

រូបភាពទី២៣៖ រូបភាពផ្សេងៗទាក់ទងនិងសកម្មភាពដំណើរកម្សាន្តជាមួយទេសភាពធម្មជាតិតាមជួរភ្នំក្រវាញ[101]



[101] https://visitcambodia.travel/kh/







## ២.៦ ហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈនានា

ទោះបីជាតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងសំបូរទៅដោយធនធានធម្មជាតិដែលត្រូវចិត្តនឹងអ្នកទេសចរក៏ពិតមែនប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធពុំទាន់មានភាពសំបូរបែបនៅឡើយទេ។

- ការធ្វើដំណើរទៅកាន់សហគមន៍អារ៉ែងគឺមានផលវិបាកខ្លាំង ព្រោះតំបន់នេះមិនទាន់មានស្ពាន ផ្លូវថ្នល់ស្រួលនោះទេក្នុងការធ្វើដំណើរ
- ការធ្វើដំណើរពីតំបន់កម្សាន្តមួយទៅតំបន់មួយត្រូវប្រើម៉ូតូ ឬជិះទូករបស់អ្នកភូមិ
- យើងអាចជួលម៉ូតូឬទូករបស់អ្នកភូមិជិះខ្លួនឯងបាន

## ២.៧ ការអភិវឌ្ឍទេសចរណ៍បានផ្តល់ផលប៉ះពាល់វិជ្ជមាន

ជាទូទៅរាល់ការអភិវឌ្ឍទេសចរណ៍នៅលើពិភពលោកគឺត្រូវបានធ្វើឡើងដើម្បីទាញយកនូវផលប្រយោជន៍តាមរយៈច្រើនរូបភាពដែលគេរំពឹងចង់បានដូចជាផលចំណេញពីការអភិវឌ្ឍទេសចរណ៍ ដែលតែងតែចង់បានផលចំណេញផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម និងផ្នែកវប្បធម៌[102]។ល។ មនុស្សជាច្រើន និងប្រទេសជាច្រើនយល់ថាវិស័យទេសចរណ៍នាំមកនូវផលប្រយោជន៍ និងគុណសម្បត្តិជាច្រើនដល់សង្គមជាតិ។ តាមទស្សនៈនេះ ការអភិវឌ្ឍទេសចរណ៍គឺជាអាទិភាព។ សកម្មភាពទេសចរណ៍ ពិតជាបានជះឥទ្ធិពលទៅលើប្រជាពលរដ្ឋម្ចាស់ស្រុកពិសេសគឺផ្នែកសេដ្ឋកិច្ច។ ឥទ្ធិពលនេះបានរាលដាលយ៉ាងលឿនហើយថែមទាំងបានជួយទ្រទ្រង់ដល់ផ្នែកសេដ្ឋកិច្ចពិតមែន។ ជាក់ស្តែងវិស័យទេសចរណ៍ដែលត្រូវបានអភិវឌ្ឍន៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងពិតជាមានកាលានុវត្តភាព និងសក្តានុពលនាំផលប្រយោជន៍ជាច្រើនដល់តំបន់អារ៉ែងដែលត្រូវបានជំរុញអភិវឌ្ឍ។ ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍នេះបានបង្ហាញឱ្យឃើញដូចជា៖ ១-សេដ្ឋកិច្ច ២-បរិស្ថាន ៣-វប្បធម៌ និង ៤-សង្គម។

### ២.៧.១ ផលប៉ះពាល់វិជ្ជមានចំពោះសេដ្ឋកិច្ច

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានផលប៉ះពាល់ជាវិជ្ជមានចំពោះសេដ្ឋកិច្ច បានផ្តល់ផលប្រយោជន៍ដោយផ្ទាល់ និងប្រយោល ពីព្រោះការអភិវឌ្ឍនេះបានរកប្រាក់ចំណូលជូនជាតិ និងធ្វើឱ្យប្រសើរឡើងដល់ហេដ្ឋារចនាសម្ព័ន្ធនៃសេវាកម្មផ្សេងៗ[103] ដូចជា សេវាកម្មស្នាក់នៅ សេវាកម្មដឹកជញ្ជូន សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ សេវាកម្មលំហែកម្សាន្ត។ល។ ជាក់ស្តែង ទេសចរណ៍ជាវិស័យមួយនៅក្នុងចំណោមវិស័យអាទិភាពនៃសេដ្ឋកិច្ច។ ដូច្នេះ ការអភិវឌ្ឍទេសចរណ៍ជាកត្តាចាំបាច់ព្រោះវាអាចនាំមកនូវចំណូលជូនសហគមន៍អេកូទេសចរណ៍អារ៉ែងជាទូទៅពីរពាន់ដុល្លារក្នុងមួយខែៗ។ ចំណូលនេះបានរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ

[102] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១២១

[103] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១២២

របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានផ្ទាល់។ វិស័យទេសចរណ៍បានចូលរួមចំណែកក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ដោយស្រូបយកនូវចំណូលរូបិយវត្ថុបរទេស។ ការរីកចម្រើននៃវិស័យទេសចរណ៍ និងការបង្កើនការងារដល់ប្រជាជន ជាពិសេសប្រជាជនដែលរស់នៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង ពិតជាបានរួមចំណែកកាត់បន្ថយនូវភាពគ្មានការងារធ្វើថែមទាំងបានជួយថែរក្សាមរតកប្រពៃណីវប្បធម៌សង្គម និងបូរណៈភាពទឹកដីព្រមទាំងជួយជំរុញឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង និងឈានទៅអភិវឌ្ឍសង្គមជាតិទាំងមូល[104]។ ជាពិសេស គឺការផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋដោះស្រាយវិបត្តិសេដ្ឋកិច្ច និងសង្គមយ៉ាងមានប្រសិទ្ធភាព។ ការប៉ាន់ស្មានលើការចំណាយរបស់ទេសចរនៅក្នុងប្រទេសដែលពួកគេបានមកសហគមន៍អេកូទេសចរណ៍អារ៉ែងដូចជាចំណាយលើការស្នាក់នៅចំណាយទៅលើការដឹកជញ្ជូន ចំណាយលើម្ហូបអាហារ និងភេសជ្ជៈចំណាយលើទំនិញប្រើប្រាស់វត្ថុអនុស្សាវរីយ៍ និងចំណាយលើការកម្សាន្ត និងចំណាយផ្សេងៗតាមការចាំបាច់ពិតជាមានផលប៉ះពាល់ជាវិជ្ជមានចំពោះសេដ្ឋកិច្ចនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងពិតមែន ។

### ២.៧.២ ផលប៉ះពាល់វិជ្ជមានចំពោះបរិស្ថាន

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានផលប៉ះពាល់ជាវិជ្ជមានចំពោះបរិស្ថាន ពីព្រោះកាអភិវឌ្ឍនេះពិតជាបាននឹងរួមចំណែកដល់ការ ការពារ គាំពារ អភិរក្ស និងថែរក្សាបរិស្ថានធម្មជាតិនិងវប្បធម៌[105]។ ការរៀបចំបរិស្ថានសង្គមឱ្យមានរបៀបរៀបរយនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងបានផ្លាស់ប្តូរបទពិសោធពីរបៀបរស់នៅស្អាត និងអនាម័យល្អជំរុញឱ្យមានការរៀបចំសេវាកម្មនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងឱ្យកាន់តែប្រសើរធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងកាកសំណល់ និងបង្កើនការយល់ដឹងផ្នែកបរិស្ថាន និងអេកូឡូស៊ី។ ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនេះផ្ទាល់ អាចបង្កឱ្យមានលទ្ធភាពទាក់ទាញទេសចរឱ្យមានចិត្តចង់ស្គាល់តំបន់អារ៉ែងដែលជាតំបន់ការពារពោរពេញទៅដោយទេសភាពដែលមានលក្ខណៈជាធម្មជាតិនិងសំបូរទៅដោយធនធានទាក់ទាញសំខាន់ៗជាច្រើននៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ លើសពីនេះផងដែរ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនេះផ្ទាល់អាចជួយយ៉ាងខ្លាំងដល់ការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន ខ្យល់ ទឹក និងប្រភេទ ផ្សេងៗនៃការបំពុលពិសេសភាពកខ្វក់ និងខ្វះអនាម័យ។ ការថែរក្សាបរិស្ថានឱ្យស្អាតស្អំ និងមានគុណភាពស្រស់ត្រកាលអាចជួយជំរុញឱ្យសហគមន៍អេកូទេសចរណ៍អារ៉ែងមានតម្រូវការលើការទស្សនាភាពល្អត្រកាលទាំងនេះ។

[104] សួន វ៉ានី និងហុង វណ្ណៈ និរន្តភាពនៃការអភិវឌ្ឍទេសចរណ៍ ភ្នំពេញ ២០១២ ទំព័រ៥៣

[105] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១២២

### ២.៧.៣ ផលប៉ះពាល់វិជ្ជមានចំពោះវប្បធម៌

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់វិជ្ជមានចំពោះវប្បធម៌ ពីព្រោះការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនេះពិតជាបានរួមចំណែកដល់ការការពារគាំពារ អភិរក្ស និងថែរក្សានូវវប្បធម៌ ប្រវត្តិសាស្ត្រដូចជាម្លូសបុរាណនៅតំបន់ពាង៧០ឬភ្នំពើង និងទ្រព្យសម្បត្តិដែលជាបេតិកភណ្ឌជាតិធនធានវប្បធម៌ជាសកម្មភាពផ្សេងទៀតលើកទឹកចិត្តដល់ការសម្តែងសិល្បៈនិងរបាំធ្វើឱ្យប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋនៅក្នុងតំបន់មូលដ្ឋានផ្ទាល់មានការយល់ពីតម្លៃនៃវប្បធម៌ជាតិ ការខិតខំថែរក្សាឱ្យបាននូវអត្តសញ្ញាណជាតិ និងការផ្លាស់ប្តូរវប្បធម៌រវាងទេសចរ និងម្ចាស់ស្រុក[106]។

### ២.៧.៤ ផលប៉ះពាល់វិជ្ជមានចំពោះសង្គម

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់ជាវិជ្ជមានចំពោះសង្គមក៏ដូចជានៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនេះផងដែរ ពីព្រោះវានាំឱ្យមានការថែរក្សាប្រពៃណីទំនៀមទម្លាប់សាសនានៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ឬរបាំ តន្ត្រី ល្ខោន សំលៀកបំពាក់ ប្រពៃណី ទំនៀមទម្លាប់ សិប្បកម្ម បុណ្យទានកេរដំណែលសម្រាប់ភាពទាក់ទាញដល់ទេសចរដែលចង់មកលេងនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ ទន្ទឹមគ្នានេះផងដែរ ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនាំឱ្យមានការគាំពារ និងកែលម្អមូលដ្ឋានវប្បធម៌នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង និងប្រើប្រាស់ចំណូលពីទេសចរណ៍សម្រាប់ប្រយោជន៍សង្គមជារួមដូចជា ការពង្រឹងសហគមន៍មូលដ្ឋាន ការពង្រីកសេវាកម្មដែលពលរដ្ឋនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងអាចប្រើប្រាស់ដោយផ្ទាល់ និងមានការសាងសង់សាលារៀន មន្ទីរពេទ្យ ហេដ្ឋារចនាសម្ព័ន្ធនានា។ ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងអាចជួយឱ្យមានកំណើនឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងប្រជាពលរដ្ឋស្ញើច សរសើរ គោរព និងបង្កើនការស្រឡាញ់វប្បធម៌ ទំនៀមទម្លាប់សាសនា និងមរតកដូនតាដែលបានទុកឱ្យកូនចៅជំនាន់ក្រោយ។ ម្យ៉ាងវិញទៀត ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់ជា វិជ្ជមានចំពោះសង្គមក៏ដូចជានៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងជាច្រើនថែមទៀតដូចជា ការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់សហគមន៍ ការចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍និងសង្គម, ការបំបាត់ភាពអត់ការងារធ្វើនៅក្នុងសង្គម ការអភិវឌ្ឍនូវមូលដ្ឋានសម្ភារៈ និងសម្បទាទេសចរណ៍បំបាត់ភាពអផ្សុក និងបង្កើតសុខុមាលភាពជូនមនុស្សបង្កើតការគោរពរាប់អាន និងការយោគយល់គ្នា ការផ្តល់ពិសោធពីស្ថានភាព និងការរស់នៅរបស់មនុស្ស ថែរក្សា និងពង្រីកសណ្តាប់ធ្នាប់សង្គម ការជួយផ្តល់នូវស្ថេរភាពនយោបាយ និងសន្តិសុខសង្គមពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិអន្តរជាតិ និងការអភិវឌ្ឍធនធានមនុស្ស។ ឆ្លងតាមការបកស្រាយខាងលើ ឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍ពិតជាមានផល

[106] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១២៥

ប៉ះពាល់ជាវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម។ ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងទទួលបានលទ្ធផលជាវិជ្ជមាននេះ គឺជាការខិតខំប្រឹងប្រែងពីសំណាក់ដៃគូអភិវឌ្ឍន៍គ្រប់លំដាប់ថ្នាក់ និងមានការចូលរួមអភិវឌ្ឍន៍ពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឬសហគមន៍មូលដ្ឋានដែលបានយកចិត្តទុកដាក់ និងធ្វើទៅតាមផែនការអភិវឌ្ឍជាមួយគ្នា។ នៅក្នុងគោលការណ៍អភិវឌ្ឍសហគមន៍អេកូទេសចរណ៍អារ៉ែងនេះ គឺជាការធ្វើយ៉ាងណាឱ្យមានផលប៉ះពាល់ជាវិជ្ជមានចំពោះ សេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គមឱ្យឡើងដល់កម្រិតអតិបរិមា។

## ២.៨ ការអភិវឌ្ឍទេសចរណ៍បានផ្តល់ផលប៉ះពាល់អវិជ្ជមាន

បន្ទាប់ពីមានការយល់ដឹងពីឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់ជាវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម។ ពេលនេះយើងធ្វើការសិក្សាពីឥទ្ធិពលនៃការអភិវឌ្ឍទេសចរណ៍មានផលប៉ះពាល់ជាអវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម ដែលត្រូវបានបង្ហាញឃើញជាផលប៉ះពាល់ជាអវិជ្ជមានដូចជា[107] ១-សេដ្ឋកិច្ច ២-បរិស្ថាន ៣-វប្បធម៌ និង ៤-សង្គម។

### ២.៨.១ ផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ច

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានផលប៉ះពាល់ជាអវិជ្ជមានចំពោះសេដ្ឋកិច្ចពីព្រោះមានការខាតបង់ប្រាក់ចំណេញសេដ្ឋកិច្ច ឬការផ្លុះផ្លាយសេដ្ឋកិច្ចដែលបង្កឡើងដោយសារការវិនិយោគទុនបរទេស១០០% និងដោយសារការលើកទឹកចិត្តដល់វិនិយោគិនតាមរូបភាពផ្សេងៗ។ ការខាតបង់ប្រាក់ចំណេញសេដ្ឋកិច្ចឬការផ្លុះផ្លាយសេដ្ឋកិច្ចដោយសាររាល់ទំនិញ បរិក្ខារ សម្ភារៈនិងរបស់របរប្រើប្រាស់ផ្សេងៗជាច្រើន អាចមានទាំងបន្លែ ត្រី និងសាច់ផង ដែលត្រូវប្រើប្រាស់នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនូវមិនទាន់មានគ្រប់គ្រាន់ដូចនេះហើយនាំឱ្យជាកម្លាំងតូចមួយក្នុងកម្លាំងទូទាំងប្រទេសជំរុញឱ្យមានការនាំចូលមកពីបរទេស[108]។ ការបាត់បង់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងរដ្ឋាភិបាលដោយសារការប្រែប្រួលនៃបរិមាណទេសចរដែលមកដល់ទៅតាមរដូវទេសចរតិច និងរដូវទេសចរច្រើន។ ផលចំណេញសេដ្ឋកិច្ចដែលទទួលបានពីការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងតែងតែពុំបានបែងចែកឱ្យបានគ្រប់ទិសទីដោយសារតែមានការអភិវឌ្ឍតែតំបន់១ តំបន់២ ឬតំបន់៣ ដោយពុំបានគិតពីការរៀបចំធ្វើការអភិវឌ្ឍនៅតំបន់ផ្សេងទៀត[109]។ ក្នុងតំបន់អភិវឌ្ឍន៍សហគមន៍អេកូទេសចរណ៍អារ៉ែងជាទូទៅតែងតែមាន អតិផរណាចំពោះតម្លៃដីធ្លី តម្លៃទំនិញ និងសេវាកម្មទេសចរណ៍មួយចំនួនទៀត។ ទន្ទឹមគ្នានេះដែរ ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានឥទ្ធិពលចំពោះសេដ្ឋកិច្ចជាអវិជ្ជមានដោយសារតែការផ្តល់ឱកាសការងារ និងការលើកទឹកចិត្តច្រើនពេកដល់ជនបរទេសមកបម្រើការងារ ដោយមានទាំងអ្នកជំនាញចាំបាច់ និងមិនចាំបាច់ដែលចូលមកក្នុងតំបន់អភិវឌ្ឍន៍។

---

[107] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១២៨

[108] សួន វ៉ានី និងហុង វណ្ណៈ និរន្តភាពនៃការអភិវឌ្ឍទេសចរណ៍ ភ្នំពេញ ២០១២ ទំព័រ៨៥

[109] សួន វ៉ានី និងហុង វណ្ណៈ និរន្តភាពនៃការអភិវឌ្ឍទេសចរណ៍ ភ្នំពេញ ២០១២ ទំព័រ៨៥

### ២.៨.២ ផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាន

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះបរិស្ថានពីព្រោះក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងមិនមានការគ្រប់គ្រងដិតដល់ដូចជា ការចោលសំរាមគ្មានបន្ទប់អនាម័យដោយសារតែគ្មានមធ្យោបាយ និងការគិតគូរត្រឹមត្រូវ។ ភាពខ្វះអនាម័យ ការរស់នៅ ការទទួលទានអាហារ និងសកម្មភាពផ្សេងៗនាំឱ្យមានការបំពុលបរិយាកាស ទឹក និងកើនឡើងនូវកាកសំណល់រឹងរាវ។

### ២.៨.៣ ផលប៉ះពាល់អវិជ្ជមានចំពោះវប្បធម៌

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះវប្បធម៌ពីព្រោះនៅពេលបរិមាណទេសចរចូលមកទស្សនាមានច្រើននោះអាចធ្វើឱ្យម្ចាស់ស្រុកឬសហគមន៍មានទង្វើមិនសមរម្យទៅលើពួកគេ។ កត្តាហេតុនេះ បានធ្វើឱ្យមានការធុញទ្រាន់ និងជិនណាយ។ មានភាពរិចរិលនូវអាហារដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ និងវត្ថុបុរាណសំខាន់ៗនានាដែលបង្កឡើងមកពីការប្រើប្រាស់កម្រិតការទស្សនាលើសកម្រិត និងការប៉ះពាល់ផ្សេងៗ។ យុវវ័យងាយនឹងត្រងត្រាប់តាមនូវទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ អាកប្បកិរិយា និងលក្ខណៈផ្សេងទៀតនៃវប្បធម៌បរទេស ដែលធ្វើឱ្យប្រាសចាកពីវប្បធម៌នៅក្នុងតំបន់។ ការបំផ្លិចបំផ្លាញធនធានធម្មជាតិដែលជាភាពទាក់ទាញហើយបែរជាយកទីតាំងនោះសម្រាប់សាងសង់សំណង់ថ្មីៗ ដែលបម្រើឱ្យវិស័យទេសចរណ៍ ឬបម្រើក្នុងផ្នែកផ្សេងទៀត ។

### ២.៨.៤ ផលប៉ះពាល់អវិជ្ជមានចំពោះសង្គម

ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះសង្គមក៏ដូចជានៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងផ្ទាល់ពីព្រោះមានការកើតឧក្រិដ្ឋកម្មផ្សេងៗ ដូចជាការលួច និងការឆបោកនិងការក្លែងបន្លំ។ រឿងសំខាន់មួយទៀតគឺការកើតមានឆ្លងជំងឺសង្គមផ្សេងៗ ពិសេសជំងឺកូវីដ-១៩[110]។ល។ សរុបសេចក្តីមក ឥទ្ធិពលនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ពិតជាមានផលប៉ះពាល់ជាអវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម។ ទោះជាយ៉ាងណាក៏ដោយការអភិវឌ្ឍទេសចរណ៍ជាទូទៅមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម ប៉ុន្តែភាគីពាក់ព័ន្ធអភិវឌ្ឍចាំបាច់ធ្វើសកម្មភាពយ៉ាងណាចំពោះការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងឱ្យមានផលប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា។ ការគិតពីផលប៉ះពាល់អវិជ្ជមានចំពោះសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម គឺមានអត្ថប្រយោជន៍ សម្រាប់រក្សាបានការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងប្រកបដោយនិរន្តរភាព។

[110] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១៣២

## ២.៩ យុទ្ធសាស្ត្រគ្រប់គ្រងអំពីផលប៉ះពាល់លើការអភិវឌ្ឍអេកូទេសចរណ៍អារ៉ែង

ដោយយោងតាមបទពិសោធ និងការអង្កេតតាមដានឃើញថាផលប៉ះពាល់អវិជ្ជមាននៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមួយចំនួនភាគច្រើនបានកើតមានឡើងនៅតំបន់និងទីកន្លែងជាច្រើនដែលពុំមាន ឬមានតិចតួចនូវការធ្វើផែនការកម្ម ឬធ្វើការគ្រប់គ្រងឱ្យបានជាក់លាក់នោះទេ។ ហេតុនេះហើយទើបរាល់ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងដែលនិយាយដល់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងគុណភាពនៅក្នុងសហគមន៍នេះបានបង្កើតជាយុទ្ធសាស្ត្រនៃផែនការសម្រាប់ការគ្រប់គ្រងដើម្បីជួយសម្រាលឥទ្ធិពលអវិជ្ជមានដែលបណ្តាលពីទេសចរណ៍ឱ្យនៅមានកម្រិតអប្បបរមា និងជំរុញឱ្យមានឥទ្ធិពលវិជ្ជមានដល់កម្រិតអតិបរមានឹងបង្ហាញអំពីយុទ្ធសាស្ត្រសង្ខេបសំខាន់ៗមួយចំនួនសម្រាប់គ្រប់គ្រងផលប៉ះពាល់។

### ២.៩.១ ការគ្រប់គ្រងផលប៉ះពាល់នៃការអភិវឌ្ឍទេសចរណ៍

ការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាននៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងអាចនឹងផ្តល់ផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន។ នៅពេលការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនេះត្រូវបានធ្វើឡើងដោយមានសិក្សាថ្លឹងថ្លែង ពិចារណា និងមានការរៀបចំត្រឹមត្រូវ និងបង្កើតឱ្យមានផលប៉ះពាល់វិជ្ជមាន។ ផ្ទុយទៅវិញបើសិនជានៅក្នុងសហគមន៍ត្រូវបានគេខិតខំអភិវឌ្ឍន៍តែតាមទីផ្សារ និងតម្រូវការដោយមិនមានចំណេះដឹងត្រឹមត្រូវ នឹងបង្កើតឱ្យមានផលប៉ះពាល់អវិជ្ជមាន មានន័យថាការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង នឹងមិនធានាបាននូវនិរន្តរភាពឡើយ។ ដូច្នេះ ការគ្រប់គ្រងបានល្អពីផលប៉ះពាល់អវិជ្ជមាននៅក្នុងដំណើរនៃការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍អារ៉ែង នឹងជួយឱ្យសម្រេចបាននូវគោលបំណងស្តីពីនិរន្តរភាពពិតប្រាកដ។ ការងារអាទិភាពក្នុងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាននៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងដូចជា[111]

ការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន ការគ្រប់គ្រងផលប៉ះពាល់សេដ្ឋកិច្ច និងការគ្រប់គ្រងផលប៉ះពាល់សង្គម និងវប្បធម៌។

ការគ្រប់គ្រងបរិស្ថាន គឺជាវិធានការមួយចាំបាច់ ដែលអាចចាត់ទុកថាជាការបង្កើតផែនការការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងត្រូវផ្អែកលើទស្សនៈនានាដោយទប់ស្កាត់ឱ្យបានការកាប់ព្រៃឈើហួសហេតុការរក្សាលំនឹងបរិស្ថាន និងបន្ថយការខូចខាតបរិស្ថានហាមប្រើប្រាស់ព្រៃព្រឹក្សា និងធម្មជាតិខ្លាំងហួសហេតុមានវិធានការជាក់លាក់ដើម្បីរក្សាបរិស្ថានធម្មជាតិ។ ទន្ទឹមគ្នានេះផងដែរសហគមន៍អេកូទេសចរណ៍អារ៉ែងក៏បានបង្កើតឱ្យមានប្រព័ន្ធផ្គត់ផ្គង់គ្រប់គ្រងក្នុងតំបន់អភិវឌ្ឍន៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងបង្កើតឱ្យមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ការប្រមូលកាកសំណល់ និងប្រព័ន្ធចាក់ចោលគរនូវកាកសំណល់។ លើសពីនេះទៅទៀតក៏មានការអភិវឌ្ឍផ្លូវថ្នល់ និងប្រព័ន្ធដឹកជញ្ជូនឱ្យបានសមស្រប ជាក់ស្តែងដើម្បីរក្សាសោភណ្ឌភាព

[111] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១២៨

នៅក្នុងសហគមន៍ និងធ្វើផែនការប្រើប្រាស់ដីធ្លីក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងកំណត់ទីតាំងដីសមស្របសម្រាប់សំណង់ទេសចរណ៍ ។

ការគ្រប់គ្រងផលប៉ះពាល់នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ត្រូវបានប្រើប្រាស់បទដ្ឋានអភិវឌ្ឍឱ្យបានសមស្របល្អសម្រាប់សំណង់ទេសចរណ៍ដូចជាបឹងកាឡូសំណង់ត្រូវឆ្លុះបញ្ចាំងធម្មជាតិបៃតងផ្សារជាប់និងបេះដូងអ្នកអភិរក្ស និងបរិស្ថានជាតិគ្រប់គ្រងដោយប្រុងប្រយ័ត្នការប្រើប្រាស់ធនធានគ្រប់គ្រង និងគ្រប់គ្រងជម្រកសត្វព្រៃតំបន់ការពារគ្រប់គ្រងការចោលសំរាមនៅក្នុងសហគមន៍ អប់រំប្រជាពលរដ្ឋឱ្យចេះរក្សាអនាម័យដោយដាក់សំរាមទៅក្នុងធុងសំរាមនៅកន្លែងនានា។ វិធានការចុងក្រោយសម្រាប់បរិស្ថាន គឺជាការទប់ស្កាត់ការបំផ្លាញសត្វព្រៃ ជីវិត និងរុក្ខជាតិកម្រ ការគ្រប់គ្រងឱ្យមាននិរន្តភាពនៃធនធានព្រៃឈើ ការទប់ស្កាត់ការកាប់ព្រៃឈើនៅក្នុងតំបន់ការពារ ថែរក្សាសុខភាពប្រជាជននិងទេសចរ បង្កើតយន្តការអនុវត្តន៍ច្បាប់បរិស្ថាន។ បន្ថែមមួយទៀតរដ្ឋបាលទេសចរណ៍និងរដ្ឋបាលបរិស្ថានបានដើរតួនាទីដ៏សំខាន់ដើម្បីបង្កើតបែបបទសម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថាននៅគ្រប់ដំណើរការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងទាំងអស់ ពិសេសគឺបណ្តាទីតាំងសេវាកម្ម និងទីកន្លែងកម្សាន្តផ្សេងទៀតនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងផងដែរ ។

ការគ្រប់គ្រងផលប៉ះពាល់សេដ្ឋកិច្ចនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានមធ្យោបាយជាច្រើនដែលត្រូវប្រើប្រាស់ជាកម្លាំងចលករនៃកំណើនសេដ្ឋកិច្ចនៅក្នុងសហគមន៍ផ្ទាល់ទៅលើសេដ្ឋកិច្ចដោយមធ្យោបាយអាទិភាពមួយចំនួន និងពិសេសមានការបង្កើតនូវយន្តការដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅតំបន់អភិវឌ្ឍសហ-គមន៍អេកូទេសចរណ៍អារ៉ែង តាមរយៈវិស័យទេសចរណ៍ដូចជាការបង្កើតកញ្ចប់ដំណើរកម្សាន្ត និងរៀបចំប្រជាជនក្នុងតំបន់ជាសហគមន៍ដើម្បីទទួលទេសចរដូចជា ចុងភៅ និងអ្នកនាំភ្ញៀវទេសចរចូលព្រៃជាដើម។ ការគ្រប់គ្រងផលប៉ះពាល់សេដ្ឋកិច្ច គឺជាការធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងក្លាយជាកម្លាំងចលករពិតៗ សម្រាប់ជំរុញការរីកចម្រើននូវសេដ្ឋកិច្ចនៅក្នុងតំបន់។ មធ្យោបាយទាំងអស់នោះរួមមានដូចជាការជំរុញពង្រឹងទិដ្ឋភាពទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ដើម្បីឱ្យមានការស្នាក់នៅយូរនិងចំណាយខ្ពស់។ ទេសចរណ៍មានគុណភាព ភាគច្រើនអាចផ្តល់ការចំណេញដល់ផ្នែកវប្បធម៌ និងធ្វើឱ្យបរិស្ថានមានលក្ខណៈល្អប្រសើរឡើង។ ការជំរុញឱ្យទេសចរស្នាក់នៅសហគមន៍អេកូទេសចរណ៍អារ៉ែងយូរតាមរយៈការផ្តល់នូវការទាក់ទាញអារម្មណ៍ទេសចរឱ្យបានច្រើនឡើងស្របជាមួយការជំរុញពង្រីកសេវាកម្មទាំងបរិមាណនិងគុណភាព និងបង្កើនប្រសិទ្ធភាពសេវាកម្មផ្សេងៗនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ។

ដាក់ស្តែងការបង្កើនការផ្តល់ឱកាសកាន់តែច្រើនថែមទៀតដល់ទេសចរដើម្បីចំណាយប្រាក់កាន់តែច្រើនទៀតតាមរយៈការអភិវឌ្ឍ សហគមន៍អេកូទេសចរណ៍អារ៉ែង ការពង្រីកបរិមាណផលិតផលទំនិញសិប្បកម្មដែលមានគុណភាពល្អ បង្កើនការដាក់លក់ទំនិញទេសចរណ៍ សិប្បកម្ម វត្ថុអនុស្សាវរីយ៍ រួមទាំងការអភិវឌ្ឍទីផ្សារផលិតផលសិប្បកម្មនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ ការបង្កើនឱ្យមានការលើកទឹកចិត្តដើម្បីឱ្យមាន

ការប្រើប្រាស់ផលិតផលនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងដោយមានការបង្កើតផលិលផលកសិកម្មឱ្យមានគុណភាពខ្ពស់។

ការគ្រប់គ្រងផលប៉ះពាល់សេដ្ឋកិច្ចគឺជាការជំរុញឱ្យមានការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងដើម្បីចែកចាយផលចំណេញសេដ្ឋកិច្ចទៅកាន់សហគមន៍អេកូទេសចរណ៍អារ៉ែងនៅក្នុងតំបន់ទាំងមូលឱ្យប្រជាពលរដ្ឋមានជីវភាពល្អប្រសើរ ដោយពង្រីកទីផ្សារទេសចរណ៍ និងបង្កើនការទាក់ទាញឱ្យទេសចរស្នាក់នៅយូរ និងបង្កើតកញ្ចប់ដំណើរកម្សាន្តនានានៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងក្នុងគោលបំណងបម្រើភ្ញៀវទេសចរឱ្យមកហើយចង់មកទៀត។ ផងដែរនោះបង្កើនការអភិវឌ្ឍ និងកែលម្អសម្បទាទេសចរណ៍នានា ដើម្បីទាក់ទាញទេសចរណ៍អាជីវកម្មផ្សេងទៀត។ ការថែរក្សាគោលនយោបាយជំរុញលើតម្លៃទេសចរណ៍នៅក្នុងសហ-គមន៍អេកូទេសចរណ៍អារ៉ែង ដើម្បីរក្សាការងារធ្វើជាអតិបរមាដល់ប្រជាពលរដ្ឋ រួមទាំងបង្កើនការគ្រប់គ្រងឱ្យបានល្អតាមរយៈគោលនយោបាយបុគ្គលិក និងការបណ្តុះបណ្តាលឱ្យទទួលបានគុណភាព។ ជាក់ស្តែង ការលើកទឹកចិត្តសហគមន៍អារ៉ែង ឱ្យជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍទេសចរណ៍ក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងរបស់ពួកគាត់ ដើម្បីបង្កលទ្ធភាពសម្រាប់ពួកគាត់ទទួលបាននូវផលចំណេញសេដ្ឋកិច្ចផ្ទាល់ ឬប្រយោល។

ការគ្រប់គ្រងផលប៉ះពាល់សង្គម និងវប្បធម៌ចាំបាច់រក្សាឱ្យបាននូវប្រពៃណីទំនៀមទម្លាប់ដូចជា របាំ និងល្ខោន ព្រមទាំងសិល្បៈ និងសិប្បកម្មដែលមានលក្ខណៈជាតិ ដើម្បីឱ្យទិដ្ឋភាពនៃមរតកវប្បធម៌បម្រើការទាក់ទាញដ៏សំខាន់សម្រាប់ទេសចរ ដោយមិនអាចធ្វើឱ្យខូចខាតដល់វិស័យទេសចរណ៍ឡើយ។ កម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដើម្បីធានាឱ្យបានភាពបរិសុទ្ធ។ ទីតាំងបុរាណវិទ្យា និងប្រវត្តិសាស្ត្រត្រូវបានថែរក្សាឱ្យបានសមស្រប និងត្រូវបានបកស្រាយនិងពន្យល់ខ្លឹមសារទៅឱ្យទេសចរទទួលបានចំណេះដឹង។ ទេសចរអាចប្រើប្រាស់ទីតាំងអស់នេះដោយទទួលផលតាមបំណងប្រាថ្នា តែមិនបានធ្វើឱ្យមានការខូចខាតធនធានទាំងនេះឡើយ។

ការគ្រប់គ្រងផលប៉ះពាល់សង្គម និងវប្បធម៌ចាំបាច់ធានាឱ្យបានផលចំណេញនៃទេសចរណ៍បានទៅដល់ដៃប្រជាជននៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងរួមមានទាំងការបណ្តុះបណ្តាល និងអប់រំប្រជាជនឱ្យចេះធ្វើការងារយ៉ាងមានប្រសិទ្ធភាពក្នុងវិស័យទេសចរណ៍ និងផ្តល់អាទិភាពការងារដល់ពួកគេជាមុនប្រសិនបើគេបានបណ្តុះណ្តាលសមស្រប។ ការគ្រប់គ្រងនេះជំរុញឱ្យប្រើប្រាស់ទំនិញ និងសម្ភារៈដែលផលិតនៅក្នុងស្រុកដោយជំរុញបង្កើតផលិតផលទៅតាមស្តង់ដារ និងធានារ៉ាប់រងគុណភាពសម្រាប់ការបម្រើសេវាកម្មនានាដល់ទេសចរណ៍ព្រោះវាផ្តល់ជំនួយដល់ប្រជាជនក្នុងការបង្កើនបរិមាណ និងគុណភាពផលិតកម្ម។ តាមរយៈបច្ចេកទេសម៉ាឃីតធីង មានការទាក់ទាញប្រភេទទេសចរណ៍ដែលគោរពមរតកវប្បធម៌និងប្រពៃណីនៅតំបន់ទេសចរណ៍។

ការគ្រប់គ្រងផលប៉ះពាល់សង្គម និងវប្បធម៌ជាកត្តាចាំបាច់បង្កើតឱ្យមានការអប់រំ និងមានការណែនាំប្រជាពលរដ្ឋនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងឱ្យយល់ពីតម្លៃទេសចរណ៍ ទស្សនៈរបស់ទេសចរណ៍ និងទទួលផលចំណេញពីវិស័យនេះមកវិញ។ ការពង្រឹងនិងពង្រីកគោលនយោបាយផែនការជំរុញអភិវឌ្ឍនៅក្នុង

សហគមន៍អេកូទេសចរណ៍អារ៉ែង និងវិធានការអនុវត្តទេសចរណ៍ជាមូលដ្ឋានដ៏សំខាន់ដើម្បីបង្កលទ្ធភាពឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងសកម្មភាពទេសចរណ៍ និងព្រឹត្តិការណ៍ថ្មីៗនៃទេសចរណ៍។

ការគ្រប់គ្រងផលប៉ះពាល់សង្គម និងវប្បធម៌មានតួនាទីដ៏សំខាន់ដើម្បីផ្សព្វផ្សាយព័ត៌មានដល់ទេសចរអំពីទំនៀមទម្លាប់ ប្រពៃណី សំលៀកបំពាក់អាកប្បកិរិយា និងគោលនយោបាយនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងស្តីអំពី ការថតរូប ការឱ្យរង្វាន់លើកទឹកចិត្ត ព័ត៌មានអំពីសក្តានុពលទេសចរណ៍ និងអំពីច្បាប់ទម្លាប់នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ មានការគ្រប់គ្រងឧក្រិដ្ឋកម្មដែលតម្រង់ទៅកជនបរទេសនិងទេសចរ ដោយមានការផ្តល់ព័ត៌មានដល់ទេសចរ អំពីវិធានការការពារខ្លួននៅពេលពួកគេធ្វើដំណើរ។

### ២.៩.២ ការគ្រប់គ្រងផលប៉ះពាល់ដើម្បីទទួលបាននិរន្តរភាព

ការគ្រប់គ្រងផលប៉ះពាល់ដើម្បីទទួលបាននិរន្តរភាព មានកត្តាជាប់ពាក់ព័ន្ធមួយចំនួនដូចជា ការអភិវឌ្ឍធនធានមនុស្ស ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល ការពង្រីកគោលដៅទាក់ទាញទេសចរណ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងទេសចរ ការអប់រំបណ្តុះស្មារតី និងការតម្រង់ទិសអ្នកពាក់ព័ន្ធ។

និរន្តរភាពពីការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងបានពឹងផ្អែកលើមនុស្សដែលជាធនធានដ៏មានតម្លៃ និងជាកម្លាំងដ៏សំខាន់ដែលអាចជួយផ្តល់នូវមធ្យោបាយដ៏ត្រឹមត្រូវសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍនៅក្នុងសហគមន៍ ដោយធ្វើឱ្យសហគមន៍អេកូទេសចរណ៍អារ៉ែងមួយនេះ មានគុណភាព និងធ្វើឱ្យប្រាកដពីភូមិសាស្ត្រ និងផលប្រយោជន៍នៃការប្រកួតប្រជែងជាលក្ខណៈតំបន់។

ការអភិវឌ្ឍធនធានមនុស្សពិតជាមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងប្រកបដោយនិរន្តភាព។ គ្មានការអភិវឌ្ឍណាមួយនឹងទទួលបានផលល្អនោះឡើយ ប្រសិនបើមិនមានធនធានមនុស្សគ្រប់គ្រាន់ សម្រាប់ធ្វើការងារគ្រប់យ៉ាងដែលត្រូវការមិនអាចខ្វះបាននៅក្នុងដំណើរការណ៍ និងការប្រព្រឹត្តទៅនៃការអភិវឌ្ឍ។ នេះចង់បញ្ជាក់ថា ការរៀបចំគោលនយោបាយ ការរៀបចំផែនការ ការកំណត់ស្តង់ដារបរិស្ថាន និងប្រព័ន្ធវាយតម្លៃបរិស្ថាន ការរៀបចំច្បាប់ បទបញ្ញត្តិ គោលការណ៍ណែនាំ ការគ្រប់គ្រងការអភិវឌ្ឍផលិតផល និងសម្បទាទេសចរណ៍ ការគ្រប់គ្រងទេសចរ ការគ្រប់គ្រងធនធានទេសចរណ៍ ការរៀបចំប្រព័ន្ធគ្រប់គ្រងការចេញលិខិតអនុញ្ញាត និងអាជ្ញាបណ្ណទេសចរណ៍ ការគ្រប់គ្រងអាជីវកម្ម ការគ្រប់គ្រងផលប៉ះពាល់ទេសចរណ៍ ការគ្រប់គ្រងការងារអភិវឌ្ឍ ការតាមដានត្រួតពិនិត្យ។ល។ និងមិនអាចប្រព្រឹត្តទៅបាននោះឡើយ ប្រសិនបើពុំមានធនធានមនុស្សគ្រប់គ្រាន់ ឬមនុស្សដែលមានសមត្ថភាពពេញលេញ ក្នុងការធ្វើការងារទាំងឡាយនោះប្រកបដោយគុណភាព និងចំណេះដឹងគ្រប់គ្រាន់។ នេះគឺបញ្ជាក់ថា ហេតុនេះការអភិវឌ្ឍធនធានមនុស្សនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង គឺជាការងារអាទិភាពមួយទៀតដែលទាមទារនូវធនធានមនុស្សជាតម្រូវការចាំបាច់ ដើម្បីជួយឱ្យការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងទទួលបាននិរន្តភាព។ ថាការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងបានដោយនិរន្តភាព។

និរន្តរភាពពីការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងពិតជាត្រូវការបង្កើតផែនការប្រើប្រាស់ធនធានមនុស្ស ដែលបញ្ជាក់ច្បាស់លាស់ពីតម្រូវការលើធនធានមនុស្សគ្រប់កម្រិតទាំងសម្រាប់ឧស្សាហកម្មទេសចរណ៍ដែលបុគ្គលិក និយោជិក និងប្រតិបត្តិករទេសចរណ៍ និងសម្រាប់វិស័យទេសចរណ៍ជារួមដូចជា ផ្នែករដ្ឋបាលនិងការគ្រប់គ្រងទេសចរណ៍ ផ្នែកគោលនយោបាយ និងផែនការអភិវឌ្ឍទេសចរណ៍ ផ្នែកទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ ផ្នែកច្បាប់ និងកែទម្រង់ទេសចរណ៍។ល។ ការខ្វះខាតធនធានមនុស្ស និងសមត្ថភាពមន្ត្រីគ្រប់ជាន់ថ្នាក់ដែលកំពុងបម្រើការក្នុងរដ្ឋបាលទេសចរណ៍សាធារណៈ គឺជារឿងធំមួយដែលមានឥទ្ធិពលអវិជ្ជមានដល់ការដឹកនាំ ការចាត់ចែង និងការគ្រប់គ្រង ដោយតម្លាភាពដែលមិនអាចធានាបាននូវគុណភាពប្រសិទ្ធភាព និងនិរន្តរភាពសម្រាប់វិស័យទេសចរណ៍ឡើយ។ អតីតកាលបានបន្សល់ទុកនូវបញ្ហាបច្ចុប្បន្នកាលមិនបានគិតគូរឱ្យហ្មត់ចត់ និងធ្វើការកែទម្រង់បញ្ហាប្រឈមនិងការលំបាកនានា។ ការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលទេសចរណ៍ក្នុងគោលបំណងទ្រទ្រង់ដល់ការគ្រប់គ្រងការអភិវឌ្ឍវិស័យទេសចរណ៍ និងជួយតម្រែតម្រង់កំណែទម្រង់ឧស្សាហកម្មទេសចរណ៍។

ការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលទេសចរណ៍ គឺជាយុទ្ធសាស្ត្រអាទិភាពមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង ដឹកនាំនិងអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងដោយធានាឱ្យមានការរីកចម្រើន និងធានាគុណភាពប្រកួតប្រជែង។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង គឺជាយុទ្ធសាស្ត្រអាទិភាពមួយមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍អារ៉ែងនិងផ្តល់កាលានុវត្តភាពសម្រាប់ការរៀបចំប្រើប្រាស់ប្រែក្លាយសក្តានុពលធនធានទេសចរណ៍ដ៏សម្បូរបែបឱ្យក្លាយជាផលិតផលទេសចរណ៍ថ្មីៗបង្កើនការគាំទ្រផលិតផលបានអភិវឌ្ឍរួចហើយ និងផ្តល់កាលានុវត្តភាពសម្រាប់ជម្រើសនៃការទស្សនាព្រមទាំងការពង្រីកសកម្មភាពទេសចរណ៍ឱ្យកាន់តែទូលំទូលាយនិងច្រើនថែមទៀត។ ហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករូបវន្ត និងផ្នែកអរូបវន្ត មានន័យថាជីវិតនិងសេដ្ឋកិច្ចមានដង្ហើម។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់និងស្ពាន ការផលិតថាមពលអគ្គិសនី និងបណ្តាយចែកចាយទឹកស្អាតប្រព័ន្ធធារាសាស្ត្រជាដើម។

ការគ្រប់គ្រងទេសចរ ជាអាទិភាពមួយទៀតដែលត្រូវធ្វើឡើងដើម្បីជួយទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃទេសចរណ៍ និងជួយឱ្យការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងធានាបាននិរន្តភាព។ ទេសចរ គឺជាអ្នកប្រើប្រាស់ផលិតទេសចរណ៍ ទេសចរជាអ្នកដែលចូលមកកម្សាន្ត និងធ្វើសកម្មភាពទេសចរណ៍នៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងមួយនេះ។ ប្រសិនបើគ្មានទេសចរទេសកម្មភាពនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងក៏ពុំអាចកើតមានដែរ ហើយអ្វីៗទាំងអស់ក៏មិនអាចមានសកម្មភាពនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងបានដែរ។ ដូច្នេះនៅពេលទេសចរបានទៅទស្សនាកម្សាន្តនៅទីនេះពួកគាត់មានតួនាទីសំខាន់ណាស់ក្នុងការធ្វើឱ្យតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងមួយនេះឱ្យមាននិរន្តរភាព។

ភាពពេញចិត្តដែលទេសចរទទួលបានពីសកម្មភាពរបស់ពួកគាត់ក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង ជាផ្នែកមួយដែលធ្វើឱ្យការអភិវឌ្ឍមាននិរន្តភាព។ ម្យ៉ាងវិញទៀត ប្រសិនបើទេសចរពុំបានយល់ដឹងពីសារៈសំខាន់នៃអ្វីៗនៅក្នុងតំបន់កម្សាន្តនោះទេពួកគាត់អាចធ្វើទង្វើខុសឆ្គងផ្សេងៗ ដែលជាបុព្វហេតុមួយធ្វើឱ្យតំបន់ទេសចរណ៍មានបញ្ហា និងទីបំផុតមានការបំផ្លាញអាចកើតមានឡើង។

ទេសចរមួយចំនួនចូលទៅតំបន់មួយនិងនាំដល់ការបំផ្លាញដល់របៀបរបបរស់នៅ ប្រពៃណី ទំនៀមទម្លាប់របស់ម្ចាស់ស្រុក ហើយខ្លះទៀតបានធ្វើឱ្យបរិស្ថាននៅតំបន់ធម្មជាតិអារ៉ែងមួយមានការបំផ្លាញសោភណ្ឌភាពដោយការបេះបោចដំណាំ រុក្ខជាតិ បំភ័យដល់ជីវិតរស់នៅរបស់សត្វព្រៃ ការពង្រាយកាកសំណល់នៅក្នុងកន្លែងកម្សាន្ត ឬក្នុងទឹកជាដើម ដែលអាចធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីមានភាពប្រែប្រួល។ល។ ដូច្នេះ ការគ្រប់គ្រងទេសចរ គឺជាផ្នែកមួយដ៏មានសារៈសំខាន់ ដែលជួយឱ្យតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងមានស្ថេរភាព មានបរិស្ថានល្អ និងមានការពេញចិត្តពីទេសចរគ្រប់រូប។ ការគ្រប់គ្រងទេសចរអនុញ្ញាតឱ្យពួកគេយល់និងចូលរួមជាមួយម្ចាស់ស្រុក និងប្រតិបត្តិការគម្រោងអភិវឌ្ឍន៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងទាំងអស់ក្នុងការធានានិរន្តភាព និងនាំឱ្យទទួលបានប្រជាប្រិយភាពទីផ្សារកើនឡើង ហើយអាចទទួលបាននិរន្តភាពពិតពីការអភិវឌ្ឍ។

ការអប់រំបណ្តុះគំនិតស្មារតីដល់មនុស្សនានាឱ្យយល់ពីសកម្មភាពទេសចរណ៍ និងអប់រំអ្នករស់នៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងទាំងឡាយពិតជាមានសារៈសំខាន់ណាស់ ពិសេសក្នុងការទទួលបាននិរន្តភាពពីការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ បុគ្គលិក និយោជិក និងម្ចាស់អាជីវកម្មទាំងឡាយអាចផ្តល់ព័ត៌មានយ៉ាងជាក់លាក់ជូនទេសចរអំពីសកម្មភាពផ្សេងៗ ដែលមានឥទ្ធិពលដល់ការធ្វើឱ្យប្រសើរឡើងនូវបរិស្ថាន និងជាមធ្យោបាយជួយដល់ការកាត់បន្ថយផលប៉ះពាល់ទាំងអស់ឱ្យនៅតិចបំផុត។ ការអប់រំបានទូលំទូលាយនូវចំណេះដឹងពិតប្រាកដ និងប្រកបដោយឆន្ទៈព្រមទាំងទេពកោសល្យផងនាំឱ្យមានការពាំនាំនិងបញ្ជូនព័ត៌មាន ដែលចាំបាច់ទៅដល់ទេសចរបាននិងទៅដល់មនុស្សទាំងឡាយដែលពាក់ព័ន្ធផង។ ការងារនេះថែមទាំងបានជួយមនុស្សទាំងអស់បានយល់ពីសារៈសំខាន់នៃការគាំពារការអភិវឌ្ឍ និងការចូលរួមគ្រប់សកម្មភាពដើម្បីការអភិវឌ្ឍ និងទទួលបាននិរន្តភាពនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។

ការអប់រំបណ្តុះគំនិតស្មារតី បានបង្កើតបាននូវគំនិតចាំបាច់មួយចំនួន ដូចជា ១-គុណភាពពិតជាតម្រូវការមិនអាចខ្វះបាន ២-គុណភាពពិតជាត្រូវបានគេការពារ និងជំរុញលើកទឹកចិត្តក្នុងការអភិវឌ្ឍទេសចរណ៍ និង ៣-ទំនាក់ទំនងនិងមិនអាចខ្វះបាននៃទេសចរណ៍ និងបរិស្ថាន វប្បធម៌ សង្គមនិង សេដ្ឋកិច្ច។ ជាមួយគ្នានេះផងដែរ ត្រូវបង្កើនប្រសិទ្ធភាពនិងការយល់ដឹងរបស់បុគ្គលិក និយោជិក ទេសចរម្ចាស់ស្រុក ប្រតិបត្តិករទេសចរណ៍ និងបណ្តាអ្នកមានការងារពាក់ព័ន្ធទាំងអស់អំពីគុណភាពនៃការបកប្រែដោយធ្វើឱ្យមានប្រសិទ្ធភាពក្នុងការងារអប់រំ និងផ្តល់គំនិតល្អសម្រាប់ទេសចណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង និងជំរុញទេសចរឱ្យផ្សារភ្ជាប់ទៅក្នុងឥរិយាបថ និរន្តភាពកាន់តែខ្លាំង ការអប់រំស្តីអំពីបរិស្ថាន និងការអភិវឌ្ឍច្បាប់សម្រាប់ផ្តល់ដំបូន្មានដល់ពួកគេ។

ការអភិវឌ្ឍទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងប្រព្រឹត្តទៅបានល្អ និងធានាមាននិរន្តភាពអាស្រ័យដោយមានការចូលរួមពីផ្នែកនានាជាច្រើន។ ការចូលរួមជាកត្តាសំខាន់បំផុតដើម្បីធ្វើឱ្យមានការអភិវឌ្ឍទទួលបាននិរន្តភាពស្ថិតស្ថេរគង់វង្ស និងមានតម្លៃទៅអនាគត។ អ្នកចូលរួមក្នុងការធ្វើឱ្យមាននិរន្តភាពចំពោះការអភិវឌ្ឍនេះ អាចជាការចូលរួមដោយផ្ទាល់ឬចូលរួមដោយប្រយោលពីបណ្តាលសមាសធាតុពាក់ព័ន្ធជាច្រើនដែលការចូលរួមទាំងអស់នេះ មានតួនាទីផ្សេងពីគ្នានិងរបៀបការអនុវត្តក៏ផ្សេងគ្នាដែរ។ អ្នកចូលរួមដែលជួយឱ្យមាននិរន្តភាពចំពោះការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងបានបែងចែកជា៥ក្រុមផ្សេងៗពីគ្នាដូចជា រដ្ឋាភិបាលនិងអាជ្ញាធរដែនដី ផ្នែកឯកជន អង្គការនិងសមាគម ការចូលរួមពីសហគមន៍មូលដ្ឋាន និងការអភិវឌ្ឍធនធានមនុស្ស។

រដ្ឋាភិបាលនិងអាជ្ញារធដែនដី គឺជាក្រុមដ៏សំខាន់ និងមានឥទ្ធិពលបំផុតចំពោះការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ រដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់នូវគោលនយោបាយ និងរៀបចំច្បាប់បទបញ្ញត្តិជួយតម្រង់ទិស និងតម្រែតម្រង់ការអភិវឌ្ឍ។ អាជ្ញាធរដែនដីជាសេនាធិការរបស់រដ្ឋាភិបាល ក៏ដូចជារដ្ឋាភិបាលថ្នាក់លើដែរ ដោយមានតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួល និងជំរុញរាល់គម្រោងវិនិយោគដែលមានក្នុងដែនដីសហគមន៍អេកូទេសចរណ៍អារ៉ែងឱ្យដំណើរការទៅបានល្អ។ ជាពិសេស មានការផ្តល់គោលនយោបាយណែនាំអំពីកន្លែងណាដែលគួរសាងសង់កន្លែងណាដែលគួរបង្កើតជាសកម្មភាពទេសចរណ៍ និងកន្លែងណាដែលត្រូវអភិរក្សទុកឱ្យបានល្អ។ អាជ្ញាធរដែនដី បានធ្វើការអប់រំ និងជំរុញប្រជាពលរដ្ឋឱ្យចូលរួមថែរក្សាការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ខ្លួន ចូលរួមក្នុងសកម្មភាពអភិវឌ្ឍ និងស្រូបយកប្រយោជន៍ពីទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងផងដែរ។ម្យ៉ាងទៀតអាជ្ញារធដែនដី ក៏មានតួនាទីរៀបចំសណ្តាប់ធ្នាប់ រក្សាសន្តិសុខ សុវត្ថិភាព និងបង្កើតសោភណ្ឌភាព ការការពារ និងអភិរក្សបរិស្ថាន ដោយធ្វើឱ្យមានបរិយាកាសល្អទាក់ទាញនៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងទាំងមូល។

ផ្នែកឯកជន ជាផ្នែកមួយនៃការអភិវឌ្ឍ ជាម្ចាស់គម្រោង ជាអ្នកវិនិយោគឬជាអ្នករកស៊ីក្នុងអាជីវកម្មទេសចរណ៍នៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង។ ផ្នែកឯកជនមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងអភិវឌ្ឍន៍ទៅមុខប្រកបដោយ និរន្តភាព ព្រោះអាជីវកម្មរបស់ពួកគេត្រូវការទាញយកផលយូរអង្វែងផងដែរ។ គម្រោងវិនិយោគឯកជនទាំងអស់ដោយធ្វើយ៉ាងណាអនុវត្តន៍គម្រោងកុំឱ្យបង្កនូវផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច វប្បធម៌ សង្គម និងបរិស្ថាននៅក្នុងតំបន់។ គម្រោងវិនិយោគរបស់ផ្នែកឯកជនមានដំណើរការទៅបានល្អជាមួយការទទួលបានផលចំណេញព្រមទាំងជៀសវាង និងកាត់បន្ថយឱ្យបានកម្រិតអប្បបរមានូវផលប៉ះពាល់អវិជ្ជមាន។ ផ្នែកឯកជនត្រូវបានគោរពនិងអនុវត្តន៍ឱ្យបានត្រឹមត្រូវទៅតាមគោលនយោបាយច្បាប់ និងការណែនាំរបស់រដ្ឋាភិបាល និងអាជ្ញាធរដែនដី។ មួយទៀត ផ្នែកឯកជនគឺមិនត្រូវលោភលន់ហួសកម្រិត

ដែលគិតតែផលចំណេញមានន័យថាត្រូវយល់ពីផលប្រយោជន៍នៃនិរន្តភាពនៃការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងគិតពីប្រជាពលរដ្ឋ និងគិតពីមាតុភូមិ។

អង្គការក្នុងនិងក្រៅរដ្ឋាភិបាល និងសមាគមជាតិជាច្រើនត្រូវបានគេបង្កើតឡើងដើម្បីធ្វើការគាំទ្រ និងអង្កេតពិនិត្យមើលលើបរិស្ថានធម្មជាតិវប្បធម៌ និងទៅលើសេដ្ឋកិច្ចនៅទូទាំងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង។ អង្គការមួយចំនួនបង្កើតឡើងជាអង្គការឯករាជ្យទទួលបន្ទុកឃ្លាំមើលសកម្មភាពទាំងអស់។ អង្គការនិងសមាគមន៍នានា មានតួនាទីសំខាន់ក្នុងការជួយផ្តល់យោបល់ធ្វើយ៉ាងណាមិនឱ្យផលប៉ះពាល់ផ្តល់គោលការណ៍ណែនាំអំពីបញ្ហានិរន្តភាពអវិជ្ជមានកើតមានច្រើននៅតំបន់ណាមួយ។ បណ្តាក្រុមអង្គការសមាគមន៍ជាច្រើនជាសមាសធាតុមួយក្នុងកិច្ចពិភាក្សាផ្តល់យោបល់ចំពោះការអភិវឌ្ឍថាតើគួរឱ្យអភិវឌ្ឍន៍ឬមិនគួរ និងក្រុមនេះមានតួយ៉ាងសំខាន់មួយដែរ ដែលរង់ចាំអង្កេតមើលសកម្មភាពរបស់ម្ចាស់គម្រោងដែលបានអនុវត្តន៍ និងធ្វើការទិតៀនកែលម្អ ចំពោះអ្វីដែលមិនសមហេតុផល និងធ្វើឱ្យមានផលប៉ះពាល់ចំពោះបរិស្ថានសង្គមវប្បធម៌ក៏ដូចជាទៅលើសេដ្ឋកិច្ចតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ Wild Alliance អាចពាក់ព័ន្ធទៅនឹងអង្គការបរិស្ថានជាតិ អន្តរជាតិ អង្គការ UNESCO អង្គការ UNDP អង្គការ DANIDA អង្គការ GLOBALWITHNESS Wild Aid ជាអង្គការឃ្លាំមើលសត្វព្រៃ និងសមាគមជាច្រើនទៀត។

ការចូលរួមពីសហគមន៍មូលដ្ឋាន ជាផ្នែកមួយមានឥទ្ធិពលយ៉ាងខ្លាំងចំពោះតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង។ ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែង គឺជាមនុស្សសំខាន់មិនអាចខ្វះបានក្នុងការជួយអភិរក្សបរិស្ថាន ការថែរក្សាបរិស្ថានវប្បធម៌ក្នុងតំបន់របស់ខ្លួន។ ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងនេះផ្ទាល់ក៏ជាអ្នកដែលអាចបំផ្លាញបរិស្ថាន សេដ្ឋកិច្ច និងវប្បធម៌ដែរ ប្រសិនបើពួកគាត់ពុំបានយល់អំពីតម្លៃរបស់ធនធានទាំងនោះ ដូចជាការកាប់ព្រៃ ការបរបាញ់សត្វ ការនេសាទខុសច្បាប់ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ប្រជាជននឹងជួយថែរក្សាអភិរក្សរាល់ធនធានទាំងអស់ក្នុងតំបន់ និងចូលរួមក្នុងការលើកតម្កើងសកម្មភាពទេសចរណ៍ដោយថែរក្សាប្រពៃណី វប្បធម៌ ទំនៀមទម្លាប់របស់ខ្លួនព្រមទាំងទទួលស្វាគមន៍ទេសចរ ដែលចូលមកទស្សនាកម្សាន្តនៅពេលដែលពួកគេទាំងអស់បានយល់ដឹងពីតម្លៃ និងអត្ថប្រយោជន៍របស់ទេសចរណ៍និងធនធានទាំងនេះក្នុងជីវិតរបស់ពួកគាត់។ មិនតែប៉ុណ្ណោះ ប្រសិនបើប្រជាពលរដ្ឋនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមិនទទួលយល់ព្រម ចំពោះគម្រោងអភិវឌ្ឍក្នុងតំបន់របស់គាត់ទេនោះគម្រោងនោះពុំអាចដំណើរការទៅបានទេ និងសកម្មភាពទេសចរណ៍ក៏ពុំអាចរីកចម្រើនបានឡើយ។

ការលើកកម្ពស់ការបែងចែកផលពីការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ត្រូវគិតពីផលប្រយោជន៍ដែលជារឿងសំខាន់។ មនុស្សទាំងអស់ដែលពាក់ព័ន្ធនិងការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងសុទ្ធតែចង់បានផលប្រយោជន៍ដូចៗគ្នា។ ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានដំណើរការទៅល្អនិងអាចធានាបាននូវនិរន្តភាពប្រសិនបើផលពីការអភិវឌ្ឍត្រូវបានគេបែងចែកឱ្យបានត្រឹមត្រូវ និងដោយ

សមធម៌។ ការទទួលបានផលប្រយោជន៍ដោយសមធម៌ នឹងធ្វើឱ្យមនុស្សដែលពាក់ព័ន្ធទាំងអស់ មានកម្លាំងចិត្ត បន្តធ្វើឱ្យកាន់តែល្អ និងកាន់តែប្រសើរឡើងនូវការងាររបស់ខ្លួន។ ផ្ទុយទៅវិញ បញ្ហានឹងកើតមានដោយរឿងមិនសុខចិត្តហើយនឹងអាចនាំដល់ការបំផ្លាញ ទោះជាដោយចេតនាក្តី ឬក៏ដោយអចេតនាក្តី នឹងកើតមានជាមួយការខឹងសម្បា ការតវ៉ា ការបាតុកម្ម ការប្រឆាំងការរំខានអាចនឹងកើតមានគ្រប់ពេល ប្រសិនបើផលប្រយោជន៍ពីការអភិវឌ្ឍមិនត្រូវបានបែងចែកបានត្រឹមត្រូវមានន័យថាមិនបានដោយសមធម៌ទេនោះ។

តម្លាភាពនៃការអនុញ្ញាត និងចេញអាជ្ញាបណ្ណ គឺជាអាទិភាពមួយទៀតក្នុងការធានាឱ្យមាននិរន្តភាពនូវការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ដែលយន្តការនៃការចេញលិខិតអនុញ្ញាតនិងការផ្តល់អាជ្ញាបណ្ណ។ ប្រព័ន្ធផ្តល់ការអនុញ្ញាតតាមរយៈការចេញច្បាប់អនុញ្ញាត ឬអាជ្ញាបណ្ណទាមទារឱ្យប្រតិបត្តិករទេសចរណ៍ ឬអ្នកអភិវឌ្ឍដាក់ពាក្យសុំការអនុញ្ញាត ក្នុងការបង្កើតសកម្មភាពជាក់លាក់នៅក្នុងតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងមួយនេះ។ ជាទូទៅដំណើរការនៃការដាក់ពាក្យសុំគឺទាមទារឱ្យមានប្រត្យក្សភាព ភាពត្រឹមត្រូវនូវរាល់សកម្មភាពដែលបានស្នើរសុំត្រូវបានធានាមិនមានផលប៉ះពាល់អវិជ្ជមានចំពោះបរិស្ថាននោះទេ។ ច្បាប់អនុញ្ញាតត្រូវមានកំណត់ និងកម្រិតមិនឱ្យមានច្រើនពេក។ ការចេញលិខិតអនុញ្ញាតអាចជាទម្រង់មួយដែលបានដាក់កាតព្វកិច្ចជាកិច្ចសន្យាជាមួយប្រតិបត្តិករទេសចរណ៍ និងក្នុងករណីគេយល់ព្រមទទួលនូវលក្ខខណ្ឌទាំងឡាយទើបចេញលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម។

គុណភាពការងារគ្រប់គ្រង និងការដឹកនាំជាមូលដ្ឋានមួយដ៏មានសារៈសំខាន់ក្នុងការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមួយប្រកបដោយនិរន្តរភាព។ ការងារគ្រប់គ្រងការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងនេះ គឺជាការងារអាទិភាព ដែលត្រូវគិតពីគុណភាព។ ប្រសិទ្ធភាពនៃការគ្រប់គ្រងការអភិវឌ្ឍ គឺត្រូវផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធការងារមូលដ្ឋានថ្នាក់ជាតិមួយ និងដែលរឹងមាំសម្រាប់ការអភិវឌ្ឍ ដើម្បីធានាឱ្យមាននិរន្តភាពដែលសមស្របទៅនឹងបណ្តាការងារ និងសកម្មភាពអនុវត្តនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង។ មានន័យថា មានតម្រូវការចាំបាច់នូវប្រព័ន្ធគ្រប់គ្រងស្ថាបនាការងារ និងមានការគិតគូរពីយន្តការអធិការកិច្ច ត្រួតពិនិត្យ តាមដានវាយតម្លៃ ការអនុវត្តបានត្រឹមត្រូវ ។

## ២.១០ យុទ្ធសាស្ត្រម៉ាឃីតធីង និងការអប់រំ

**១.ភាពសមរម្យ** យុទ្ធសាស្ត្រម៉ាឃីតធីងអាចជួយជំរុញដល់ការអភិវឌ្ឍនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងប្រកបដោយនិរន្តរភាព។ កត្តាសំខាន់បំផុតនៃយុទ្ធសាស្ត្រនេះ គឺការអភិវឌ្ឍផលិតផលឬទស្សនៈទានរបស់ទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង ដែលត្រូវគ្នាទៅនឹងធនធានបរិស្ថានដែលតំបន់សហគមន៍អេកូទេសចរណ៍អារ៉ែងអាចធ្វើទៅបាន។ អ្នកនាំភ្ញៀវទេសចរចូលព្រៃម្នាក់ជាអ្នកនាំភ្ញៀវទៅតំបន់មួយបានផ្ទុកនូវព័ត៌មានជាច្រើន ដែលបានបង្ហាញនូវការយល់ដឹងដល់ទេសចរយ៉ាងច្រើនស្តីអំពីបរិស្ថាន និងជំរុញឱ្យមានការរៀបចំសកម្មភាពទេសចរណ៍ជាច្រើនទៀត ដូចជា ចូលព្រៃមើលសក្តានុពលធម្មជាតិនិងវត្ថុបុរាណ។ ប្រការដ៏មាន

សារៈសំខាន់មួយផងដែរក្នុងការផ្តល់ព័ត៌មានពិតប្រាកដត្រឹមត្រូវអំពីបរិស្ថាននិងឥទ្ធិពលបរិស្ថានក្នុងកាផ្សព្វផ្សាយពាណិជ្ជកម្ម។

**២.ការអប់រំដល់បុគ្គលិក** ការអប់រំដល់បុគ្គលិកដែលបម្រើការងារក្នុងអាជីវកម្មទេសចរណ៍នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងក៏អាចផ្តល់នូវតម្លៃយ៉ាងសំខាន់សម្រាប់ការគ្រប់គ្រងផលប៉ះពាល់ផងដែរ។ ដើម្បីធ្វើការបកស្រាយបង្ហាញទេសចរ ការអប់រំបុគ្គលិកឱ្យផ្តល់ព័ត៌មានយ៉ាងជាក់លាក់អំពីសកម្មភាពផ្សេងៗ ដែលជាឥទ្ធិពលរបស់គេចំពោះបរិស្ថាន និងជាមធ្យោបាយដើម្បីធ្វើឱ្យផលប៉ះពាល់ទាំងអស់នេះមានកម្រិតអប្បបរមា ព្រោះថាព័ត៌មានគឺជាផ្នែកមួយដែលអាចជួយបុគ្គលិកនៅទីកន្លែងដែលគេធ្វើការ។ ការប្រើប្រាស់ច្បាប់បញ្ញត្តិ ដើម្បីធ្វើការអប់រំផ្តល់ដំបូន្មាន ឬអប់រំឥរិយាបថរបស់ទេសចរឱ្យងាកទៅរកបរិស្ថាន គឺជាយុទ្ធសាស្ត្រថ្មីដែលជាទម្រង់នៃការអប់រំដ៏មានប្រជាប្រិយភាពមួយសម្រាប់ទេសចរ ។

## ២.១១ ការអភិវឌ្ឍ អភិរក្ស ថែរក្សា ការពារតំបន់អេកូទេសចរណ៍

### ២.១១.១ ការអភិរក្ស

យើងបានដឹងស្រាប់ហើយថាអារ៉ែងជាតំបន់ព្រៃត្រូពិចមួយដែលសម្បូរទៅដោយធនធានធម្មជាតិ ព្រៃភ្នំ សត្វព្រៃគ្រប់ប្រភេទឬកម្រៗ និងតំបន់បុរាណឬប្រវត្តិសាស្ត្រនានា ដូច្នេះហើយប្រជាពលរដ្ឋនៅក្នុងសហគមន៍មន្ត្រីទេសចរណ៍ កងរាជអាវុធហត្ថ សកម្មជនបរិស្ថាន អាជ្ញាធរ ត្រូវតែរួមគ្នា ចូលរួមអភិរក្សឱ្យបាននូវៈ

- ព្រៃឈើ កុំឱ្យមានការកាប់ព្រៃឈើលក់ និងជួញដូរផ្សេងៗ
- ការពារឱ្យបាននូវសត្វព្រៃគ្រប់ប្រភេទ ជៀសវាងការបរបាញ់សត្វព្រៃគ្រប់ប្រភេទរបស់មនុស្សដោយខុសច្បាប់
- បង្កើនការយកចិត្តទុកដាក់ការពារបរិស្ថានកុំឱ្យប៉ះពាល់ដល់តំបន់សក្តានុពលធនធានធម្មជាតិផ្សេងៗទៀត
- ថែរក្សាឱ្យបាននូវតំបន់ប្រវត្តិសាស្ត្រឬបុរាណនានាដើម្បីទទួលភ្ញៀវទេសចរជាច្រើននាក់និងបង្ហាញឱ្យពិភពលោកឃើញពីតំបន់ស្អាតៗនិងអស្ចារ្យពីកម្ពុជា។

### ២.១១.២ ការអភិវឌ្ឍ

បច្ចុប្បន្ននេះរាជរដ្ឋាភិបាលមានគម្រោងក្នុងការស្ថាបនាផ្លូវថ្នល់ និងសាងសង់ស្ពានទៅកាន់តំបន់អារ៉ែងព្រោះយើងមើលឃើញស្រាប់ហើយថាសម្រាប់ការធ្វើដំណើរគឺមានផលវិបាកទើបទីនោះទទួលបានតែភ្ញៀវដែលចូលចិត្តផ្សងព្រេងហ៊ានប្រថុយនិងគ្រោះថ្នាក់ទើបអាចទៅដល់ទីនោះបាន។ ប្រសិនបើយើងមានផ្លូវថ្នល់ល្អស្រួលធ្វើដំណើរនិងឆ្លងកាត់មិនពិបាកប្រាកដណាស់នឹងមានភ្ញៀវទេសចរជាច្រើននាក់ច្រើនប្រភេទអាចទៅដល់ទីនោះបានយ៉ាងស្រួលនិងផ្តល់ជាចំណូលច្រើនទៅដល់ប្រជាជននៅក្នុងសហគមន៍ច្រើនទៀតផង។ សមាជិកសហគមន៍តំបន់អារ៉ែងនិងជនជាតិដើមភាគតិចក៏បានសាទរដល់គម្រោងអភិវឌ្ឍន៍ផ្លូវថ្នល់ស្ពានទៅកាន់តំបន់របស់ពួកគេផងដែរប៉ុន្តែទន្ទឹមនិងនេះការព្រួយបារម្ភរបស់សកម្មជនការពារបរិស្ថានតំបន់អារ៉ែងនិងប្រធានសហគមន៍ជនជាតិដើមភាគតិចទាំងមូលសុទ្ធតែមានការព្រួយបារម្ភពាក់ព័ន្ធជាមួយនិងបទល្មើសផ្សេងៗកើតមានក្នុងកំឡុង

ពេលសាងសង់ឬពេលសាងសង់រួច ដូចជាបទល្មើសព្រៃឈើ លំហូរចេញនូវគ្រឿងញៀន និងបទល្មើសចោរកម្ម នៅពេលដែលមានផ្លូវស្រួលឆ្លងកាត់ និងមានឈ្មួញទុច្ចរិតចូលមកវិនិយោគផ្សេងៗធ្វើឱ្យប៉ះពាល់តំបន់ធនធានធម្មជាតិជាច្រើនកន្លែងទាំងនេះគឺជាបញ្ហាដែលរាជរដ្ឋាភិបាលត្រូវតែមានវិធានការច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាមួយនេះដោយត្រឹមត្រូវនិងម៉ត់ចត់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់សហគមន៍អារ៉ែងទាំងមូល។

## ២.១២ កត្តាសំខាន់ដើម្បីទទួលនិរន្តភាព

កត្តាជាគន្លឹះសំខាន់ៗដើម្បីទទួលបាននិរន្តរភាព ដែលក្នុងនោះរួមមានទស្សនៈជាច្រើនបានលើកឡើងពីការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព។ ជាពិសេសការអភិវឌ្ឍនេះមានការធានាឱ្យបាននូវចំណេះដឹងចំណេះអនុវត្តពិតប្រាកដ មានគុណធម៌ អត្តចរិតល្អ មានកាយសម្បទារឹងមាំ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការងារ។ ទន្ទឹមគ្នានេះផងដែរអង្គការទេសចរណ៍ពិភពលោកបានបញ្ជាក់ពីការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពដែលតម្រូវឱ្យមានការត្រិះរិះពិចារណាឱ្យបានហ្មត់ចត់លើកត្តាជាគន្លឹះសំខាន់ៗ៨យ៉ាងដើម្បីទទួលបាននិរន្តរភាព នឹងត្រូវបានបង្ហាញដូចខាងក្រោម[112] ៖

១.អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិ សង្គម និងវប្បធម៌ប្រកបដោយនិរន្តរភាព។ មានន័យថា ការអភិវឌ្ឍទេសចរណ៍ទាមទារចាំបាច់ផែនការ និងការគ្រប់គ្រងត្រឹមត្រូវដោយមានការគិតគូរពីបញ្ហា និងព្រំដែននៃបរិស្ថានដើម្បីធានាបានការប្រើប្រាស់យូរអង្វែង និងមានតម្លៃចំពោះធនធានធម្មជាតិ និងមនុស្សក្នុងតំបន់។

២.ការធ្វើផែនការទេសចរណ៍ គឺជាការរៀបចំផែនការទេសចរណ៍ដើម្បីអភិវឌ្ឍនិងប្រតិបត្តិការ គួរតែបានធ្វើសមាហរណកម្មទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍដោយនិរន្តរភាពមូលដ្ឋាន និងថ្នាក់ជាតិ។ មួយទៀត គឺមានការពិចារណាអំពីការអភិវឌ្ឍផ្សេងៗ ពិសេសគឺការអភិវឌ្ឍសេដ្ឋកិច្ចដោយបញ្ហានេះទាក់ទងនឹងដីធ្លី ការប្រើប្រាស់ធនធានផ្សេងៗ ការជីករ៉ែ ការអភិវឌ្ឍថាមពល និងឧស្សាហកម្ម និងកត្តានានានៃវប្បធម៌សង្គម។

៣.ទេសចរណ៍ជាគន្លឹះនៃការគាំទ្រសកម្មភាពសេដ្ឋកិច្ច ដែលជាមូលដ្ឋានសម្រាប់ផ្តល់អត្ថប្រយោជន៍ និងផ្តល់ការចំណាយចំពោះបរិស្ថានប៉ុន្តែត្រូវជៀសវាងដោយមិនអនុញ្ញាតឱ្យសកម្មភាពសេដ្ឋកិច្ចមូលដ្ឋានព្រមទាំងកាចំណាយចំពោះបរិស្ថានទាំងនេះក្លាយជាសកម្មភាពដែលគ្រប់គ្រងសេដ្ឋកិច្ចនៅទូទាំងតំបន់ឡើយ។

៤.សហគមន៍មូលដ្ឋានគួរត្រូវបានលើកទឹកចិត្ត និងទទួលបានការគាំទ្រពីរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍ឱ្យមានការចូលរួមក្នុងការធ្វើផែនការក្នុងការអភិវឌ្ឍ និងការត្រួតពិនិត្យ។ ការចូលរួមជាពិសេសគួរជាពលរដ្ឋអន្តោគ្រាមដែលមានការពាក់ព័ន្ធស្ត្រី និងក្រុមជនជាតិភាគតិចដើម្បីធានាឱ្យច្បាស់លាស់ក្នុងការបែងចែកផលប្រយោជន៍ពីវិស័យទេសចរណ៍ប្រកបដោយសមធម៌។

[112] សៀវភៅការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព Sustainable Tourism Development and Planning, អ្នកនិពន្ធ បណ្ឌិត ឈឹមផាន់ណា, ទំព័រ១០៦

៥.គ្រប់អង្គភាព និងបុគ្គលទាំងអស់ដែលអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងទេសចរផងដែរ គួរតែគោរពវប្បធម៌ទំនៀមទម្លាប់ ប្រពៃណី និងសាសនា គោរពសេដ្ឋកិច្ច មធ្យោបាយរកចិញ្ចឹមជីវិត បរិស្ថាន និងរចនាសម្ព័ន្ធនយោបាយក្នុងតំបន់គោលដៅ។

៦.គ្រប់អ្នកពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ទាំងអស់ គួរសិក្សា និងទទួលបានការអប់រំអំពីភាពចាំបាច់ក្នុងទម្រង់នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ទាំងនេះ រួមមានការបណ្តុះបណ្តាល ការអប់រំតាមមធ្យោបាយនានា និងការធ្វើម៉ាឃីតធីងប្រកបដោយការទទួលខុសត្រូវ ដើម្បីបង្កើត និងបង្កើនការយល់ដឹងរបស់បុគ្គលិក និងសហគមន៍ជាក់ស្តែងព្រមទាំងទេសចរណ៍ដែរ។

៧.ការសិក្សាស្រាវជ្រាវ គួរអនុវត្តគ្រប់តំណាក់កាលអភិវឌ្ឍទេសចរណ៍និងកិច្ចប្រតិបត្តិការដើម្បីត្រួតពិនិត្យនូវផលប៉ះពាល់នានា ដោះស្រាយបញ្ហានានានិងអនុញ្ញាតឱ្យប្រជាពលរដ្ឋដទៃទៀត មានលទ្ធភាពឆ្លើយតបចំពោះការផ្លាស់ប្តូរនិងទទួលបានបន្តបន្ទាប់នូវឱកាសនានា។

៨.គ្រប់ភ្នាក់ងារ អង្គភាព ក្រុមហ៊ុន និងបុគ្គលទាំងអស់គួរសហប្រតិបត្តិការ និងធ្វើការរួមគ្នាដើម្បីជៀសវាងជម្លោះ និងសុទិដ្ឋិនិយមចំពោះបណ្តាអត្ថប្រយោជន៍នានា ដែលអ្នកពាក់ព័ន្ធទាំងអស់ទទួលបានពីការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យទេសចរណ៍។

សរុបសេចក្តីមកកត្តាជាគន្លឹះសំខាន់ៗ៨យ៉ាងដើម្បីទទួលបាននិរន្តភាពបានដើរតួនាទីដ៏មានសាសំខាន់នៅក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តភាពពីព្រោះវាទាំងឡាយជាមូលដ្ឋានគ្រឹះ ឬជាគំរូសម្រាប់ភាគីពាក់ព័ន្ធអភិវឌ្ឍន៍ត្រូវគោរព និងអនុវត្តតាម។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព មិនមែនជាការងាយស្រួលដើម្បីសម្រេចឱ្យបានតាមគោលបំណងរបស់ខ្លួននោះទេ ប្រសិនបើដៃគូអភិវឌ្ឍមិនបានគិតគូមិនបានថ្លឹងថ្លែងបានត្រឹមត្រូវ និងមិនមានផែនការច្បាស់លាស់។ ទន្ទឹមគ្នានេះផងដែរ ដោយឆ្លងតាមការសិក្សា និងស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ និងជាពិសេស ការសិក្សាស្រាវជ្រាវសរសេរសៀវភៅជាច្រើនក្បាលលោកសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី បានរកឃើញគំនិតថ្មីៗល្អមួយចំនួនមានលក្ខណៈវិទ្យាសាស្ត្រពិតប្រាកដ និងសមស្របសម្រាប់ការអនុវត្តផង។ របកគំហើញនោះ គឺមាគ៌ាអនុវត្ត ៦ យ៉ាង ដើម្បីជួយឱ្យការអភិវឌ្ឍទេសចរណ៍ទទួលបាននិរន្តភាព។ ១-តម្រូវការគោលនយោបាយ, ២-តម្រូវការផែនការអភិវឌ្ឍ ៣-ស្តងដារ និងប្រព័ន្ធវាយតម្លៃបរិស្ថាន ៤- គ្រប់គ្រងដោយច្បាប់ និងបទបញ្ញត្តិ ៥-គ្រប់គ្រងការអភិវឌ្ឍផលិតផលនិងសម្បទា ៦- គ្រប់គ្រងធនធាន។

# ជំពូកទី៣
# ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍផលិតផលសហគមន៍អារ៉ែង

យើងបានដឹងស្រាប់ហើយថាក្នុងបច្ចុប្បន្ននេះ ប្រជាជនខ្មែរភាគច្រើនងាកមកចាប់អារម្មណ៍ដំណើរកម្សាន្តបែបផ្សងព្រេង ដើរព្រៃ បោះតង់ទៅកាន់តំបន់ធម្មជាតិគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា។ នេះជាផ្លែផ្កាមួយដែលអាចឱ្យសហគមន៍យើងទទួលបានភ្ញៀវទេសចរជាច្រើននាក់និងពីគ្រប់មជ្ឈដ្ឋានទាំងជាតិនិងអន្តរជាតិ។ ជាក់ស្តែងសហគមន៍យើងទទួលបានភ្ញៀវទេសចរជាច្រើននាក់គ្រប់រដូវកាលនិងរៀងរាល់សប្តាហ៍ប៉ុន្តែរាល់បញ្ហាខ្វះខាតនានាតែងកើតមានឡើងកំឡុងពេលទទួលភ្ញៀវទេសចរ ដូច្នេះទាំងនេះជាផែនការយុទ្ធសាស្ត្របន្ថែមដើម្បីធ្វើការអភិវឌ្ឍន៍ កែប្រែ ជួលជុល ពង្រីក ពង្រឹងបន្ថែមដើម្បីធ្វើឱ្យសហគមន៍មួយនេះជាសហគមន៍គំរូនិងទទួលបានភ្ញៀវទេសចរកើនឡើងជាលំដាប់និងចំណូលខ្ពស់ជារៀងរាល់ឆ្នាំ ។

## ៣.១ កញ្ចប់សេវាកម្មទេសចរណ៍

នៅក្នុងសហគមន៍របស់យើងក៏មានធ្វើការទទួលរៀបចំជាកញ្ចប់សេវាកម្មទេសចរណ៍ដើម្បីរៀបចំទាំងការស្នាក់នៅ ការហូបចុក ការធ្វើដំណើរ មគ្គុទេសក៍ទេសចរក្នុងការនាំភ្ញៀវទៅកម្សាន្តនៅតំបន់ៗនានារបស់អារ៉ែងយើង បែងចែកទៅតាមប្រភេទភ្ញៀវទេចរ និងរយៈពេលមកកម្សាន្តរបស់ភ្ញៀវ។

### ៣.១.១ កញ្ចប់ធួររយៈពេលខ្លី

#### ៣.១.១.១ សម្រាប់ភ្ញៀវជាក្រុម

បច្ចុប្បន្ននេះ យុវវ័យយើងចូលចិត្តដំណើរកម្សាន្តបែបផ្សងព្រេង ជាពិសេសតំបន់អារ៉ែងជាទីតាំងអតិភាពមួយសម្រាប់ពួកគេក្នុងការមកសម្រាកលំហែ ផ្លាស់ប្តូរ បរិយាកាសរស់នៅជាមួយធម្មជាតិនិងជីវិតសាមញ្ញ។ ពួកគេចូលចិត្តមកជាក្រុមនិងចូលចិត្តបោះតង់ ដើរព្រៃ និងផ្សងព្រេង ។ សម្រាប់ភ្ញៀវប្រភេទនេះគឺងាយស្រួលក្នុងការទទួលពួកគេបំផុតព្រោះពួកគេមានសម្ភារៈផ្ទាល់ខ្លួនក្នុងការប្រើប្រាស់ខ្លះៗ និងអាចចុះសម្រុងជាមួយជីវិតបែបជនបទនិងសាមញ្ញបានគ្រប់រឿង។

#### ៣.១.១.២ សម្រាប់ភ្ញៀវជាគ្រួសារ

ភ្ញៀវទេសចរខ្លះគាត់អញ្ជើញមកជាលក្ខណៈគ្រួសារខ្លះសមាជិកតិចច្រើនទៅតាមនិង សហគមន៍យើងត្រូវធ្វើការរៀបចំនិងត្រៀមទុកជាមុននូវផ្ទះស្នាក់ ម្ហូប និងសេវាកម្មផ្សេងៗដើម្បីទុកបម្រើជូនភ្ញៀវទេសចរឱ្យបានគ្រប់ជ្រុងជ្រោយ។

#### ៣.១.១.៣ សម្រាប់ភ្ញៀវជាក្រុមហ៊ុន

សម្រាប់ភ្ញៀវជាលក្ខណៈក្រុមហ៊ុនយើងត្រូវធ្វើការទំនាក់ទំនងនិងទទួលការកក់ពីក្រុមហ៊ុននូវចំនួនភ្ញៀវទេសចរជាក់លាក់ដើម្បីឱ្យសហគមន៍ធ្វើការរៀបចំនិងចាំទទួលនូវម្ហូបអាហារ ការស្នាក់នៅទាំងផ្ទះស្នាក់និងការបោះតង់ និងត្រៀមទុកនូវសម្ភារៈនានាដើម្បីផ្តល់ជូនភ្ញៀវ។

### ៣.១.២ កញ្ចប់ធូររយៈពេលវែង

#### ៣.១.២.១ សម្រាប់ក្រុមអ្នកស្រាវជ្រាវរុករក

សហគមន៍យើងខ្ញុំក៏មានការទទួលភ្ញៀវទេសចរបែបមកធ្វើការស្រាវជ្រាវ សិក្សាលំអិតពីប្រព័ន្ធជីវៈចម្រុះ។ ពីសត្វព្រៃពីធនធានធម្មជាតិនិងបញ្ហានានាដែលក្រុមអ្នកស្រាវជ្រាវរុករកត្រូវធ្វើការសិក្សាលំអិត។ ភ្ញៀវប្រភេទនេះយើងអាចសិក្សានិងធ្វើការជាមួយពួកគាត់បានយូរ និងទទួលបានសេវាកម្មច្រើននិងចំណូលគួរសម ។

#### ៣.១.២.២ អ្នកចិត្តសាស្ត្រ ធ្វើសមាធិ និងវិបាសនា

ភ្ញៀវទេសចរប្រភេទនេះភាគច្រើនយើងទទួលតែការស្នាក់នៅនិងម្ហូបអាហារនិងជូនពួកគាត់ទៅទីកន្លែងណាដែលធម្មជាតិនិងស្ងប់ស្ងាត់បំផុត ។

### ៣.១.៣ សេវាកម្មគោលសម្រាប់ទទួលភ្ញៀវទេសចរ

សេវាកម្មគោលសម្រាប់ទទួលភ្ញៀវទេសចរមានដូចជា មគ្គុទេសក៍ទេសចរណ៍, ផ្ទះស្នាក់ឬ ជួលតង់, ចុងភៅភូមិ, ទូក, ម៉ូតូឌុប និងគោយន្ត។

**មជ្ឈមណ្ឌលភ្ញៀវទេសចរ** STAR-CBET មានវិសាលភាពដ៏ធំ រួមមាន[113] មជ្ឈមណ្ឌលភ្ញៀវទេសចរចំនួន៤៖ មជ្ឈមណ្ឌលចម្បងចំនួន១ និងមជ្ឈមណ្ឌលរងចំនួន ៣។ រាល់មជ្ឈមណ្ឌលភ្ញៀវទេសចរ មាននូវការិយាល័យ និងអាហារដ្ឋានសហគមន៍ ហើយក៏មានផងដែរនូវគ្រឿងបរិក្ខារសម្រាប់អង្គុយសម្រាក។ វាក៏ជួយបម្រើជាកន្លែងប្រជុំសម្រាប់ទាំងភ្ញៀវ និងប្រជាជនផងដែរ។ មជ្ឈមណ្ឌលភ្ញៀវទេសចរត្រូវបានសាងសង់ឡើង ដោយប្រើប្រាស់វត្ថុធាតុដើមបុរាណដូចជា ឬស្សី និងដបប្លាស្ទិកកែច្នៃឡើងវិញ ជាមួយនឹងការរចនាបែបទំនើប។ ទាំងបុគ្គលិកនិយាយភាសាខ្មែរ និងអង់គ្លេស បានត្រៀមខ្លួនរួចរាល់ ក្នុងការឆ្លើយតបនូវចម្ងល់នានារបស់អស់លោកអ្នក ចាប់ពីម៉ោង ៧ ព្រឹក ដល់ម៉ោង ៧ យប់។

**ភោជនីយដ្ឋានសហគមន៍** មានទីតាំងនៅជាមួយគ្នានឹង មជ្ឈមណ្ឌលភ្ញៀវទេសចរនីមួយៗ ។ ភោជនីយដ្ឋានដំណើរការដោយសហគន៍តំបន់ស្ទឹងអារ៉ែង ក្នុងនោះមានបុគ្គលិកចំនួន ៣៤ នាក់មកពីភូមិនានានៅក្នុងមូលដ្ឋាន[114]។ អាហារទាំងអស់ត្រូវបានចម្អិនដោយប្រើប្រាស់គ្រឿងផ្សំដែលមាននៅក្នុងភូមិស្រាប់ ហើយធ្វើការចម្អិនភ្លាមៗ តាមវិធីចម្អិនបែបប្រពៃណី និងសម័យ។ មុខម្ហូបសម្រាប់អ្នកបរិភោគអាហារបួស និងអ្នកដែលមិនបរិភោគផលិតផលសាច់សត្វ មានបម្រើជូនយ៉ាងងាយស្រួល ហើយប្រសិនបើលោកអ្នកជាអ្នកតមអាហារ ឬមានប្រតិកម្មជាមួយអាហារនានា សូមផ្តល់ដំណឹងជូនបុគ្គលិកយើងខ្ញុំ ដើម្បីពួកយើងអាចធានាបាននូវបទពិសោធន៍ក្នុងការបរិភោគអាហារដ៏ឈ្ងុយឆ្ងាញ់ និងមានផាសុខភាពជូនលោកអ្នក។

---

[113] http://areng-valley.org/kh/aboutus

[114] http://areng-valley.org/kh/food-lodging

**ផ្ទះស្នាក់** ផ្តល់នូវការស្វែងយល់ដ៏វិសេសមួយ អំពីជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកភូមិ ហើយបានផ្តល់ឱ្យភ្ញៀវទេសចរនូវឱកាសដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយប្រជាជនក្នុងមូលដ្ឋាន។ អ្នកភូមិភាគច្រើនមានដីសម្រាប់ធ្វើស្រែ និងដាំបន្លែហើយក៏មានចិញ្ចឹមសត្វផងដែរដូចជា ក្របី មាន់ និងជ្រូក ។ ផ្ទះស្នាក់ របស់ពួកយើងមានបំពាក់នូវផ្ទាំងសូឡាសម្រាប់ផ្តល់នូវថាមពលអគ្គិសនី និងធុងចម្រោះទឹក ដែលផ្តល់នូវទឹកស្អាតសម្រាប់ទទួលទាន។ បន្ទប់ទាំងអស់មានផ្តល់នូវគ្រឿងបរិក្ខារដូចជា គ្រែ មុង កន្សែងជូតខ្លួន កង្ហារ និងស្បែកជើងផ្ទាត់។ បន្ទប់ទឹកនៅដាច់ដោយឡែកពីផ្ទះស្នាក់ និងមានទឹកសម្រាប់ដុសលាងផងដែរ។ ភ្ញៀវប្រហែលជាអាចត្រូវការយកពិល និងគ្រឿងប្រើប្រាស់ក្នុងបន្ទប់ទឹករបស់ពួកគេមកជាមួយផងដែរ។ ផ្ទះស្នាក់ មានតម្លៃ ៦ ដុល្លារក្នុងមួយយប់សម្រាប់មនុស្ស ២នាក់។ ភ្ញៀវទេសចរភាគច្រើនចង់ទទួលទានអាហារពេលល្ងាចជាមួយម្ចាស់ផ្ទះស្នាក់លោកអ្នកក៏អាចចូលរួមបរិភោគអាហារពេលល្ងាចបែបនេះបានដែរ ហើយញ៉ាំនូវរាល់អ្វីដែលម្ចាស់ផ្ទះបានចម្អិន។ យ៉ាងណាក៏ដោយ ម្ចាស់ផ្ទះស្នាក់ភាគតិចណាស់ ដែលអាចនិយាយភាសាអង់គ្លេសបាន ដូច្នេះប្រសិនបើលោកអ្នកត្រូវការអាហារពិសេសអ្វីនោះ សូមប្រាប់បុគ្គលិកសហគមន៍ដោយផ្ទាល់ ដើម្បីអាចជួយរៀបចំជូនតាមតម្រូវការជាមួយនឹងម្ចាស់ផ្ទះស្នាក់។

**បោះតង់** ភាពទាក់ទាញមួយក្នុងចំណោមភាពទាក់ទាញជាច្រើននៅក្នុងតំបន់អារ៉ែង គឺដំណើរកម្សាន្តបោះតង់ដែលជាជម្រើសមួយផ្សេងទៀតសម្រាប់ការស្នាក់នៅ។ សម្រាប់អ្នកដែលចង់បោះតង់សហគមន៍ផ្តល់ជូននូវកម្រាលគេង តង់ ខ្នើយ ភួយ និងសំភារៈចាំបាច់មួយចំនួន។ តំបន់អារ៉ែង មានកន្លែងជាច្រើនសម្រាប់បោះតង់ទាំងនៅក្នុងព្រៃជ្រៅ លើកំពូលភ្នំ និងនៅតាមទឹកឆាយក្បែរភូមិ។ សូមរីករាយទទួលទានអាហារពេលល្ងាចរបស់អ្នក ជាមួយនឹងភ្នក់ភ្លើងជុំរុំ ដែលរៀបចំដោយចុងភៅព្រៃដ៏ជំនាញរបស់សហគមន៍យើងខ្ញុំ ហើយភ្ញាក់ឡើងជាមួយនឹងព្រះអាទិត្យរះដ៏ស្រស់ស្អាត អមដោយសម្លេងបក្សាបក្សី ដែលធ្វើឱ្យលោកអ្នកមិនអាចបំភ្លេចបាន។

តារាងទី១៖ តារាងតម្លៃសេវាកម្ម[115]

| ល.រ | ឈ្មោះសេវាកម្ម | ចំនួន | តម្លៃរៀល | តម្លៃដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ផ្ទះស្នាក់ | ១បន្ទប់គេងបាន២នាក់ | 24,000៛ | 6$ | |
| ២ | អាហារពេលល្ងាចក្នុងភូមិ | ១នាក់ | 14000៛ | 3.5$ | |
| ៣ | អាហារពេលល្ងាចក្នុងព្រៃ | ១នាក់ | 12000៛ | 3$ | |
| ៤ | អាហារពេលថ្ងៃត្រង់ក្នុងភូមិ | ១នាក់ | 14000៛ | 3.5$ | |
| ៥ | អាហារពេលថ្ងៃត្រង់ក្នុងព្រៃ | ១នាក់ | 10.000៛ | 2.5$ | |
| ៦ | អាហារពេលព្រឹកក្នុងភូមិ | ១នាក់ | 10.000៛ | 2.5$ | |
| ៧ | អាហារពេលព្រឹកក្នុងព្រៃ | ១នាក់ | 10.000៛ | 2.5$ | |
| ៨ | កែវយឺតសម្រាប់មើលសត្វព្រៃ | ១គ្រឿង | 10.000៛ | 2.5$ | |
| ៩ | កង់ជួលសម្រាប់ឡើងភ្នំ | ១ថ្ងៃ | 40.000៛ | 10$ | |
| ១០ | តង់សម្រាប់គេងក្នុងព្រៃ | ១ឈុតក្នុងមួយយប់ | 40.000៛ | 10$ | |
| ១១ | អង្រឹងសម្រាប់ជួល | ១យប់ | 8000៛ | 2$ | |
| ១២ | ការបូបស្ពាយពីក្រោយ | ១ថ្ងៃ | 8000៛ | 2$ | |
| ១៣ | មគ្គុទេសក៏នាំភ្ញៀវ | ១នាក់ក្នុងមួយថ្ងៃមួយយប់ | 46000៛ | 11.5$ | |
| ១៤ | ចុងភៅព្រៃសម្រាប់ចម្អិនអាហារក្នុងព្រៃ | ១នាក់ក្នុងមួយថ្ងៃមួយយប់ | 46000៛ | 11.5$ | |
| ១៥ | ទឹកបរិសុទ្ធ | ១ដប=១លីត្រកន្លះ | 3000៛ | 0.75$ | |

**សកម្មភាពសម្រាប់ទទួលភ្ញៀវទេសចរក្នុងការធ្វើដំណើរកម្សាន្តមានជាច្រើនដូចជា**[116]៖ ជិះទូកកម្សាន្ត, ស្ទូចត្រី, ថតរូបអនុស្សាវរីយ៍, ដាក់ម៉ងនេសាទត្រីធម្មជាតិនិងចាប់ក្តាម, អាំងត្រីសាច់ គ្រឿង, សមុទ្រ, បោះតង់លើភ្នំ, បោះតង់លើឆ្នេរខ្សាច់, ជិះទូកកាយ៉ាក, ទស្សនាទឹកធ្លាក់ស្រូបខ្យល់ត្រជាក់និងធម្មជាតិ,ដើរព្រៃ និងឡើងចុះភ្នំ, ងូតទឹកជ្រោះ, ដុតភ្នក់ភ្លើង, ទស្សនាពាងបុរាណ, ទស្សនារូងភ្នំបុរាណ, ទស្សនារបាំ,ប្រពៃណីជនជាតិភាគតិចទស្សនាសត្វព្រៃ

[115] ប្រធានមន្ទីរសហគមន៍អេកូទេសចរណ៍អារ៉ែង

[116] http://areng-valley.org/kh/get-involved

ត្រីនាគ និងក្រពើភ្នំ, មើលឆាយពពកពេលព្រឹក, ស្រូបខ្យល់អាកាសធម្មជាតិលាយឡំជាមួយនិងទឹកសន្សើម និងបោះតង់នៅមាត់អូរ ។

### ៣.១.៤ ផលិតផលទេសចរណ៍

ទន្ទឹមនឹងការរីកចម្រើនឡើងជាលំដាប់នៃចំនួនភ្ញៀវទេសចរដែលបានធ្វើដំណើរមកកាន់សហគមន៍ខាងសហគមន៍ក៏មានគម្រោងក្នុងបើកហាងតូចមួយនៅក្នុងសហគមន៍របស់យើងដើម្បីធ្វើការផលិតនិងលក់ផលិតផលទេសចរណ៍ផ្សេងៗគ្រប់ប្រភេទដែលជាផលិតផលធ្វើដោយដៃ និងជាចម្លាក់ ឬជាប្រភេទដែលអាចបង្ហាញពីអត្តសញ្ញាណជាតិ ពីប្រពៃណី វប្បធម៌ទំនៀមទម្លាប់ របស់យើងផងដែរ វត្ថុអនុស្សាវរីយ៍យើងមានដូចជា៖

#### ៣.១.៤.១ ដបទឹក កែវទឹក សៀវភៅ ប៊ិច បរិស្ថានអាចធ្លាក់រូបបាន

ដបទឹកនេះអាចធ្វើជាវត្ថុអនុស្សាវរីយ៍របស់ប្រើប្រាស់ប្រចាំថ្ងៃមានគ្រប់ម៉ូត និងធ្វើជាការជូនមនុស្សជាទីស្រឡាញ់បាន ហើយវារក្សាទុកសីតុណ្ហភាពបានរយៈពេល ៥ ទៅ ៦ ម៉ោង និងមានចំណុះខុសៗគ្នាចាប់ពី ៣០០ML រហូតដល់ ៥០០ML និងតម្លៃខុសគ្នា។

រូបភាពទី២៤៖ ដបទឹក កែវទឹក សៀវភៅ ប៊ិច បរិស្ថានអាចធ្លាក់រូបបាន[117]




[117] https://www.facebook.com/ArtisansAngkor/

### ៣.១.៤.២ ផ្ទាំងគំនូរ ចម្លាក់ស្បែកគោ និងចម្លាក់នានា

ទាំងនេះគឺជាផ្ទាំងគំនូរដែលគូរដោយដៃផ្ទាល់របស់កូនខ្មែរ ចម្លាក់ស្បែកគោគឺយើងដាប់និងឆ្លាក់វាពីស្បែកគោសុទ្ធនិងធ្វើដោយដៃ ឬឯចម្លាក់នានាក៏យើងឆ្លាក់និងដាប់ដៃតាមរយៈថ្មម៉ាប់ ឬថ្មផ្សេងៗពីគ្នា។

រូបភាពទី២៥៖ ផ្ទាំងគំនូរ[118]





## ៣.២ រចនាសម្ព័ន្ធទីផ្សារ

ដើម្បីទទួលបានភ្ញៀវទេសចរជាច្រើនប្រភេទពីគ្រប់មជ្ឈដ្ឋានយើងត្រូវធ្វើការផ្សព្វផ្សាយពីតំបន់កម្សាន្ត សេវាកម្មនានា ជីវភាពនិងការរស់នៅរបស់ជនជាតិភាគតិច និងប្រជាពលរដ្ឋនៅក្នុងសហគមន៍អារ៉ែង ផ្សព្វផ្សាយលើក

118 https://www.facebook.com/TripTip-TourTravel-247784102581668/

កម្ពស់ពីធនធានធម្មជាតិ សត្វព្រៃ ព្រៃឈើនិងអ្វីផ្សេងៗដែលភ្ញៀវទេសចរគួរតែទៅធ្វើការកម្សាន្តនៅតំបន់អារ៉ែងឱ្យខានតែបាន។

### ៣.២.១ សម្បាទារទីផ្សារ

យើងមានសម្បាទារដើម្បីធ្វើការផ្សព្វផ្សាយពីតំបន់អេកូទេសចរណ៍សហគមន៍អារ៉ែងយ៉ាងទូលំទូលាយនៅក្នុងសម័យកាលឌីជីថលនេះ យើងអាចផ្សព្វផ្សាយបានតាមរយៈ ៖ Website, Brochure, Flyer, Tuk Tuk, PassApp និង Grap។

### ៣.២.២ ទីផ្សារឌីជីថល

នៅក្នុងសម័យកាលទីផ្សារឌីជីថល គឺមានភាពងាយស្រួលចំណាយតិច និងលឿនរហ័សក្នុងការផ្សព្វផ្សាយចែករំលែកពីតំបន់ទេសចរណ៍របស់យើងបានយ៉ាងងាយស្រួល ហើយសហគមន៍យើងក៏មានប្រព័ន្ធផ្សព្វផ្សាយទាំងនោះដូចជា៖ Facebook Page, Google Ads, YouTube, Alexa Certificate ,Twitter Instagram, Pinterest និង Linked IN។

ទំព័រហ្វេសបុកផ្លូវការរបស់យើងខ្ញុំមានឈ្មោះ Steung Areng Community- Based Ecotourism (សហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង) វេបសាយផ្លូវការ ( www.areng-valley.org )

រូបភាពទី២៦៖ Logo Website និង Page ផ្លូវការរបស់សហគមន៍អេកូទេសចរណ៍អារ៉ែង[119]




[119] https://www.facebook.com/arengecotourism/

## ៣.៣ ពង្រឹងគុណភាពសេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធ

### ៣.៣.១ សេវាកម្ម

ដោយបានដឹងពីខាងលើមកហើយថា សហគមន៍អារ៉ែងយើងខ្ញុំមាន ៦សេវាកម្មធំៗ ហើយសេវាកម្មទាំងអស់នោះសុទ្ធសឹងតែសំខាន់និងមានភាពចាំបាច់ក្នុងការទទួលបម្រើទៅកាន់ភ្ញៀវទេសចរគ្រប់រូបហើយសេវាកម្មដែលមានភាពប្រឈមជាងគេក្នុងពេលបច្ចុប្បន្ននេះគឺសេវាកម្មម្ហូបអាហារព្រោះតែតំបន់យើងនៅឆ្ងាយនិងដាច់ស្រយាលពិបាកក្នុងការរកទិញគ្រឿងបន្លែ ត្រីសាច់ទុកបានភ្លាមៗនិងទាន់ពេលប្រសិនបើពេលណាមានភ្ញៀវទេសចរបុកមកកម្សាន្តច្រើននាក់និងមិនបានធ្វើការកក់ទុកជាមុន ។

#### ៣.៣.១.១ ការស្នាក់នៅ

យើងបានដឹងហើយថានៅក្នុងសហគមន៍យើងនេះមានទទួលសេវាកម្មស្នាក់នៅតែ២ផ្នែកប៉ុណ្ណោះគឺះ ផ្ទះស្នាក់ និងបោះតង់។ តាមគម្រោងរបស់យើងសហគមន៍នឹងមានផ្ទះបឹងហ្កាឡូបែបធម្មជាតិ មានសួនផ្កានៅខាងមុខមានពាងមួយនៅពីមុខផ្ទះ និងមានដំណាំតិចតួចនៅជាប់បរិវេនផ្ទះ។ មួយវិញទៀតយើងនឹងមានតង់ធំៗសម្រាប់ដាក់ជួលទាំងសម្រាប់ភ្ញៀវជាលក្ខណៈគ្រួសារឬ ប្តីប្រពន្ធ ឬគូស្នេហ៍ ដើម្បីឱ្យពួកគេមានភាពងាយស្រួលក្នុងការស្នាក់នៅ ហើយការបោះតង់នៅតែមានភាពងាយស្រួលនិងសាមញ្ញសម្រាប់អ្នកចូលចិត្តដើរព្រៃ ឡើងភ្នំជាពិសេសពួកគេអាចបោះតង់ក្រោមតំណក់ទឹកសន្សើមនិងមើលថ្ងៃរះនិងពេលចុះអ័ព្ទ អមជាមួយនិងទេសភាពព្រៃឈើខៀវស្រងាត់ និងស្តាប់សម្លេងសត្វយំនៅតំបន់ធម្មជាតិបែបនេះ ។

#### ៣.៣.១.២ ម្ហូបអាហារ

នៅក្នុងបច្ចុប្បន្ននេះសហគមន៍យើងប្រឈមមុខនិងការខ្វះខាតនូវម្ហូបអារហារដោយសារតែតំបន់យើងនៅដាច់ស្រយាលពីផ្សារនិងទីប្រជុំជនប្រសិនបើមានភ្ញៀវទេសចរមកសម្រាកលំហែរកាយដោយមិនបានកក់ទុកជាមុនយើងពិតជាមិនបានត្រៀមអ្វីទាំងអស់និងមានអាចធ្វើបាននិងរៀបចំបានភ្លាមៗនោះទេ ដូច្នេះហើយតាមគម្រោងរបស់សហគមន៍យើងគឺយើងនឹងចាត់ចែងរកទីតាំងណាធ្វើជាកន្លែងះ

**ចិញ្ចឹមសត្វះ** នៅថ្ងៃខាងមុខយើងនឹងធ្វើការចិញ្ចឹមសត្វគោ មាន់ ទា និងជ្រូក ដើម្បីធ្វើការផ្គត់ផ្គង់នៅសាច់សត្វគ្រប់ប្រភេទទៅកាន់តំរូវការរបស់ចំនួនភ្ញៀវទេសចរដែលបានមកធ្វើដំណើរកម្សាន្តនៅសហគមន៍យើង។

**ដាំបន្លែះ** បន្លែគឺជាគ្រឿងផ្សំចាំបាច់មួយដ៏សំខាន់ក្នុងការក្នុងការផ្គត់ផ្គង់ម្ហូបអារហារទៅកាន់ភ្ញៀវទេសចរ នៅពេលដែលយើងមានបន្លែដាំដុះដោយខ្លួនឯងបានច្រើននិងទូលំទូលាយយើងអាចប្រើប្រាស់បានសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃនិងទុកទទួលភ្ញៀវទេសចរបានដោយងាយស្រួល។

**ស្រះចិញ្ចឹមត្រីះ** យើងអាចធ្វើជាស្រះលំអងមានព្រលិត កាំប្លោក ផ្កាឈូក និងមានចិញ្ចឹមត្រីដើម្បីទុកឱ្យភ្ញៀវគយគន់បាន ។

#### ៣.៣.១.៣ ការដឹកជញ្ជូន

នៅទីនេះយើងមានតែម៉ូតូសម្រាប់ដឹកភ្ញៀវទេសចរទៅកាន់តំបន់មួយទៅកន្លែងមួយទៀត ហើយនិងមានកង់ជួលសម្រាប់អ្នកចង់ហាត់ប្រាណ និងវិធីសាស្ត្រមួយទៀតគឺជិះទូក ឬការណូត ។

### ៣.៣.២ ហេដ្ឋារចនាសម្ព័ន្ធ

#### ៣.៣.២.១ ស្ពាន ផ្លូវថ្នល់ ប៉ុស្តិ៍សុខភាព

ពាក់ព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ផ្លូវថ្នល់នៅសហគមន៍យើងមិនទាន់មានភាពងាយស្រួលនៅឡើយទេ កន្លែងខ្លះក៏ពិបាកធ្វើដំណើរទៅដល់និងគ្មានសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរធម្មតាៗ។ជាក់ស្តែងបើយោងទៅតាមសម្តីរបស់ប្រធានសហគមន៍អេកូទេសចរណ៍អារ៉ែងបាននិយាយថា៖

រាជរាដ្ឋាភិបាលគ្រោងនឹងធ្វើស្ពាន ផ្លូវ ថ្នល់ នៅតំបន់អារ៉ែងនិងគ្រោងសាងសងមន្ទីរពេទ្យបង្អែកព្រោះរាល់ថ្ងៃមានត្រឹមតែប៉ុស្តិសុខភាពប៉ុណ្ណោះ ។

#### ៣.៣.២.២ សេវាសាធារណៈផ្សេងៗ

ចំពោះប្រព័ន្ធទូរស័ព្ទ ទឹកស្អាត ភ្លើងយើងនឹងពង្រីកវាឱ្យបានធំនិងមានវិសាលភាពទូលំទូលាយសម្រាប់ការប្រើប្រាស់របស់ប្រជាជននិងភ្ញៀវទេសចរ។

### ៣.៣.៣ ការវិភាគនៅលើសហគមន៍អេកូទេសចរណ៍អារ៉ែង

#### ៣.៣.៣.១ ភាពខ្លាំង

- ជាតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិ ព្រៃឈើធំនិងក្រាស់ស្រស់ស្អាតជាងគេនៅក្នុងទ្វីអាស៊ីយើងនេះ
- ជាតំបន់ដែលជាជម្រកសត្វព្រៃធំជាងគេ
- ជាតំបន់ដែលសម្បូរទៅដោយសត្វព្រៃកម្រគ្រប់ប្រភេទ
- ជាតំបន់ព្រៃក្រាស់និងធំចុងក្រោយគេរបស់កម្ពុជានិងជាតំបន់ព្រៃត្រូពិចដ៏ធំនិងសំខាន់ជាងគេនៅក្នុងអាស៊ីអាគ្នេយ៍
- សម្បូរទៅដោយទឹកជ្រោះ ជ្រលង ដងអូរ ស្ទឹង
- មានភ្នំបុរាណ ក្រពើភ្នំ និងពាងបុរាណ ដែលនៅសេសសល់
- ការពារប្រព័ន្ធអេកូឡូស៊ីដ៏មានសារៈសំខាន់ ពីការប្រមាញ់សត្វព្រៃ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់
- ជាសហគមន៍គំរូ
- ជាតំបន់ទើបតែបង្កើតសហគមន៍និងជាតំបន់អេកូទេសចរណ៍ដែលបង្កើតភ្លាមទទួលបានការគាំទ្រភ្លាម
- ជាតំបន់ដែលស្ងប់ស្ងាត់ ស្រស់ស្អាតដោយទេសភាពបៃតងខៀវស្រងាត់និងសាកសមបំផុតសម្រាប់អ្នកចូលចិត្តផ្សងព្រេងនិងអ្វីថ្មីៗនិងរស់នៅជាមួយធម្មជាតិ
- ជាតំបន់ដែលសម្បូរទៅដោយជនជាតិភាគតិចនិងប្រជាជនដែលមានការសាមគ្គីភាពល្អ មានការអភិវឌ្ឍ អភិរក្សល្អ ប្រកបដោយនិរន្តភាព

**៣.៣.៣.២ ភាពខ្សោយ**

- ជាតំបន់ដាច់ស្រយាលខ្លាំងពេក
- ពិបាកក្នុងការធ្វើដំណើរទៅដល់ដោយសារមិនទាន់មានស្ពាន ផ្លូវ ថ្នល់ធំៗនិងងាយស្រួលឆ្លងកាត់បាន
- ប្រឈមមុខនិងការខ្វះខាតនូវ សម្ភារៈប្រើប្រាស់ បន្លែ និងសាច់សត្វ
- មិនទាន់មានមន្ទីពេទ្យបង្អែក
- ខ្វះខាតនូវការបណ្តុះបណ្តាលនូវជំនាញវិជ្ជាជីវៈពាក់ព័ន្ធនិងការទទួលភ្ញៀវទេសចរ

**៣.៣.៣.៣ ឱកាស**

- នឹងទទួលបានភ្ញៀវទេសចរជាច្រើនប្រភេទនិងគ្រប់រដូវកាល
- នឹងមានការអភិវឌ្ឍផ្លូវថ្នល់ ស្ពាន មន្ទីពេទ្យបង្អែក
- នឹងមានការផ្គត់ផ្គង់ផ្នែកអាហារ សម្ភារៈប្រើប្រាស់ រីកចម្រើននូវផ្ទះស្នាក់ឬបឹងហ្គាឡូនានាដើម្បីបម្រើឱ្យដល់ភ្ញៀវទេសចរ
- ប្រជាជនមានចំណូលខ្ពស់ ដើម្បីចិញ្ចឹមក្រពះ កាត់បន្ថយចំណាកស្រុក
- នឹងទទួលបានការបណ្តុះបណ្តាលនូវជំនាញវិជ្ជាជីវៈនានា

**៣.៣.៣.៤ កត្តារារាំងនិងគំរាមកំហែង**

- មានការភ័យព្រួយនិងប្រឈមមុខក្នុងការបាត់បង់ពូជសត្វព្រៃ
- សត្វព្រៃក្នុងតំបន់ប្រឈមមុខនិងការផុតពូជ ដោយសារការបរបាញ់សត្វព្រៃខុសច្បាប់
- ប្រឈមមុខនិងការប៉ះពាល់ទៅដល់ធនធានធម្មជាតិ និងតំបន់ប្រវត្តិសាស្ត្រនានា
- ប្រឈមមុខនិងបញ្ហានានានៅពេលដែលមានការអភិវឌ្ឍមានអ្នកចេញចូលច្រើនគឺអាចនឹងប៉ះពាល់ទៅដល់សុវត្ថិភាពក្នុងសហគមន៍ មានការកាប់ព្រៃឈើនិងនាំព្រៃឈើចេញទៅក្រៅនិងមានអំពើរចារកម្មផ្សេងៗ
- ប៉ះពាល់ទៅដល់ការរស់នៅរបស់ប្រជាជនក្នុងសហគមន៍និងក្នុងតំបន់
- ប៉ះពាល់ទៅដល់ធនធានធម្មជាតិនិងតំបន់កម្សាន្តនានា

# សន្និដ្ឋាន

តាមការពិភាក្សាខាងលើយើងបានស្វែងយល់ថា សហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែងជាសហគមន៍មួយដែលមានការគ្រប់គ្រងនិងរចនាសម្ព័ន្ធត្រឹមត្រូវជាតំបន់ដែលមានសក្តានុពលធនធានធម្មជាតិ និងសត្វព្រៃជាតំបន់ព្រៃត្រូពិកដ៏ធំនិងអស្ចារ្យដែលមានទស្សនីយភាពស្អាតនិងធម្មជាតិដាច់គេក្នុងអាស៊ីអាគ្នេយ៍យើងនេះ អារ៉ែងជាតំបន់ដ៏សាកសមបំផុតសម្រាប់អ្នកចូលចិត្តដំណើរកម្សាន្តបែបផ្សងព្រេងនិងធម្មជាតិសុទ្ធសាធមិនថាទាំងការស្នាក់នៅ ការហូបចុកការធ្វើដំណើរនោះទេ គឺសុទ្ធតែទាមទារការអត់ធ្មត់ ព្យាយាម ជួបនិងបញ្ហាផ្សេងៗដើម្បីទម្រាំទៅដល់គោលដៅនីមួយៗបាន។ តំបន់អារ៉ែងជាតំបន់ដែលមានសក្តានុពលធនធានធម្មជាតិជាង៦០កន្លែងនិងតំបន់ប្រវត្តិសាស្ត្រ ឬបុរាណនានាដែលកំពុងមានតួនាទីសំខាន់ក្នុងការបម្រើដល់វិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា។ ដោយសារតែមើលឃើញពីធនធានធម្មជាតិ និងសត្វព្រៃជាច្រើនប្រភេទបែបនេះហើយទើបមានសហគមន៍នេះឡើងដើម្បីការពារនូវបរិស្ថាន ធម្មជាតិ សត្វព្រៃ ការពារអភិរក្សឱ្យបាននៅសត្វព្រៃកម្រៗនិងតំបន់ប្រវត្តិសាស្ត្រនានា និងប្រពៃណីទំនៀមទម្លាប់របស់ជនជាតិភាគតិចផងដែរ។ សព្វថ្ងៃនេះសមាជិកសហគមន៍និងប្រជាពលរដ្ឋក្នុងតំបន់មានការងារធ្វើនិងមានចំណូលខ្ពស់ គ្រប់ៗគ្នាហើយពួកគេក៏មានស្មារតីការពារនិងថែរក្សាឱ្យបាននូវធនធានដែលពួកគេកំពុងតែមាន។ បច្ចុប្បន្ននេះការអភិវឌ្ឍផ្លូវថ្នល់ ស្ពានផ្សេងៗគឺកំពុងតែមាន លំហូរនៃភ្ញៀវទេសចរគ្រប់ប្រភេទក៏មានច្រើន តំបន់ដែលគួរអភិវឌ្ឍន៍ក៏មានច្រើននិងទាក់ទាញការវិនិយោគគិនផ្សេងៗជាច្រើនទៀតដែលកំពុងស្រេកឃ្លាន។ តែយ៉ាងណាមិញទាំងប្រធានសហគមន៍និងប្រជាជន ពួកគេមានស្មារតីខ្ពស់ក្នុងការថែរក្សាការពារតំបន់នេះពីអ្នកវិនិយោគគិននានា និងការអភិវឌ្ឍធំៗដែលអាចធ្វើឱ្យប៉ះពាល់ដល់តំបន់ធម្មជាតិដ៏ស្រស់បំព្រងនិងជាតំបន់ភ្នំ ជួរភ្នំក្រវាញដែលធំនិងស្រស់ស្អាតជាងគេរបស់កម្ពុជា ។

# អនុសាសន៍

ទន្ទឹមនិងការអភិវឌ្ឍ ការអភិរក្ស ការចូលរួមរបស់សហគមន៍ មានសក្តានុពលធនធានធម្មជាតិ ក៏ដូចជាភាពរីកចម្រើននៃតំបន់គោលដៅសហគមន៍ អេកូទេសចរណ៍ ស្ទឹងអារ៉ែង បានទទួល លទ្ធិផលល្អពិតមែនប៉ុន្តែក៏នៅមានចំណុចខ្វះខាតមួយចំនួនកើតឡើងដែរ ដូចនេះខ្ញុំសូមចូលរួមផ្តល់ជាមតិយោបល់តាមរយៈការផ្តល់អនុសាសន៍ដូចខាងក្រោម៖ យើងគប្បី ៖

- ពន្យល់និងបង្ហាញពីការរស់នៅប្រកបដោយគុណភាពអនាម័យទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ឱ្យបានគ្រប់ៗគ្នា
- រក្សាឱ្យបាននៅសេវាកម្មល្អនិងតម្លៃសមរម្យដូចសព្វថ្ងៃមិនឡើងតម្លៃចំថ្ងៃបុណ្យជាតិនានា
- ប្រធានសហគមន៍ចុះបង្រៀនបើកវគ្គខ្លីៗដល់ប្រជាពលរដ្ឋក្នុងការប្រកបរបរនិងផ្តល់សេវកម្មដល់ភ្ញៀវទេសចរឱ្យបានត្រឹមត្រូវនិងស្តង់ដារ
- ប្រធានសហគមន៍ អាជ្ញាធរ កងរាជអាវុធហត្ថ មានការសហការណ៍គ្នាក្នុងការទប់ស្កាត់បទល្មើសផ្សេងៗពីជនខិលខូចដែលមានបំណងចង់លួចកាប់ព្រៃឈើយកទៅលក់ ជួញដូរគ្រឿងញៀន អំពើរចោរកម្មផ្សេងៗដែលកើមានជាយថាហេតុនៅក្នុងតំបន់
- ការពារនិងថែរក្សា អភិរក្សឱ្យបានស្ថិតស្ថេរនិងនិរន្តភាពនៅធនធានធម្មជាតិ តំបន់ទាក់ទាញ សត្វព្រៃ តំបន់បុរាណឬប្រវត្តិសាស្ត្រនានាដើម្បីទុកជាកន្លែងទទួលភ្ញៀវទេសចរណ៍ដែលចូលចិត្តដំណើរបែបផ្សងព្រេងនិងធម្មជាតិ
- ទទួលយកការអភិវឌ្ឍន៍ផ្លូវថ្នល់ និងការកែឆ្នៃ កែប្រែឱ្យមានភាពងាយស្រួលជាងមុននិងមិនប៉ះពាល់ដល់ប្រជាពលរដ្ឋនិងតំបន់សក្តានុពលផ្សេងៗទៀត
- ធ្វើគម្រោងផែនការអភិវឌ្ឍដាំដុះនិងចិញ្ចឹមសត្វបន្ថែមដើម្បីផ្គត់ផ្គង់ម្ហូបអារហារនៅក្នុងតំបន់ពេលមានភ្ញៀវទៅកម្សាន្តច្រើន
- ពង្រឹងសមត្ថភាពរបស់ប្រជាជននៅក្នុងសហគមន៍ដែលមានតួនាទីនាំភ្ញៀវនិងទទួលស្វាគមន៍ភ្ញៀវទេសចរ។

# ឯកសារយោង

# ឯកសារយោង


I. **ឯកសារយោងជាភាសាខ្មែរ**

១. បណ្ឌិតសួនវ៉ានី ទ្រឹស្តីនិងទស្សនៈមូលដ្ឋាន២០០៦

២. សៀវភៅផែនការអភិវឌ្ឍន៍ទេសចរណ៍របស់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

៣. របាយការណ៍របស់អង្គការទេសចរណ៍ពិភពលោក

៤. thecbca.weebly.com ជំពូកទី២ រចនាសម្ព័ន្ធទូទៅ របស់សហគមន៍

៥. សៀវភៅអេកូទេសចរណ៍ Eco-Tourism, ភ្នំពេញ ឆ្នាំ២០១៤, អ្នកនិពន្ធ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី, បណ្ឌិតហុងវណ្ណៈនិងបណ្ឌិត ឈឹមផាន់ណា

៦. ក្រសួងទេសចរណ៍ "ច្បាប់ស្តីពី ភ្នំពេញ" ,២០០៩

៧. វ៉ា ស៊ីហេង ស៊ុំ សុចិន្តា និងហុង វណ្ណៈ, អេកូទេសចរណ៍, ភ្នំពេញ ២០០៦

៨. ច្បាប់ស្តីទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ២០០៩

៩. សេចក្តីណែនាំអំពីអេកូទេសចរណ៍

១០. សហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែង

១១. ប្រធានសហគមន៍អេកូទេសចរណ៍អារ៉ែង ទិត្យ លី

១២. និរន្តរភាពនៃអេកូទេសចរណ៍ ឆ្នាំ២០១២ ដោយ បណ្ឌិត ស៊ួន វ៉ានី និងបណ្ឌិត ឈឹម ផាន់ណា

១៣. ផែនការទេសចរណ៍និងការអភិវឌ្ឍ ឆ្នាំ២០១៣ដោយ បណ្ឌិត ស៊ួន វ៉ានី និង បណ្ឌិត ឈឹម ផាន់ណា

១៤. អេកូទេសចរណ៍រៀបរៀងដោយ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី បណ្ឌិ ឈឹម ផាន់ណា បណ្ឌិត ហុង វណ្ណៈ ឆ្នាំ២០១៤

១៥. ការអភិវឌ្ឍនិងផែនការទេសចរណ៍ប្រកបដោយនិរន្តភាព រៀបរៀងដោយ បណ្ឌិត ឈឹម ផាន់ណា ឆ្នាំ២០១៨

១៦.ផែនការយុទ្ធសាស្រ្តក្នុងការអភិវឌ្ឍទេសចរណ៍ឆ្នាំ ២០១២ -២០២០ គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩ ២០៣០អនុម័តដោយគណៈរដ្ឋមន្រ្តីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៩ ខែវិច្ឆកា ឆ្នាំ២០១៨, pdf

១៧. វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត គ.ស.១៩៦៧, ទំព័រ៩៩០

១៨. សួន វ៉ានី, ប្រតិបត្តិការដំណើរទេសចរណ៍ និងខ្សែទស្សនកិច្ច ភ្នំពេញ

១៩. សួន វ៉ានី និងហុង វណ្ណៈ, និរន្តភាពនៃការអភិវឌ្ឍទេសចរណ៍, ភ្នំពេញ ២០១២

២០. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍទេសចរណ៍ ២០១២-២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា

២១. ផែនដី និងបរិស្ថានវិទ្យា កម្មវិធីសិក្សាថ្នាក់ទី១១, ២០០០

២២. http://www.areng-valley.org/

២៣. https://khmertomorrow.com/areng-koh-kong-biodiversity-sanctuary-kh/

២៤. https://visitcambodia.travel/kh/

២៥. ams.com.kh

២៦. Moe.gov.kh

II. **ឯកសារយោងជាភាសាបរទេស**

១. Stan MCGAHEY, The Ethics, Obligations, and Stake Holders of Ecotourism Marketing, United States, 2012

២. The International Ecotourism Society, 1990

៣. The International Ecotourism Strategy 1994

៤. www.conversation.org/xp/CIWEB/programs/ecotourism.xml

៥. IUCN, 1996

៦. www.merriam-webster.com/dictionary

៧. Sdt.unwto.org/en/content/ecotourism-and-protected-areas, 2013

៨. Tin Ponlok, Dictionary of Environment Terms, Phnom Penh

៩. Nigel Daunly, Guidelines for Applying Protected Area Management Categories, IUCN, Gland, Switzerland, 2008

១០. Liliane Pasape, Towards Sustainable Ecotourism through Stakeholder Collaborations in Tanzania, Department of Marketing, University of Dar es Salaam December 26

១១. https://www.wildlifealliance.org/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# កម្រងសំណួរសម្រាប់ សហគមន៍អេកូទេសចរណ៍ អារ៉ែង

សូមគោរពជូនលោកប្រធានសហគមន៍អេកូទេសចរណ៍ ស្ទឹងអារ៉ែង ខេត្តកោះកុង ពួកយើងខ្ញុំជានិស្សិតនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកទេសចរណ៍និងបដិសណ្ឋារកិច្ច ឆ្នាំទី៤ ជំនាន់ទី៧ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើសហគមន៍អេកូទេសចរណ៍ អារ៉ែង ខេត្តកោះកុង ។

## ក្រោមប្រធានបទ

« **ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ អារ៉ែង** » ដូចច្នេះហើយក្រុមយើងខ្ញុំបានរៀបចំជាសំណួរសំខាន់ៗពាក់ព័ន្ធនិងផែនការយុទ្ធសាស្ត្រផ្សេងៗប្រចាំសហគមន៍អារ៉ែង ។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាផ្តល់នូវអនុសាស ជាពត៌មាន ឯកសារ ដល់ក្រុមយើងខ្ញុំដើម្បីធ្វើជាមូលដ្ឋានក្នុងការសរសេរសារណាសម្រាប់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយក្តីអនុគ្រោះ ។

១. តើសហគមន៍អេកូទេសចរណ៍អារ៉ែងផ្តួចផ្តើមបង្កើតឡើងដំបូងដោយអ្នកណា?

២. តើសហគមន៍អារ៉ែងបង្កើតឡើងក្នុងឆ្នាំណា ? ហើយមានសមាជិកប៉ុន្មានគ្រួសារចូលរួម?

៣. តើមានកត្តាសំខាន់ៗអ្វីខ្លះទើបបណ្តាលឱ្យមានការកកើតឡើងនូវសហគមន៍មួយនេះ?

៤. តើសហគមន៍អារ៉ែងមានរចនាសម្ព័ន្ធគ្រប់គ្រងយ៉ាងដូចម្តេចខ្លះ?

៥. តើសហគមន៍អារ៉ែងមានសកម្មភាពអ្វីខ្លះសម្រាប់បម្រើឱ្យវិស័យទេសចរណ៍ក្នុងស្រុកនិងតំបន់?

៦. តើសហគមន៍មានការណែនាំ បទបញ្ជាផ្ទៃក្នុង បណ្តុះបណ្តាលវិជ្ជាជីវៈទៅប្រជាជនយ៉ាងដូចម្តេចខ្លះ?

៧. តើសហគមន៍នេះមានបែងចែកតំបន់កម្សាន្តជាប៉ុន្មានផ្នែកនិងមានសេវាកម្មទេសចរណ៍អ្វីខ្លះ?

៨. តើសហគមន៍ទទួលបានចំណូលជាមធ្យមប៉ុន្មានប្រចាំឆ្នាំ និងចំនួនភ្ញៀវទេសចរមកកម្សាន្តជាលក្ខណៈប្រភេទអ្វីខ្លះ?

៩. តើសេវាកម្មណាដែលទទួលបានការគាំទ្រជាងគេនៅក្នុងសហគមន៍?

១០. តើសហគមន៍អេកូទេសចរណ៍អារ៉ែងមានផែនការយុទ្ធសាស្ត្រយ៉ាងណាខ្លះក្នុងការអភិវឌ្ឍសហគមន៍ប្រកបដោយនិរន្តភាព ?

១១. តើសហគមន៍មានដៃគូពាក់ព័ន្ធ និងដៃគូសហការណាខ្លះក្នុងការចូលរួមចំណែកអភិវឌ្ឍ ?

១២. តើសហគមន៍មានផែនការនិងយុទ្ធសាស្ត្រនានាក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ក្នុងតំបន់យ៉ាងដូចម្តេច?

១៣. តើសហគមន៍មានផែនការរៀបចំហិរញ្ញវត្ថុនិងប្រមូលថវិការសម្រាប់ការអភិវឌ្ឍសហគមន៍យ៉ាងដូចម្តេច?

១៤. តើសហគមន៍មានផែនការបែបណាដើម្បីធ្វើការធានាជូនផ្តល់នូវជាសុខភាពសម្រាប់ភ្ញៀវទេសចរ?

១៥.តើសហគមន៍មានវិធីសាស្រ្តបែបណាក្នុងការផ្តល់សេវាកម្មល្អដើម្បីឱ្យភ្ញៀវមកកម្សាន្តពេលក្រោយទៀត?
១៦.តើសហគមន៍មានផែនការបែបណាក្នុងការរកចំណូលបន្ថែមមកកាន់សហគមន៍?
១៧.តើសហគមន៍មានផែនការបែបណាដើម្បីធានាឱ្យបាននូវផលប៉ះពាល់នានាចំពោះបរិស្ថាន ជីវៈចម្រុះ។ អេកូឡូស៊ី?
១៨.តើសហគមន៍មានផែនការរយៈពេលបីឆ្នាំទៅមុខទៀតក្នុងការអភិវឌ្ឍសហគមន៍យ៉ាងដូចម្តេច?

# ឧបសម្ព័ន្ធទី២
# កម្រងសំណួរសិក្សាស្រាវជ្រាវ
# សម្រាប់ ៖ ទេសចរ
# ក្រោមប្រធានបទ
# ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍គោលដៅទេសចរណ៍ សហគមន៍អេកូទេសចរណ៍អារ៉ែង

ជំរាបសួរ លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព យើងខ្ញុំជានិស្សិតឆ្នាំទី០៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចដែលបានចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យយកមកសិក្សា ដើម្បីរៀបចំធ្វើកិច្ចការស្រាវជ្រាវរបស់សាលា។ អាស្រ័យហេតុនេះ សូមលោក លោកស្រី អ្នកនាងកញ្ញា មេត្តាចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក ដើម្បីជួយផ្តល់នូវចម្លើយដែលលោកអ្នកពេញចិត្ត។ យើងខ្ញុំសូមជម្រាបថា រាល់ទិន្នន័យដែលបានពីកម្រង សំណួរនេះ គឺប្រើប្រាស់ក្នុងគោលដៅសំរាប់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

## I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទ

☐ ប្រុស ☐ ស្រី

២. អាយុ

☐ ១៨ឆ្នាំ -២៥ឆ្នាំ ☐ ២៦ឆ្នាំ -៣០ឆ្នាំ ☐ ៣០ឆ្នាំ -៣៥ឆ្នាំ ☐ ៣៦ឆ្នាំ -៤០ឆ្នាំ

៣. មុខរបរ

☐ និស្សិត ☐ មន្ត្រីរាជការ ☐ កសិករ ☐ អ្នកជំនួញ

☐ លក់ដូរ ☐ មេផ្ទះ ☐ បុគ្គលិកអង្គការ ☐ ផ្សេងៗ

## II. ព័ត៌មានទូទៅ

១. តើអ្នកស្គាល់សហគមន៍អេកូទេសចរណ៍អារ៉ែងតាមរយៈអ្វី?

☐ ទូរទស្សន៍ ☐ ទស្សនាវត្តី ☐ ក្រុមហ៊ុនទេសចរណ៍ ☐ មិត្តភក្តិ

☐ បងប្អូន ☐ ផ្សេងៗ

២. តើអ្នកធ្លាប់មកទស្សនាសហគមន៍អេកូទេសចរណ៍អារ៉ែងប៉ុន្មានដង?

☐ លើកទី១ ☐ ១ដង ☐ ២ដង ☐ ៣ដង ☐ លើសពី៣ដង

៣. តើអ្នកប្រើមធ្យោបាយបែបណា ក្នុងការធ្វើដំណើរមកកាន់សហគមន៍អេកូទេសចរណ៍អារ៉ែងនេះ?

☐ រថយន្តផ្ទាល់ខ្លួន ☐ រថយន្តឈ្នួល ☐ ម៉ូតូ ☐ ឡានក្រុង ☐ ផ្សេងៗ

៤. តើអ្នកមកទស្សនាសហគមន៍អេកូទេសចរណ៍អារ៉ែង ក្នុងគោលបំណងអ្វី?

☐ លំហែរកម្សាន្ត ☐ សិក្សាស្រាវជ្រាវ ☐ សួរសុខទុក្ខបងប្អូន មិត្តភក្តិ ☐ ផ្សេងៗ

៥. តើអ្នកមានគោលបំណងមកកម្សាន្តសហគមន៍អេកូទេសចរណ៍អារ៉ែងប៉ុន្មានថ្ងៃ?

☐ ១ថ្ងៃ ☐ ២ថ្ងៃ ☐ ៣ថ្ងៃ ☐ លើសពី៣ថ្ងៃ

៦. តើអ្នកធ្លាប់ទៅទស្សនាសហគមន៍អេកូទេសចរណ៍ ក្នុងឱកាសអ្វី?

☐ បុណ្យជាតិ ☐ ថ្ងៃឈប់សម្រាក ☐ វិស្សមកាល ☐ ផ្សេងៗ

៧. តើអ្នកមកទស្សនាកម្សាន្តសហគមន៍អេកូទេសចរណ៍អារ៉ែង ក្នុងលក្ខណបែបណា?

☐ បុគ្គល ☐ ក្រុមគ្រួសារ ☐ មិត្តភក្តិ ☐ ផ្សេងៗ

៨. តើអ្នកចំណាយទៅលើអ្វីខ្លះ នៅក្នុងអំឡុងពេលដែលអ្នកមកទស្សនាកម្សាន្ត នៅសហគមន៍អេកូទេសចរណ៍អារ៉ែង?

☐ សេវាកម្មដឹកជញ្ជូន ☐ សេវាកម្មស្នាក់នៅ ☐ សេវាកម្មម្ហូបអាហារ ☐ ផ្សេងៗ

៩. តើផ្លូវចូលទៅកាន់សហគមន៍អេកូទេសចរណ៍អារ៉ែង មានលក្ខណៈបែបណា

☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១០. តើអ្នកទទួលទានអាហារនៅកន្លែងណា នៅពេលដែលអ្នកទៅទស្សនាកម្សាន្តនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង?

☐ ផ្ទះស្នាក់សហគមន៍ ☐ អាហារដ្ឋាន ☐ ផ្ទាល់ខ្លួន

១១. តើអ្នកគ្រប់គ្រងក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានលក្ខណៈបែបណាដែរ?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១២. តើធនធានទាក់ទាញទេសចរណ៍ នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានលក្ខណៈបែបណា?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៣. តើអ្នកយល់យ៉ាងណាដែរ ចំពោះសន្តិសុខ និងសុវត្ថិភាពនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៤. តើការគ្រប់គ្រងកាកសំណល់ នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងយ៉ាងដូចម្តេច?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៥. តើអ្នកយល់យ៉ាងណាដែរ ចំពោះបរិស្ថាននៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ កង្វក់ ☐ កង្វក់ណាស់

១៦. តើអ្នកយល់យ៉ាងណាដែរ ចំពោះសេវាកម្មដែលផ្តល់ដោយប្រជាសហគមន៍អេកូទេសចរណ៍អារ៉ែង?

☐ ល្អ ☐ ល្អណាស់ ☐ មធ្យម ☐ ខ្សោយ ☐ ខ្សោយណាស់

១៧. តើអ្នកយល់យ៉ាងណាដែរ ចំពោះអាកប្បកិរិយារបស់ប្រជាជននៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង?

☐ រួសរាយ ☐ គំរូសគំរើស ☐ ឆ្មើងឆ្មៃ ☐ ធម្មតា ☐ ផ្សេងៗ

១៨. តើសកម្មភាពណាខ្លះដែលអ្នកចូលចិត្ត និងមិនចូលចិត្តនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង?

| | ចូលចិត្ត | មធ្យម | មិនចូលចិត្ត |
|---|---|---|---|
| ទស្សនាតាមភូមិក្នុងសហគមន៍ | ☐ | ☐ | ☐ |
| ថតរូបអនុស្សាវរីយ៍ | ☐ | ☐ | ☐ |
| ទិញផលិតផលក្នុងសហគមន៍ | ☐ | ☐ | ☐ |
| ទិញវត្ថុអនុស្សាវរីយ៍ | ☐ | ☐ | ☐ |
| ជិះទូកកម្សាន្ត | ☐ | ☐ | ☐ |

| | | | |
|---|---|---|---|
| ជិះកង់កម្សាន្ត | ☐ | ☐ | ☐ |
| ទស្សនារូងប្រចៀវ | ☐ | ☐ | ☐ |
| ទស្សនាពាងបុរាណ និងម្សូសបុរាណ | ☐ | ☐ | ☐ |

១៩. តម្លៃសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ឬសេវាកម្មដទៃទៀត នៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានលក្ខណៈយ៉ាងណាដែរ?

| | ចូលចិត្ត | មធ្យម | មិនចូលចិត្ត |
|---|---|---|---|
| សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ | ☐ | ☐ | ☐ |
| សេវាកម្មស្នាក់នៅ | ☐ | ☐ | ☐ |
| វត្ថុអនុស្សាវរីយ៍ | ☐ | ☐ | ☐ |
| ផលិតផលក្នុងតំបន់ | ☐ | ☐ | ☐ |
| ជិះទូកកម្សាន្ត | ☐ | ☐ | ☐ |
| ជិះកង់កម្សាន្ត | ☐ | ☐ | ☐ |

២០. តើស្លាកសញ្ញាបង្ហាញទិសនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែងមានគ្រប់គ្រាន់ដែរឬទេ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់ ☐ មិនទាន់មាន

២១. បើមានឱកាស តើអ្នកចង់មកទស្សនាកម្សាន្តសហគមន៍អេកូទេសចរណ៍អារ៉ែងនេះម្តងទៀតដែរឬទេ?

☐ ចង់ ☐ មិនចង់ ☐ ពិចារណាម្តងទៀត

២២. សម្រាប់គំនិតរបស់អ្នក តើអ្នកចង់ឱ្យសហគមន៍អេកូទេសចរណ៍បង្កើតនូវផលិតផលឬសេវាកម្មថ្មីអ្វីទៀតដែរឬទេ?

២៣. តើអ្នកមានមតិយោបល់ ឬសំណូមពរ ក្នុងការកែលម្អ គ្រប់គ្រង និងអភិវឌ្ឍន៍ ក៏ដូចជាអភិរក្សសហគមន៍

អេកូទេសចរណ៍ងអារ៉ែង ឱ្យមានការរីកចម្រើន ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ទាំងជាតិ និងអន្តរជាតិឱ្យចូលមកកម្សាន្តកាន់តែច្រើនឡើងដែរឬទេ?

**ឧបសម្ព័ន្ធទី៣**

**កម្រងសំណួរសិក្សាស្រាវជ្រាវ**

**សម្រាប់ ៖ អាជីវករ និងប្រជាពលរដ្ឋមូលដ្ឋាន**

**ក្រោមប្រធានបទ**

# ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍គោលដៅទេសចរណ៍ សហគមន៍អេកូទេសចរណ៍អារ៉ែង

ជំរាបសួរ លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរព យើងខ្ញុំជានិស្សិតឆ្នាំទី០៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចដែលបានចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យយកមកសិក្សា ដើម្បីរៀបចំធ្វើកិច្ចការស្រាវជ្រាវរបស់សាលា។ អាស្រ័យហេតុនេះ សូមលោក លោកស្រី អ្នកនាងកញ្ញា មេត្តាចំណាយពេលវេលាដ៏មានតម្លៃរបស់លោកអ្នក ដើម្បីជួយផ្តល់នូវចម្លើយដែលលោកអ្នកពេញចិត្ត។ យើងខ្ញុំសូមជម្រាបថា រាល់ទិន្នន័យដែលបានពីកម្រង សំណួរនេះ គឺប្រើប្រាស់ក្នុងគោលដៅសំរាប់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

## I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទ

☐ ប្រុស ☐ ស្រី

២. អាយុ

☐ ១៨ឆ្នាំ -២៥ឆ្នាំ ☐ ២៦ឆ្នាំ -៣០ឆ្នាំ ☐ ៣០ឆ្នាំ -៣៥ឆ្នាំ ☐ ៣៦ឆ្នាំ -៤០ឆ្នាំ

៣. មុខរបរ

☐ និស្សិត ☐ មន្រ្តីរាជការ ☐ កសិករ ☐ អ្នកជំនួញ

☐ លក់ដូរ ☐ មេផ្ទះ ☐ បុគ្គលិកអង្គការ ☐ ផ្សេងៗ

## II. ព័ត៌មានទូទៅ

១. តើអ្នកប្រកបអាជីពនេះអស់រយៈពេលប៉ុន្មានឆ្នាំមកហើយ?

☐ ១ឆ្នាំ ☐ ២ឆ្នាំ ☐ ៣ឆ្នាំ ☐ លើសពី៣ឆ្នាំ

២. តើអ្នកចេះពីរបៀបធ្វើម្ហូបនេះមកពីណា?

☐ គ្រួសារ ☐ ខ្លួនឯង ☐ បណ្ដុះបណ្ដាល

៣. តើគ្រឿងផ្សំដែលអ្នកយកមកប្រើប្រាស់ក្នុងការធ្វើម្ហូបមានប្រភពមកពីណា?

☐ ផ្សារ ☐ ដាំដុះដោយខ្លួនឯង ☐ ផលិតផលក្នុងស្រុក

៤. តើចំណូលជាមធ្យមរបស់អ្នកជាប្រចាំថ្ងៃទទួលបានប៉ុន្មាន?

៥. ក្រៅពីរបរនេះ តើអ្នកមានមុខរបរចិញ្ចឹមជីវិតផ្សេងទៀតដែរឬទេ?

☐ មាន ☐ មិនមាន

៦. តើអ្នកមានផ្ទះសំរាប់ជួលឱ្យភ្ញៀវទេសចរស្នាក់អាស្រ័យដែរឬទេ? បើមានក្នុងតម្លៃប៉ុន្មាន?

៧. តើពេលកន្លងមក អ្នកតែងតែជួបបញ្ហាអ្វីខ្លះ សម្រាប់អាជីពមួយនេះ?

៨. តើអ្នកមានដំណោះស្រាយលើបញ្ហាទាំងអស់នោះដោយរបៀបណា?

៩. តើនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានប្រព័ន្ធទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ហើយឬនៅ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១០. តើនៅក្នុងសហគមន៍អេកូទេសចរណ៍អារ៉ែង មានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ហើយឬនៅ?

☐ គ្រប់គ្រាន់ ☐ មិនទាន់គ្រប់គ្រាន់

១១. តើស្ថាប័នពាក់ព័ន្ធ ឬអាជ្ញាធរមូលដ្ឋានដែលធ្វើការបណ្តុះបណ្តាលលើផ្នែកសេវាកម្មដល់អ្នកដែរឬទេ?

☐ ម្តងម្កាល ☐ ញឹកញាប់ ☐ មិនដែលទាល់តែសោះ

១២. តើកាកសំណល់ដែលអ្នកប្រើប្រាស់រួចហើយ តើអ្នកយកវាទៅបោះចោលទីណា?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

## ឧបសម្ព័ន្ធទី៤

ផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទេសចរណ៍ឆ្នាំ ២០១២ -២០២០ គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩ ២០៣០អនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៩ ខែវិច្ឆកា ឆ្នាំ២០១៨

**៤.១. ធ្វើផែនការ និងបែងចែកជាតំបន់អេកូទេសចរណ៍អាទិភាព និងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍គំរូ**

(២៧). យុទ្ធសាស្ត្រក្នុងការធ្វើផែនការ និងបែងចែកជាតំបន់អាទិភាព និងការរៀបចំរមណីយដ្ឋានអេកូទេសចរណ៍ រួមមាន៖

- កំណត់ជាតំបន់អេកូទេសចរណ៍អាទិភាពចំនួន៤ រួមមាន៖ តំបន់ភូមិភាគឦសាន្ត តំបន់បឹងទន្លេសាប និងទន្លេមេគង្គ តំបន់ឆ្នេរសមុទ្រ និងតំបន់ជួរភ្នំក្រវាញ ព្រមទាំងធ្វើការកំណត់អត្តសញ្ញាណកម្ម (Mapping) រមណីយដ្ឋានអេកូទេសចរណ៍នៅតាមតំបន់អាទិភាពនីមួយៗ។
- រៀបចំអភិវឌ្ឍជារមណីយដ្ឋានអេកូទេសចរណ៍គំរូយ៉ាងហោចមួយនៅតាមតំបន់អាទិភាពនីមួយៗ ដែលអាចបម្រើឱ្យភ្ញៀវទេសចរស្នាក់នៅរយៈពេលខ្លី មធ្យម និងវែង (ទេសចរផ្ទះទីពីរ)។
- តម្រូវឱ្យមានផែនការមេអភិវឌ្ឍអេកូទេសចរណ៍សម្រាប់គម្រោងអភិវឌ្ឍអេកូទេសចរណ៍នីមួយៗ ដោយត្រូវគិតគូរអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផង និងឆ្លើយតបតម្រូវការចាំបាច់នៃការអភិវឌ្ឍឱ្យបានជាអតិបរមាផង ស្របតាមគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍។
- រាល់គម្រោងអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ត្រូវមាន៖
  - ត្រូវមានការកំណត់តួនាទីច្បាស់លាស់នៃគ្រប់ភាគីពាក់ព័ន្ធ។



ж

  - ត្រូវមានគម្រោងអាជីវកម្មសម្រាប់រាល់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ យន្តការបែងចែកប្រាក់ចំណេញ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយ គំរូហិរញ្ញប្បទាន ផែនការគ្រប់គ្រងហានិភ័យជាដើម
  - ត្រូវមានការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង និងរាវច្បាស់លាស់។
  - ត្រូវមានយន្តការគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចណ៍។
  - ត្រូវមានការវិភាគសមត្ថភាពផ្ទុកនៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ដើម្បីកំណត់បរិមាណអតិបរមានៃភ្ញៀវទេសចរចូលទស្សនាតាមរមណីយដ្ឋាននីមួយៗ។
- រៀបចំឱ្យមានមូលនិធិទ្រទ្រង់ដល់ការសិក្សារៀបចំគម្រោងក្នុងដំណាក់កាលសមិទ្ធលទ្ធភាព។
- តម្រូវឱ្យអ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ គឺជាសហគមន៍មូលដ្ឋានសម្រាប់រាល់គម្រោងស្ថិតលើទីតាំង ដែលមានប្រជាសហគមន៍មូលដ្ឋានស្រាប់។
- រៀបចំបទដ្ឋានគតិយុត្តសំរាប់គ្រប់គ្រងលើការតុបតែងរចនា ការស្ថាបនា និងប្រតិបត្តិការ (DBO) នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ចាំបាច់នានាក្នុងរមណីយដ្ឋានអេកូទេសចរណ៍។

# ឧបសម្ព័ន្ធទី៥

ប្រធានសហគមន៍អេកូទេសចរណ៍ អារ៉ែង

**រចនាសម្ព័ន្ធគ្រប់គ្រងរបស់**
**គណៈកម្មការសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង**



# ឧបសម្ព័ន្ធទី៦

ព័ត៌មានទាក់ទងទៅនិងប្រតិភូក្រសួងបរិស្ថានស្វែងយល់ពីការពង្រឹងជីវភាពសហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែង

https://ams.com.kh/central/detail/31333 (ចុះផ្សាយថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០)

AMS CENTRAL

ទំព័រដើម > ព័ត៌មាន > ប្រតិភូក្រសួងបរិស្ថានស្វែងយល់ពីការពង្រឹងជីវភាពសហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែង



## ប្រតិភូក្រសួងបរិស្ថានស្វែងយល់ពីការពង្រឹងជីវភាពសហគមន៍អេកូទេសចរណ៍ស្ទឹងអារ៉ែង

ព័ត៌មាន

ដោយ៖ Sereyvuth Kien | May 4, 2020 |

ចំនួនទស្សនា៖ 118

ឯកឧត្តម សៅ សុភាព និង ឯកឧត្តម ស្រ៊ុន ដារិទ្ធ រដ្ឋលេខាធិការក្រសួងបរិស្ថាន បានដឹកនាំប្រតិភូ

# ឧបសម្ព័ន្ធទី៧

ព័ត៌មានទាក់ទងទៅនិងតំបន់អារ៉ែង

KHMERTOMORROW

ទាន់ហេតុការណ៍ ាប់បន្ទាប់ពីចាក់វ៉ាក់សាំងដូសទី៣ | លោក Duong


សារព័ត៌មាន KhmerTomorrow គេហទំព័រព័ត៌មាន
ដែលមានប្រភពច្បាស់លាស់ ទទួលស្គាល់ដោយក្រសួងព័ត៌មាន
https://t.me/khmertomorrow





ឌីហ្សាញដាក់ខែ...
WAM Digital
010 761 107


កម្សាន្ត

## តំបន់អារ៉ែង ពួនសម្ងំយ៉ាងជ្រៅក្នុងដងបុព្វតា ល្បីថាអាស្ចារ្យស្អាតខ្លាំងដូចក្នុងរឿងនិទាន

ថ្ងៃទី25 ខែ01 ឆ្នាំ2021 0 607 views

,នសម្ងំយ៉ាងជ្រៅក្នុងដងបុព្វតា ដងស្ទឹងអារ៉ែង បាន